# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

**Universite Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**

**សារណាបញ្ចប់ការសិក្សា**

# កិច្ចសន្យាបញ្ញើ

ស្រាវជ្រាវពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


ស្រាវជ្រាវដោយនិស្សិត

និស្សិតឈ្មោះ៖ **ជា ស៊ីវជូ**

**លិន ឈីម៉ូលី**

សាស្ត្រាចារ្យណែនាំ

**លោក ញឹក វុឌ្ឍី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា២០២២

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីរនាក់ឈ្មោះ **ជា ស៊ីវជូ** និង **លិន ឈីម៉ូលី** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំ២០១៨-២០២២។

**សូមគោរព និងសម្តែងនូវកតញ្ញូតាធម៌ដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ ៖**

- លោកឪពុក **ជា គេងម៉ូ** និងអ្នកម្តាយ **នង លក្ខិណា**
- លោកឪពុក **ខ៉េត ស្រស់** និងអ្នកម្តាយ **អ៊ុំ ស៊ីនេត**

សូមគោរពដឹងគុណ និងអរគុណ ដល់លោកអ្នកមានគុណ ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មាន ប្រៀនប្រដៅ ព្រមទាំងខិតខំយ៉ាងលំបាកដើម្បីទំនុកបម្រុងឱ្យរូបកូនមានឱកាសក្នុងការសិក្សារៀនសូត្ររហូតដល់បានបញ្ចប់ការសិក្សា ថ្នាក់បរិញ្ញាបត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ លោកទាំងពីរ តែងតែជម្រុញ និងលើកទឹកចិត្តឱ្យរូបកូនខំពុះពារគ្រប់បញ្ហាដើម្បីក្លាយជាមនុស្សថ្លៃថ្នូរ និងមានតម្លៃនៅក្នុងសង្គម។

យើងខ្ញុំក៏សូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ ក្រសួងអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលមាន៖

- ឯកឧត្តមបណ្ឌិត **លុយ ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិង វិទ្យាសាស្ត្រសេដ្ឋកិច្ច។ ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ព្រមទាំងលោក-លោកស្រីបណ្ឌិត លោក-លោកស្រី សាស្ត្រាចារ្យ និងលោក-លោកស្រី មន្ត្រីរាជការសាលា ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានបង្ហាត់បង្រៀន និងរិះរកនូវគ្រប់មធ្យោបាយក្នុងការដោះស្រាយបញ្ហា ដើម្បីផ្តល់ភាពងាយស្រួល ផ្តល់សុខសុវត្ថិភាពដល់និស្សិតគ្រប់រូប ដែលបានជួបប្រទះបញ្ហាក្នុងការសិក្សា ក្នុងអំឡុងពេលកូវីត-១៩ ផងដែរ ។
- ជាពិសេស សូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅ ដល់លោកគ្រូ សាស្ត្រាចារ្យ **ញឹក ឧុឌ្ឋី** ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការបង្ហាត់បង្ហាញ ណែនាំ ផ្តល់ចំណេះដឹង និងជួយផ្តល់នូវអនុសាសន៍ទាក់ទងទៅនិងប្រធានបទសារណារបស់យើងខ្ញុំ ព្រមទាំងជួយកែតម្រូវនូវរាល់កំហុសខុសឆ្គងដែលកើតមានឡើងក្នុងសារណារហូតទាល់តែសារណាយើងខ្ញុំ មានភាពល្អកាន់តែប្រសើរខ្លាំងឡើង។

ជាទីបញ្ចប់នេះ យើងខ្ញុំទាំងពីរសូមបួងសួងដល់វត្ថុសក្តិសិទ្ធិទាំងឡាយលើលោក សូមតាមបីបាច់ថែរក្សា **លោកអ្នកមានគុណទាំងទ្វេ ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ព្រមទាំងលោក-លោកស្រីបណ្ឌិត លោក-លោកស្រីសាស្ត្រាចារ្យ និង លោក-លោកស្រីមន្ត្រីរាជការសាលា** ជាពិសេសលោកគ្រូ សាស្ត្រាចារ្យ **ញឹក ឧុឌ្ឋី** សូមមានសុខភាពល្អ ទទួលបានជោគជ័យគ្រប់ភារកិច្ចការងារ និងពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីសិក្សាអស់រយៈពេល៤ឆ្នាំកន្លងផុតទៅនៃការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ យើងខ្ញុំពិតជាមានក្ដីសោមនស្សរីករាយយ៉ាងក្រៃលែង ហើយបានចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើមុខវិជ្ជាដែលពាក់ព័ន្ធទៅនឹងនីតិឯកជនដែលប្រធានបទនេះហៅថា កិច្ចសន្យាបញ្ញើ ដោយសារតែមើលឃើញថាមានឯកសារដែលពាក់ព័ន្ធទៅនឹងប្រធានបទនេះមានតិចតួច ដើម្បីជំនួយបន្ថែមសម្រាប់និស្សិតផ្នែកនីតិសាស្ត្រ និងអ្នកស្រាវជ្រាវយកទៅប្រើប្រាស់ទើបបានជាយើងខ្ញុំទាំងពីររៀបចំសារណាពីប្រធានបទមួយនេះឡើង។

នៅក្នុងសារណានេះ យើងខ្ញុំបានរៀបចំសរសេរទាំងទ្រឹស្ដី និងនីតិវិធីជាក់ស្ដែង លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាបញ្ញើ លក្ខណៈនៃកិច្ចសន្យាបញ្ញើយកកម្រៃ និងមិនយកកម្រៃ (សិទ្ធិ ករណីយកិច្ចរបស់អ្នកផ្ញើនិងអ្នកទទួលបញ្ញើ និងការរួចផុតពីការទទួលខុសត្រូវនៃកិច្ចសន្យាបញ្ញើយកកម្រៃ និងមិនយកកម្រៃ) ដើម្បីជាភាពងាយស្រួលក្នុងការអនុវត្តទៅលើនីតិវិធី ក៏ដូចជាលក្ខខណ្ឌក្នុងកិច្ចសន្យានេះ។ យើងខ្ញុំសង្ឃឹម និងជឿជាក់យ៉ាងមុតមាំថាសារណាមួយនេះពិតជាអាចរួមចំណែកក្នុងការផ្ដល់នូវពុទ្ធិ ដល់បងប្អូនមិត្តអ្នកអាន សិស្សនិស្សិត និងអ្នកសិក្សាផ្នែកនីតិសាស្ត្រទាំងអស់ ហើយដើម្បីចែករំលែកបន្តទៅដល់អ្នកជំនាន់ក្រោយទទួលបានចំណេះដឹងរៀងៗខ្លួនតាមការគួរ ដើម្បីចូលរួមចែករំលែក ក្នុងការបណ្ដុះបណ្ដាលធនធានមនុស្សសម្រាប់ជាតិយើង ធ្វើឱ្យប្រទេសជាតិកាន់តែរីកចម្រើន។

ជាចុងក្រោយនេះ យើងខ្ញុំសូម ខន្តីអភ័យទោស នៅក្នុងការសរសេរ ទាំងអក្ខរវិរុទ្ធ ឬពាក្យពេចន៍ មិនសមរម្យត្រង់ណាក្នុងការសរសេរសារណានេះ ការសរសេរក៏គង់តែនឹងមានកំហុសខុសឆ្គងនានាដែលកើតឡើងដោយ អចេតនាផងដែរ។ យើងខ្ញុំរីករាយ និងទទួលការរិះគន់ទាំងឡាយ ដើម្បីស្ថាបនាឱ្យការស្រាវជ្រាវមួយនេះកាន់តែល្អប្រសើរឡើងមួយកម្រិតទៀតផងដែរ។

# មាតិកា


ទំព័រ

**សេចក្តីផ្តើម** ................................................ **១**

**ជំពូកទី១**

**សញ្ញាណទូទៅនៃកិច្ចសន្យាបញ្ញើ**

**ផ្នែកទី១. និយមន័យ** ................................................ **៤**

**កថាភាគទី១. អ្នកផ្ញើ** ................................................ **៤**

**កថាភាគទី២. អ្នកទទួល** ................................................ **៥**

**ផ្នែកទី២. កម្មវត្ថុនៃបញ្ញើ** ................................................ **៦**

**កថាភាគទី១. ចលនវត្ថុ** ................................................ **៧**

**១.និយមន័យទូទៅ** ................................................ **៧**

**២.ប្រភេទនៃចលនវត្ថុ** ................................................ **៧**

**កថាភាគទី២. កិច្ចសន្យាបញ្ញើជាប្រាក់** ................................................ **៧**

**១.កិច្ចសន្យាបញ្ញើជាប្រាក់នៅធនាគារ** ................................................ **៨**

**២.លក្ខណៈនៃកិច្ចសន្យាបញ្ញើជាប្រាក់** ................................................ **៨**

**៣.ប្រភេទនៃកិច្ចសន្យាបញ្ញើប្រាក់នៅធនាគារ** ................................................ **៨**

៣.១.បញ្ញើក្នុងគណនីមានកាលកំណត់ ................................................ **៩**

ក.សិទ្ធិ និងករណីយកិច្ចរបស់អ្នកផ្ញើ ................................................ **៩**

ខ.សិទ្ធិ និងករណីយកិច្ចរបស់អ្នកទទួលបញ្ញើ ................................................ **៩**

៣.២. បញ្ញើក្នុងគណនីមិនមានកាលកំណត់ ................................................ **៩**

ក.សិទ្ធិ និងករណីយកិច្ចរបស់អ្នកផ្ញើ ................................................ **១០**

ខ.សិទ្ធិ និងករណីយកិច្ចរបស់អ្នកទទួលបញ្ញើ ................................................ **១០**

៣.៣.បញ្ញើជាប្រាក់នៅក្នុងគណនីចរន្តធនាគារ ................................................ **១០**

**ជំពូកទី២**

**ការបង្កើតកិច្ចសន្យាបញ្ញើ**

**ផ្នែកទី១. សំណើ និងស្វីការ** ................................................ **១២**

**កថាភាគទី១. សំណើ** ................................................ **១២**

**១.លក្ខខណ្ឌសុពលភាពនៃសំណើ** ................................................ **១៣**

១.១.សំណើត្រូវតែមានលក្ខណៈច្បាស់លាស់ ........ ១៣
១.២.បញ្ជាក់ពីគោលបំណងនៃសំណើ ........ ១៣
១.៣.សំណើត្រូវបានដល់ភាគីទទួលសំណើ ........ ១៣
**២.អានុភាពនៃសំណើ** ........ **១៤**
២.១.សំណើមានកំណត់អំឡុងពេលសម្រាប់ស្វីការ និងការដកសំណើនោះ ........ ១៤
២.២.សំណើគ្មានកំណត់អំឡុងពេលសម្រាប់ស្វីការ និងការដកសំណើនោះ ........ ១៤
**កថាភាគទី២. ស្វីការ** ........ **១៤**
**ផ្នែកទី២. វិការៈក្នុងការបង្ហាញឆន្ទៈ** ........ **១៥**
**កថាភាគទី១. ការភាន់ច្រឡំ** ........ **១៥**
**កថាភាគទី២. ការឆបោក** ........ **១៦**
**កថាភាគទី៣. ព័ត៌មានមិនពិត** ........ **១៦**
**កថាភាគទី៤. ការរំលោភបំពានលើស្ថានភាព** ........ **១៧**
**កថាភាគទី៥. ការគំរាមកំហែង** ........ **១៧**
**កថាភាគទី៦. ការកេងយកចំណេញហួសហេតុ** ........ **១៧**
**កថាភាគទី៧. ឋបនីយផ្លូវចិត្ត** ........ **១៨**
**ផ្នែកទី២. សមត្ថភាពនៃភាគី** ........ **១៨**
**កថាភាគទី១. សមត្ថភាពទទួលបាននូវសិទ្ធិ** ........ **១៨**
**កថាភាគទី២. សមត្ថភាពខាងឆន្ទៈ** ........ **១៩**
**កថាភាគទី៣. សមត្ថភាពធ្វើសកម្មភាព** ........ **១៩**
**១.នីតិជន** ........ **១៩**
**២.អនីតិជនដែលទទួលបានអត្តាធីនភាព** ........ **២០**

**ជំពូកទី៣**

**ប្រភេទកិច្ចសន្យាបញ្ញើ**

**ផ្នែកទី១. កិច្ចសន្យាបញ្ញើដោយយកកម្រៃ** ........ **២២**
**កថាភាគទី១. លក្ខណៈនៃកិច្ចសន្យាបញ្ញើយកកម្រៃ** ........ **២៣**
**កថាភាគទី២. សិទ្ធិ និងករណីយកិច្ចរបស់អ្នកផ្ញើ** ........ **២៣**
**១.សិទ្ធិរបស់អ្នកផ្ញើ** ........ **២៣**

១.១.សិទ្ធិទាមទារឱ្យសងវត្ថុបញ្ញើ ............................................................................ ២៤
១.២.សិទ្ធិទាមទារសំណងនៃការខូចខាត ....................................................................... ២៤
១.៣.សិទ្ធិទទួលបានការជូនដំណឹងពីអ្នកទទួលបញ្ញើ ..................................................... ២៤
**២.ករណីយកិច្ចរបស់អ្នកផ្ញើ** ......................................................................................... **២៤**
២.១.ការបង់កម្រៃសេវាទៅឱ្យអ្នកទទួលបញ្ញើ ............................................................. ២៤
២.២.ការសងសំណងការខូចខាតទៅលើអ្នកទទួលបញ្ញើ ................................................. ២៥
២.៣.ការរាយការណ៍អំពីប្រភេទ និងតម្លៃនៃវត្ថុបញ្ញើ ...................................................... ២៥
**កថាភាគទី៣. សិទ្ធិនិងករណីយកិច្ចរបស់អ្នកទទួលបញ្ញើ** ........................................................ **២៥**
**១. សិទ្ធិរបស់អ្នកទទួលបញ្ញើ** ........................................................................................ **២៥**
១.១.សិទ្ធិទាមទារកម្រៃពីអ្នកផ្ញើក្នុងការរក្សាទុកវត្ថុបញ្ញើ ................................................. ២៥
១.២.សិទ្ធិសងវត្ថុបញ្ញើពីអ្នកទទួលបញ្ញើ ........................................................................ ២៦
១.៣.សិទ្ធិទាមទារសំណងនៃការខូចខាត ....................................................................... ២៦
១.៤.សិទ្ធិឃាត់ទុកវត្ថុបញ្ញើ ............................................................................................ ២៦
**២. ករណីយកិច្ចអ្នកទទួលបញ្ញើ** ....................................................................................... **២៦**
២.១.រក្សាទុកវត្ថុបញ្ញើ .................................................................................................... ២៦
២.២.ករណីយកិច្ចក្នុងការជូនដំណឹងរបស់អ្នកទទួលបញ្ញើ .................................................. ២៧
២.៣.សងសំណងខូចខាតទៅលើវត្ថុបញ្ញើ ......................................................................... ២៧
២.៤.សងវត្ថុបញ្ញើ ......................................................................................................... ២៧
**ផ្នែកទី២. កិច្ចសន្យាបញ្ញើមិនយកកម្រៃ** ............................................................................ **២៨**
**កថាភាគទី១. លក្ខណៈកិច្ចសន្យាបញ្ញើដោយមិនយកកម្រៃ** ..................................................... **២៩**
**កថាភាគទី២.សិទ្ធិនិងករណីយកិច្ចរបស់អ្នកផ្ញើ** ...................................................................... **២៩**
**១.សិទ្ធិរបស់អ្នកផ្ញើ** ........................................................................................................ **២៩**
១.១.សិទ្ធិទាមទារឱ្យសងវត្ថុបញ្ញើ ............................................................................... ៣០
១.២.សិទ្ធិដកហូតការព្រមព្រៀងចំពោះទំនាក់ទំនងបញ្ញើនាពេលអនាគត ............................. ៣០
១.៣.សិទ្ធិទាមទាមសំណង ............................................................................................ ៣០
**២. ករណីយកិច្ចរបស់អ្នកផ្ញើ** ............................................................................................ **៣០**

២.១.សោហ៊ុយនៃការរក្សាទុកវត្ថុបញ្ញើ ........ ៣០
២.២.ការសងសោហ៊ុយវិញ ........ ៣០
**កថាភាគទី៣. សិទ្ធិ និងករណីយកិច្ចរបស់អ្នកទទួលបញ្ញើ ........ ៣១**
**១.សិទ្ធិរបស់អ្នកទទួលបញ្ញើ ........ ៣១**
**២.ករណីយកិច្ចរបស់អ្នកទទួលបញ្ញើ ........ ៣១**
២.១.ថែរក្សាវត្ថុបញ្ញើ ........ ៣១
២.២.ករណីយកិច្ចក្នុងការជូនដំណឹងមុន ........ ៣១
២.៣.ករណីសងវត្ថុបញ្ញើ ........ ៣១
២.៤.រក្សាវត្ថុបញ្ញើដោយខ្លួនឯង ........ ៣១
២.៥.ការសងសំណងខូចខាត ........ ៣២
**ផ្នែកទី៣. ករណីសិក្សាអំពីបញ្ញើ ........ ៣២**
**កថាភាគទី១. ករណីសិក្សាទី១ ........ ៣២**
**កថាភាគទី២. ករណីសិក្សាទី២ ........ ៣៣**
**សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ........ ៣៥**
**ឯកសារយោង ........**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

បន្ទាប់ពីទទួលបានឯករាជ្យភាពឡើងវិញ ប្រទេសកម្ពុជាបានអនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី ដែលបុគ្គលឯកជនម្នាក់ៗចូលរួមអភិវឌ្ឍសេដ្ឋកិច្ចរៀងៗខ្លួនតាមរយៈការបញ្ញើវត្ថុ ការទិញលក់ ទំនិញ សេវា ដោយប្រើប្រាស់រូបិយវត្ថុជាចម្បង ឬត្រូវធ្វើឡើងតាមរយៈកិច្ចសន្យារវាងបុគ្គលម្នាក់ និងបុគ្គលម្នាក់ ដែលធ្វើឡើងទម្រង់ជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ ដោយសន្យាថានឹងគោរពសិទ្ធិ និងអនុវត្តករណីយកិច្ចរបស់ខ្លួន ដោយអនុលោមតាមគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន។ វិស័យគតិយុត្តនៅកម្ពុជា ត្រូវបានបំផ្លិចបំផ្លាញស្ទើរតែទាំងស្រុងដោយសារសង្គ្រាមស៊ីវិល ស្របពេលនោះច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា សម្រាប់អនុវត្តទៅលើរឿងក្តីរដ្ឋប្បវេណី ក៏មានភាពខ្វះខាត និងទន់ខ្សោយនៅឡើយ។ តែក្រោយពីការដួលរលំនូវរបបខ្មែរក្រហម យើងមិនមាននីតិវិធីច្បាប់គ្រប់គ្រាន់ដើម្បីយកមកដោះស្រាយនៅក្នុងរឿងក្តីរដ្ឋប្បវេណីទេ កម្ពុជាមានត្រឹមតែច្បាប់ស្តីពីការអនុវត្តសាលក្រមរដ្ឋប្បវេណីប៉ុណ្ណោះ។ ករណីវិវាទកើតមានឡើងច្រើន ពិបាកនឹងដោះស្រាយ ដោយមនុស្សម្នាក់ៗមានមូលហេតុ និងការចង់ត្រូវរៀងខ្លួន មិនថាជារឿងតូច ឬរឿងធំនោះទេ។ កង្វះនូវបទដ្ឋានគតិយុត្តនេះ ធ្វើឱ្យអ្នកអនុវត្តច្បាប់មិនមានអ្វីមួយជាគោលសម្រាប់ អនុវត្តទៅលើករណីទាំងនោះ ពោលអនុវត្តទៅតាមស្ថានភាពជាក់ស្តែងនីមួយៗ។

ការផ្ញើវត្ថុក៏អាចកើតឡើងនូវវិវាទបានដែរនៅពេលបច្ចុប្បន្ននេះ ដោយសារតែការបញ្ញើវត្ថុមានភាពសកម្ម និងអាចប្រកបជាអាជីវកម្មបានដែរនោះ។ ការបង្កឡើងដោយមានការផ្ញើ និងទទួលបញ្ញើ ក្នុងលក្ខខណ្ឌយកប្រាក់កម្រៃ និងមិនយកប្រាក់កម្រៃ ដែលជាមូលហេតុនាំឱ្យកើតមានវិវាទរវាងអ្នកផ្ញើ និងអ្នកទទួលបញ្ញើ មានការជជែកវែកញែកអំពីការទទួលខុសត្រូវទៅលើវត្ថុបញ្ញើ និងការសងសំណងនៃការខូចខាត ក្នុងករណីវត្ថុដែលជាកម្មវត្ថុនៃបញ្ញើបានខូចខាត ឬបាត់បង់។

តើបញ្ញើមានន័យដូចម្តេច? ហើយបញ្ញើនេះ បង្កជាវិវាទយ៉ាងដូចម្តេចខ្លះ និងមានប៉ុន្មានប្រភេទ? តើអ្នកណាជាអ្នកទទួលខុសត្រូវនូវសំណងនៃការខូចខាត ឬបាត់បង់នូវវត្ថុនេះ? តើភាគីនីមួយៗ ទទួលបាននូវផលប្រយោជន៍ ហើយមានសិទ្ធិ និងកាតព្វកិច្ចអ្វីខ្លះ?

គោលបំណងសំខាន់ក្នុងការស្រាវជ្រាវនូវប្រធានបទនេះ គឺដើម្បីយល់ដឹងកាន់តែច្បាស់នូវសិទ្ធិ និងកាតព្វកិច្ចរបស់អ្នកផ្ញើ និងអ្នកទទួលបញ្ញើ ដែលបច្ចុប្បន្នបានកើតឡើងនូវវិវាទជាច្រើនពាក់ព័ន្ធនឹងការខូចខាតនូវវត្ថុបញ្ញើ ក្នុងនោះដែរ ភាគតិចណាស់ដែលមនុស្សមួយចំនួនបានយល់ដឹងអំពីការខូចខាតដែលបង្កឡើង និងការបាត់បង់វត្ថុបញ្ញើ ហើយមិនដឹងអ្នកណាជាអ្នកទទួលខុសត្រូវ ឬអ្នកដែលត្រូវទទួលខុសត្រូវតែមិនព្រមទទួលខុសត្រូវ។ ដើម្បីសម្រួលដល់សកម្មភាពនៃទំនាក់ទំនងបញ្ញើនេះ ឱ្យប្រព្រឹត្តដោយរលូន កាត់បន្ថយនូវវិវាទ ច្បាប់កម្ពុជាបានកំណត់យ៉ាងច្បាស់អំពីប្រភេទនៃបញ្ញើ ដូចមានចែងក្នុងជំពូកទី១០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ប្រធានបទនេះ ទាក់ទង់ទៅនឹងនីតិឯកជន ដែលពាក់ព័ន្ធទៅនឹងកិច្ចសន្យាបញ្ញើ ដែលមានចែងក្នុងមាត្រា៦៦៩ ដល់មាត្រា៦៩១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ចូលជាធរមាន ទើបយើងខ្ញុំទាំងពីរសូមធ្វើការសិក្សា ស្រាវជ្រាវត្រឹមតែមាត្រាដែលបានកំណត់ខាងលើនេះ។

ក្នុងការសិក្សាលំអិតអំពីការបញ្ញើនៅព្រះរាជាណាចក្រកម្ពុជានេះ គឺពិតជាមានសារៈសំខាន់ណាស់ចំពោះសាធារណៈជនទូទៅ ដើម្បីធ្វើការវិភាគរកដំណោះស្រាយមួយជាក់លាក់ រួចធ្វើការផ្តល់ជាអនុសាសន៍ ដើម្បីជាផ្នែកមួយក្នុងការព្រីកចំណេះដឹងដែលទាក់ទងនឹងប្រធានបទមួយនេះទើបយើងខ្ញុំលើកប្រធានបទបញ្ញើនេះឡើង ឱ្យដឹងពីសារៈសំខាន់នៃកិច្ចសន្យាមួយនេះគឺ ជួយផ្តល់ជាអានុសាសន៍ពាក់ព័ន្ធនឹងបញ្ញើ ដើម្បីជាចំណេះដេងសម្រាប់សិស្សនិស្សិត មិត្តៗអ្នកអាន និងប្រជាជនដែលរស់នៅប្រទេសកម្ពុជា ព្រមទាំងចូលរួមចំណែកអភិវឌ្ឍន៍ប្រព័ន្ធច្បាប់នៅកម្ពុជាឱ្យកាន់តែមានភាពប្រសើរឡើងជាងមុន ហើយដើម្បីទុកជាឯកសារនៅក្នុងបណ្ណាល័យដល់សិស្សានុសិស្ស និស្សិតជំនាន់ក្រោយៗទៀត។

ក្នុងសារណានេះ យើងនឹងលើកយកមកធ្វើការសិក្សាទៅលើ បី ជំពូក:

ជំពូកទី១: សិក្សាអំពីសញ្ញាណទូទៅនៃកិច្ចសន្យាបញ្ញើ រួមមាននិយមន័យទូទៅ និងកម្មវត្ថុនៃកិច្ចសន្យាបញ្ញើ។

ជំពូកទី២: បកស្រាយអំពីការបង្កើតកិច្ចសន្យាបញ្ញើ។

ជំពូកទី៣: ដែលជាជំពូកចុងក្រោយវិញ យើងនឹងលើកឡើងនូវប្រភេទនៃកិច្ចសន្យាបញ្ញើ។

ជាបន្តទៅទៀតនេះ យើងខ្ញុំសូមធ្វើការបកស្រាយដូចតទៅ៖

# ជំពូកទី១

# សញ្ញាណទូទៅនៃកិច្ចសន្យាបញ្ញើ

# ជំពូកទី១

# សញ្ញាណទូទៅនៃកិច្ចសន្យាបញ្ញើ

បច្ចុប្បន្ននេះ កំណើនប្រជាពលរដ្ឋ សំណង់លំនៅដ្ឋាន និងអគារកើនឡើងជាលំដាប់ៗពីមួយឆ្នាំទៅមួយឆ្នាំ។ ស្ថានភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋកាន់តែមានភាពមមាញឹកឡើងពីមួយថ្ងៃទៅមួយថ្ងៃ។ កត្តានេះហើយធ្វើឱ្យទីកន្លែងរស់នៅរបស់ពលរដ្ឋក៏កាន់តែមានភាពចង្អៀតឡើងៗផងដែរ។ ជាពិសេស ប្រជាពលរដ្ឋរស់នៅក្នុងទីប្រជុំជនមានភាពលំបាកក្នុងការទុកដាក់ទ្រព្យសម្បត្តិរបស់ខ្លួន ដោយហេតុថាផ្ទះរបស់គាត់មានទំហំតូចពេក មិនអាចរក្សាទុកទ្រព្យសម្បត្តិមានទំហំធំៗបានដូចជារថយន្តជាអាទិ៍។ ដូច្នេះហើយ ប្រជាពលរដ្ឋចាំបាច់ត្រូវយកទ្រព្យសម្បត្តិរបស់ខ្លួនយកទៅផ្ញើនៅទីតាំងរបស់អ្នកដទៃ ដើម្បីរក្សាសុវត្ថិភាព ក៏ដូចជារក្សាគុណភាពនៃវត្ថុទាំងនោះផងដែរ។

បញ្ញើ គឺជាកិច្ចសន្យាផ្តល់សេវា ដូចជាកិច្ចសន្យាការងារ អាណត្តិ និងកិច្ចសន្យាម៉ៅការដែរ ប៉ុន្តែសេវាដែលអ្នកទទួលបញ្ញើត្រូវផ្តល់នោះគ្រាន់តែជាការរក្សាទុកវត្ថុតែប៉ុណ្ណោះ។ ប្រសិនបើ មានការបន្ថែមសេវាផ្សេងទៀត កិច្ចសន្យានោះនឹងក្លាយជាកិច្ចសន្យាម៉ៅការ។ ជាឧទាហរណ៍ទីមួយ កិច្ចសន្យាមួយដែលតាមរយៈនេះ អ្នកដំណើរប្រគល់អីវ៉ាន់ទៅក្រុមហ៊ុនដឹកជញ្ជូនតាមផ្លូវរថភ្លើង នៅឯស្ថានីយ៍ដែលអ្នកដំណើរត្រូវជិះ ហើយអ្នកដំណើរត្រូវទទួលអីវ៉ាន់នោះវិញ នៅស្ថានីយ៍ដែលខ្លួនទៅដល់ សេវាបែបនេះ មិនមែនគ្រាន់តែជាការរក្សាទុកនូវអីវ៉ាន់ប៉ុណ្ណោះទេ តែកាតព្វកិច្ចដឹកជញ្ជូនអីវ៉ាន់ឱ្យទៅដល់គោលដៅត្រូវបានបន្ថែម ដូច្នេះធាតុផ្សំនៃកិច្ចសន្យាម៉ៅការ ក៏ត្រូវបានបញ្ចូលផងដែរ។ ឧទាហរណ៍ទីពីរ កិច្ចសន្យាស្តុកទុកទំនិញនៅក្នុងឃ្លាំង អន្តរការីនៃការជួញដូរទំនិញកើតមានឡើងនៅក្នុងដំណើរការចែកចាយទំនិញ រវាងផលិតកម្ម និងការលក់ទៅឱ្យអ្នកប្រើប្រាស់ ដែលជាធម្មតាអ្នកលក់ដុំបន្ទាប់ពីបានទិញទំនិញពីអ្នកផលិតហើយ ពួកគេតែងតែរក្សាទុកទំនិញដែលបានទិញនោះ ហើយអាចតម្រូវឱ្យមានឧបករណ៍ពិសេសសម្រាប់រក្សាទុកផលិតផលទាំងនោះផងដែរ ដើម្បីឱ្យអ្នកកាន់កាប់ឃ្លាំងផ្ទុកផ្តាក់ទំនិញទាំងនោះ ក្នុងករណីនេះ អ្នកលក់ និងអ្នកកាន់ឃ្លាំង បានបង្កើតនូវកិច្ចសន្យាបញ្ញើ។ អ្នកកាន់កាប់ឃ្លាំងអាចចេញបង្កាន់ដៃដើម្បីបញ្ជាក់អំពីសិទ្ធិរបស់អ្នកផ្ញើ ប្រសិនបើអ្នកលក់ដុំបន្តទុកទំនិញដែលបានផ្ញើនោះ ទៅឱ្យអ្នកលក់ផ្សេងទៀត អ្នកលក់ត្រូវប្រគល់បង្កាន់ដៃទៅឱ្យអ្នកទិញបន្តនោះដោយរាប់បញ្ចូលការផ្ញើវត្ថុមានតម្លៃនៅសណ្ឋាគារ ឬអតិថិជនផ្ញើឥវ៉ាន់នៅភោជនីយដ្ឋាន ឬអ្នកដំណើរផ្ញើអីវ៉ាន់នៅស្ថានីយ៍ ជាអាទិ៍។ លើសពីនេះទៅទៀត ករណីបន្ទាប់នេះក៏ជាបញ្ញើដែរ គឺនៅពេលមានវិវាទអំពីកម្មសិទ្ធិលើវត្ថុណាមួយ តតិយជនធ្វើការ ថែរក្សានូវវត្ថុនោះ រហូតទាល់តែវិវាទត្រូវបានដោះស្រាយចប់។[1]

នៅក្នុងជំពូកនេះ យើងនឹងបានសិក្សាទៅលើនិយមន័យនៃកិច្ចសន្យាបញ្ញើ (ផ្នែកទី១) ហើយនៅផ្នែកទី២ នឹងបកស្រាយអំពីកម្មវត្ថុនៃបញ្ញើ ដែលមានជាចលនវត្ថុ និងបញ្ញើជាប្រាក់ផងដែរ។

[1] មាត្រា៦៦៩ សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ឆ្នាំ២០១០។

## ផ្នែកទី១. និយមន័យ

បញ្ញើសំដៅទៅលើកិច្ចសន្យា ដែលភាគីម្ខាងជាអ្នកទទួលបញ្ញើ សន្យាទទួលយកវត្ថុបញ្ញើ ពីភាគីម្ខាងទៀតជាអ្នកផ្ញើ មករក្សាទុកក្នុងអំឡុងពេលដែលបានកំណត់ ហើយនៅក្រោយពេលដែលអំឡុងពេលរក្សាទុកនោះត្រូវបានបញ្ចប់ ត្រូវសងវត្ថុដដែលនោះទៅឱ្យអ្នកផ្ញើវិញ។ បើគ្មានកិច្ចសន្យាពិសេសទេ អ្នកផ្ញើពុំមានករណីយកិច្ចបង់កម្រៃឱ្យអ្នកទទួលបញ្ញើឡើយ លើកលែងតែអ្នកទទួលបញ្ញើបានធ្វើកិច្ចសន្យានោះជាមួយអ្នកផ្ញើក្នុងនាមជាអាជីវកម្មរបស់ខ្លួន ឬប្រសិន បើមានកំណត់នៅក្នុងច្បាប់ ទោះបីជាមិនបានធ្វើកិច្ចសន្យាពិសេសចំពោះកម្រៃក៏ដោយ អ្នកទទួលបញ្ញើអាចទាមទារកម្រៃសមរម្យពីអ្នកផ្ញើបាន[2] ។

ដូច្នេះហើយ សូមលោក-លោកស្រីចាប់អារម្មណ៍ទៅលើនិយមន័យនៃពាក្យអ្នកផ្ញើ និងអ្នកទទួលបញ្ញើ ដែលជាឈ្មោះភាគីនៅក្នុងកិច្ចសន្យាបញ្ញើ។

### កថាភាគទី១. អ្នកផ្ញើ

អ្នកផ្ញើ ជាអ្នកយកវត្ថុមកផ្ញើជាមួយអ្នកទទួលបញ្ញើ។ ក្នុងសកម្មភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋភាគច្រើន គេយកចលនវត្ថុមកផ្ញើជាកម្មវត្ថុនៃកិច្ចសន្យាបញ្ញើ មានដូចជាយានយន្ត ប្រាក់កាស សម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួន គ្រឿងសង្ហារិម ទំនិញ គ្រឿងឧបភោគបរិភោគ និងសត្វជាដើម។ ប៉ុន្តែ សត្វ និងគ្រឿងឧបភោគបរិភោគ គេមិនសូវនិយមយកមកផ្ញើជាកម្មវត្ថុនៃបញ្ញើឡើយ ពីព្រោះសត្វមានជីវិត ដែលងាយនឹងមានជំងឺ និងអាចស្លាប់ ដែលនឹងបង្កជាហានិភ័យដល់អ្នកទទួលបញ្ញើ ហើយគ្រឿងឧបភោគបរិភោគ ទុកយូរអាចនឹងខូច ពោលមិនអាចទុករហូតដល់អំឡុងពេលកំណត់នៃការបញ្ចប់កិច្ចសន្យាបញ្ញើ។

ជាទូទៅ អ្នកផ្ញើមានគោលបំណងតែមួយគត់ គឺដើម្បីរក្សាទុកនូវទ្រព្យសម្បត្តិរបស់ខ្លួនឱ្យមានសុវត្ថិភាព។ ហេតុដែលនាំឱ្យមានការសម្រេចចិត្តផ្ញើ មានហេតុផលមួយចំនួនដូចជា ភាពចាំបាច់ ការប្រយ័ត្នប្រយែង ដែលអ្នកផ្ញើពុំអាចយកវត្ថុបញ្ញើនោះទៅតាមខ្លួនបាន។ អ្នកផ្ញើ និងអ្នកទទួលបញ្ញើមានផលប្រយោជន៍ និងមានសិទ្ធិផ្សេងៗគ្នា ដោយអ្នកផ្ញើទទួលបាននូវការថែរក្សារបស់ទ្រព្យ ហើយអ្នកទទួលបញ្ញើបាននូវប្រាក់កម្រៃ។

កិច្ចសន្យាបញ្ញើនៅក្នុងករណីបញ្ញើយកកម្រៃ អ្នកផ្ញើចាំបាច់ត្រូវបង់សោហ៊ុយជាចាំបាច់ទៅអ្នកទទួលបញ្ញើ ក្នុងការរក្សាទុកវត្ថុបញ្ញើ ហើយអ្នកទទួលបញ្ញើអាចទាមទារសំណងនៃការខូចខាត ដែលបណ្តាលមកពីវត្ថុបញ្ញើ ដោយមិនមែនជាកំហុសរបស់ខ្លួនពីអ្នកផ្ញើបាន។ មានន័យថា សោហ៊ុយសម្រាប់ការរក្សាទុកបញ្ញើ គឺជាបន្ទុករបស់អ្នកផ្ញើ និងប្រសិនបើអ្នកទទួលបញ្ញើទទួលការខូចខាតដោយសារវត្ថុបញ្ញើ ដែលមិនមែនជាកំហុសរបស់ខ្លួន អ្នកផ្ញើត្រូវសងសំណងនៃការខូចខាតនោះទៅឱ្យអ្នកទទួលបញ្ញើ។

[2] មាត្រា៦៦៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

### កថាភាគទី២. អ្នកទទួល

អ្នកទទួលបញ្ញើ គឺជាអ្នកដែលយល់ព្រមទទួលវត្ថុ ដែលជាកម្មវត្ថុនៃបញ្ញើយកមកថែរក្សា ដោយសន្យាប្រគល់វត្ថុបញ្ញើក្នុងអំឡុងពេលដែលបានកំណត់មួយ។ ការសងវត្ថុបញ្ញើ គឺផ្ញើវត្ថុអ្វីត្រូវសងវត្ថុនោះទៅអ្នកផ្ញើវិញ។ ប៉ុន្តែក្នុងករណី ដែលមានការបាត់ ឬខូចខាតវត្ថុបញ្ញើនោះ ត្រូវរកវត្ថុដែលមានរូបរាងដូច ឬសងជាប្រាក់ទៅអ្នកផ្ញើវិញឱ្យសមនឹងតម្លៃវត្ថុដែលខូចខាត។ អ្នកទទួលបញ្ញើត្រូវមានករណីយកិច្ចរក្សាទុកវត្ថុបញ្ញើ ដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ហើយប្រសិនបើគ្មានការយល់ព្រមពីអ្នកផ្ញើនោះទេ អ្នកទទួលបញ្ញើមិនអាចប្រើវត្ថុបញ្ញើឡើយ។ នៅក្នុងករណីដែលបានធ្វើបាត់បង់ ឬខូចខាតនូវវត្ថុបញ្ញើ អ្នកទទួលបញ្ញើត្រូវសងសំណងនៃការខូចខាតលើកលែងតែអ្នកទទួលបញ្ញើបញ្ជាក់អំពីការគ្មានកំហុស ហើយប្រសិនបើគ្មានការបញ្ជាក់ថា ជាករណីប្រធានសក្តិនោះទេ អ្នកទទួលបញ្ញើមិនអាចរួចផុតពីការទទួលខុសត្រូវចំពោះការបាត់បង់នោះឡើយ។ ចំពោះនៅទីកន្លែងផ្សេងៗទៀតដូចជា សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន ឬជួបជុំកន្លែងផ្សេងៗ ជាអាទិ៍ ប្រសិនបើកម្មសិទ្ធិករនៃទីតាំងទាំងនោះបានទទួលវត្ថុបញ្ញើពីភ្ញៀវ ប្រសិនបើគ្មានការបញ្ជាក់ថាជាករណីប្រធានសក្តិទេ អ្នកទទួលបញ្ញើទទួលខុសត្រូវចំពោះការបាត់បង់ ឬការខូចខាតទាំងនោះ។

ចំពោះកិច្ចសន្យាបញ្ញើដោយមិនគិតកម្រៃ តុលាការអាចបន្ថយការទទួលខុសត្រូវសងសំណងនៃការខូចខាតរបស់អ្នកផ្ញើ ដោយគិតពិចារណាទៅលើស្ថានភាពនៃទ្រព្យសម្បត្តិរបស់ភាគីទាំងសងខាង និងកាលៈទេសៈផ្សេងៗទៀត[3]។ ហើយនៅក្នុងករណី ដែលអ្នកផ្ញើបានផ្ញើប្រាក់ ឧបករណ៍អាចជួញដូរបាន និងវត្ថុ ដែលមានតម្លៃខ្ពស់ផ្សេងទៀត បើអ្នកផ្ញើមិនបានរាយការណ៍អំពីប្រភេទ និងតម្លៃនោះឱ្យទៅអ្នកទទួលបញ្ញើទេ តុលាការអាចបន្ថយការទទួលខុសត្រូវសំណងនៃការខូចខាតរបស់អ្នកទទួលបញ្ញើបាន[4]។ ប្រសិនបើវត្ថុបញ្ញើជាវត្ថុមានតម្លៃអ្នកទទួលបញ្ញើនឹងត្រូវរក្សាទុកដោយមានការប្រុងប្រយ័ត្នពិសេស ដើម្បីកុំឱ្យមានការខូចខាត។ ផ្ទុយទៅវិញ ប្រសិនបើអ្នកទទួលបញ្ញើមិនបានដឹងថា វត្ថុបញ្ញើនោះជាវត្ថុ ដែលមានតម្លៃនោះទេ អ្នកទទួលបញ្ញើនឹងមិនមានការប្រុងប្រយ័ត្នខ្ពស់ ដើម្បីរក្សាទុកនូវវត្ថុ ដែលមានតម្លៃទាមទារឱ្យមានការចំណាយច្រើន ហើយអ្នកទទួលបញ្ញើអាចទាមទារកម្រៃសម្រាប់ការរក្សាទុកនោះលើសធម្មតា។ ប៉ុន្តែប្រសិនបើ អ្នកទទួលបញ្ញើមិនបានដឹងថា វត្ថុបញ្ញើមានតម្លៃខ្ពស់ អ្នកទទួលបញ្ញើមិនអាចធ្វើដូច្នេះបានឡើយ ហេតុនេះអ្នកផ្ញើត្រូវរាយការណ៍អំពីវត្ថុ ដែលមានតម្លៃនោះទៅឱ្យអ្នកទទួលបញ្ញើ។ អ្នកទទួលបញ្ញើពុំអាចឱ្យតតិយជនរក្សាទុកវត្ថុបញ្ញើបានឡើយ បើគ្មានការអនុញ្ញាតពីអ្នកផ្ញើ ហើយនៅក្នុងករណីដែលអ្នកទទួលបញ្ញើឱ្យតតិយជនរក្សាទុកវត្ថុបញ្ញើ អ្នកទទួលបញ្ញើត្រូវទទួលខុសត្រូវចំពោះការជ្រើសតាំង និងការត្រួតពិនិត្យអ្នកទទួលបញ្ញើ ដែលត្រូវបានរក្សាទុកបន្ត។ មានន័យថា ទោះបីជាអ្នកទទួលបញ្ញើគ្រាន់តែប្រតិបត្តិរក្សាទុកនូវវត្ថុបញ្ញើក៏ដោយក៏អ្នកផ្ញើមានសិទ្ធិពិចារណាអំពីជំនាញ និងលក្ខខណ្ឌរបស់អ្នកទទួលបញ្ញើ នៅពេលសម្រេចផ្ញើវត្ថុនោះ ហេតុនេះ

[3] មាត្រា៦៧៥ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[4] មាត្រា៦៧៦ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

មិនត្រឹមត្រូវនោះទេនៅពេលដែលអ្នកទទួលបញ្ញើផ្ទុកផ្ដាក់ផ្ញើបន្តទៅឱ្យតតិយជនដោយសេរី លើកលែងតែបញ្ញើ ពាណិជ្ជកម្មជាញឹកញាប់ភាគីមានឆន្ទៈឱ្យមានបញ្ញើបន្ត ដោយត្រូវសរសេរលក្ខខណ្ឌនេះចូលទៅក្នុងកិច្ចសន្យាបញ្ញើ។ មួយវិញទៀត អ្នកទទួលបញ្ញើត្រូវទទួលខុសត្រូវចំពោះការជ្រើសតាំង និងត្រួតពិនិត្យអ្នកទទួលបញ្ញើបន្ត និងទោះបីជាកិច្ចសន្យាបញ្ញើអនុញ្ញាតឱ្យមានបញ្ញើបន្តក៏ដោយ អ្នកទទួលបញ្ញើត្រូវតែជ្រើសតាំងអ្នកទទួលបញ្ញើបន្ត ដែលអាចទុកចិត្តបាននិងទទួលមើលថែវត្ថុបញ្ញើបន្ត។ ការជ្រើសតាំងនូវអ្នកទទួលបញ្ញើបន្តមិនសមរម្យ ហើយវត្ថុបញ្ញើត្រូវបានខូចខាត ឬបាត់បង់ដោយសារកំហុសរបស់អ្នកទទួលបញ្ញើបន្ត អ្នកទទួលបញ្ញើជាអ្នកទទួលខុសត្រូវ ហើយទោះបីជាអ្នកទទួលបញ្ញើបានជ្រើសតាំងអ្នកទទួលបញ្ញើបន្ត ដែលត្រឹមត្រូវក៏ដោយ ក៏អ្នកទទួលបញ្ញើត្រូវតែទទួលខុសត្រូវចំពោះការត្រួតពិនិត្យមិនបានត្រឹមត្រូវផងដែរ។ ប្រសិនបើ តតិយជនបានអះអាងសិទ្ធិចំពោះវត្ថុបញ្ញើ បានដាក់ពាក្យបណ្ដឹងចំពោះអ្នកទទួលបញ្ញើ ឬវត្ថុបញ្ញើត្រូវបាន រឹបអូស អ្នកទទួលបញ្ញើត្រូវបានជូនដំណឹងអំពីហេតុនោះ ទៅឱ្យអ្នកផ្ញើដោយគ្មានការយឺតយ៉ាវ[5]។ កាលបើ អ្នកផ្ញើបានទទួលដំណឹងហើយតតិយជនបានអនុវត្តសិទ្ធិ អ្នកផ្ញើអាចប្រមូលភស្តុតាងដែលបញ្ជាក់ថា កម្មសិទ្ធិរបស់អ្នកផ្ញើមានសុពលភាព ហើយផ្ដល់ភស្តុតាងនោះទៅអ្នកទទួលបញ្ញើដើម្បីឱ្យអ្នកទទួលបញ្ញើធ្វើសកម្មភាពបណ្ដឹងជាអាទិ៍ ដើម្បីផលប្រយោជន៍របស់អ្នកទទួលបញ្ញើ។

ម្យ៉ាងវិញទៀត ទោះភាគីមិនបានកំណត់អំពីអំឡុងពេលសងវត្ថុក៏ដោយ អ្នកផ្ញើអាចទាមទារឱ្យសងវត្ថុនោះនៅពេលណាក៏បាន ពីព្រោះបញ្ញើត្រូវបានធ្វើឡើងដើម្បីការពារផលប្រយោជន៍របស់អ្នកផ្ញើ ហើយអ្នកទទួលបញ្ញើនឹងគ្មានផលប្រយោជន៍ផ្ទាល់ខ្លួនអ្វីក្នុងបន្តបញ្ញើនោះទេ លើកលែងតែកម្រៃ មានន័យថានៅពេលដែលអ្នកផ្ញើមកទទួលវត្ថុបញ្ញើរបស់ខ្លួនហើយនោះ អ្នកទទួលបញ្ញើត្រូវប្រគល់វត្ថុទៅឱ្យអ្នកផ្ញើវិញដោយមិនគិតពីការកំណត់អំឡុងពេល ព្រោះអ្នកវត្ថុជារបស់អ្នកផ្ញើ ហើយអ្នកទទួលគ្មានអ្វីត្រូវទុកវត្ថុរបស់គេទៀតទេឱ្យតែអ្នកផ្ញើបង់សោហ៊ុយទៅឱ្យអ្នកទទួលបញ្ញើ។ ក្នុងករណីដែលទទួលបានផលពីវត្ថុបញ្ញើ អ្នកទទួលបញ្ញើត្រូវប្រគល់ផលនោះទៅឱ្យអ្នកផ្ញើ ចំពោះកិច្ចសន្យាបញ្ញើមិនបានកំណត់អំពីកន្លែងសងវត្ថុបញ្ញើនោះ ចាំបាច់ត្រូវធ្វើនៅកន្លែងដែលត្រូវរក្សាទុកវត្ថុនោះ កាលណាមានមូលហេតុត្រឹមត្រូវការសងអាចធ្វើឡើងនៅកន្លែងរក្សាទុកជាក់ស្ដែងនាពេលសងបាន។

## ផ្នែកទី២. កម្មវត្ថុនៃបញ្ញើ

កម្មវត្ថុនៃកិច្ចសន្យា ត្រូវតែពិតប្រាកដ អាចធ្វើទៅកើត ត្រូវច្បាប់ និងប្រកបដោយសីលធម៌[6]។ កម្មវត្ថុជាធាតុសំខាន់ក្នុងការបង្កើតកិច្ចសន្យា ពោលបើគ្មានកម្មវត្ថុ ក៏កិច្ចសន្យាមិនអាចទៅរួចដែរ ព្រោះថាមិនដឹងជាកិច្ចសន្យាទៅលើអ្វីឱ្យប្រាកដនោះទេ។ ជាទូទៅក្នុងការផ្ញើវត្ថុ យើងសង្កេតឃើញមានបញ្ញើជាចលនវត្ថុ និងបញ្ញើជាសាច់ប្រាក់។

[5] មាត្រា៦៧៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[6] ញឹក វុទ្ធី "នីតិកាតព្វកិច្ច" (មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣), ភាគទី២, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, គ្មានកាលបរិច្ឆេទ, ទំព័រទី៥។

## កថាភាគទី១. ចលនវត្ថុ

អចលនវត្ថុសំដៅទៅលើ ដីធ្លី និងវត្ថុជាប់នៅលើដី ហើយមិនអាចផ្លាស់ប្តូរទីកន្លែងបានដូចជាអគារ សំណង់ ដំណាំ រុក្ខជាតិ ជាអាទិ៍។ រីឯ ចលនវត្ថុ សំដៅទៅលើវត្ថុក្រៅពីអចលនវត្ថុ។ ក្នុងន័យនេះ វត្ថុក្រៅពីដីធ្លី វត្ថុជាប់លើដីមិនអាចផ្លាស់ទីបាន គឺជាចលនវត្ថុ ដែលបានកំណត់ដោយច្បាប់។

### ១.និយមន័យទូទៅ

ចលនវត្ថុ សំដៅទៅលើវត្ថុដែលអាចរំកិល ឬផ្លាស់ទីតាំងបានដូចជារបស់របរផ្ទាល់ខ្លួន ឬទ្រព្យសម្បត្តិទាំងឡាយដែលអាចបម្លាស់ទីបាន[7]។ ចលនវត្ថុ គឺសំដៅលើវត្ថុ ឬទ្រព្យរបស់ដែលកម្រើកបាន ឬលើកដាក់ ឬដឹកនាំពីកន្លែងមួយទៅកន្លែងមួយទៀតបាន មានដូចជា តុ ទូ ជាដើម[8]។ អចលនវត្ថុ ក៏អាចក្លាយជាកម្មវត្ថុនៃបញ្ញើបានដែរ ប៉ុន្តែនៅពេលដែលអចលនវត្ថុត្រូវបានដាក់ផ្ញើ វាគ្រាន់តែត្រូវបានគេរក្សាទុកប៉ុណ្ណោះទេ គឺវាក៏ត្រូវបានគេគ្រប់គ្រងផងដែរ ឧទាហរណ៍ដូចជាការការប្រមូលថ្លៃឈ្នួលនៃភតិសន្យាអចនលវត្ថុជាអាទិ៍ ជាទូទៅត្រូវបានគេបកស្រាយថាជាអាណត្តិច្រើនជាងជាបញ្ញើ យ៉ាងណាក៏នៅតែអាចមានបញ្ញើអចលនវត្ថុ ប្រសិនបើអចលនវត្ថុគ្រាន់តែត្រូវបានរក្សាទុកដោយមិនគ្រប់គ្រង[9]។

### ២.ប្រភេទនៃចលនវត្ថុ

ចលនវត្ថុ មានលក្ខណៈងាយស្រួលមើល និងបែងចែក។ ចលនវត្ថុមានដូចជា តុ ទូ កៅអី សៀវភៅ ម៉ូតូ ឡាន កង្ហារ ជាដើម។ ចាត់ទុកថា ជាចលនវត្ថុ តែចំពោះវត្ថុដែលផ្លាស់ទីបានប៉ុណ្ណោះ មានន័យថា កង្ហារជាចលនវត្ថុក៏ដោយ ប៉ុន្តែនៅពេលដែលកង្ហារស្ទានជាប់នឹងជញ្ជាំងផ្ទះហើយ នោះវានឹងក្លាយទៅអចលនវត្ថុ ដែលជាសមាសភាគនៃផ្ទះ។ ចំពោះកប៉ាល់វិញ ជាវត្ថុមានចលនាផ្លាស់ទីបាន ប៉ុន្តែកប៉ាល់ដែលមានចំណុះតិចជាង៣០តោន ច្បាប់ចាត់ទុកជាចលនវត្ថុ ផ្ទុយទៅវិញ ចំពោះកប៉ាល់ ដែលមានចំណុះ៣០តោនឡើង ច្បាប់កំណត់ថាកប៉ាល់នោះក្លាយជាអចលនវត្ថុវិញ។ ប្រសិនបើ ប្រាក់ត្រូវបានរក្សាទុក តាមទម្រង់ជាការដាក់ក្នុងស្រោមសំបុត្រនេះត្រូវបានគេចាត់ទុកដូចគ្នានឹងវត្ថុ ប៉ុន្តែបើប្រាក់មិនត្រូវបានដាក់ក្នុងស្រោមសំបុត្រទេ កិច្ចសន្យានេះមិនមែនបញ្ញើធម្មតាទេ តែជាបញ្ញើបរិភោគ[10]។

## កថាភាគទី២. កិច្ចសន្យាបញ្ញើជាប្រាក់

ភាគច្រើន កិច្ចសន្យាបញ្ញើជាប្រាក់គេច្រើនតែឃើញធ្វើឡើងនៅស្ថាប័នធនាគារ ជាជាងយកប្រាក់ទាំងនោះទៅផ្ញើនៅអ្នកជិតខាង ឬអ្នករាប់អានគ្នា ដោយហេតុថា ការយកប្រាក់ទៅផ្ញើនៅធនាគារមានសុវត្ថិភាព និងទទួលបានអត្រាការប្រាក់ពីបញ្ញើនោះផងដែរ។

[7] យល់ដឹងផ្នែកច្បាប់៖ អំពីវត្ថុដែលមានកំណត់ក្នុងក្រមរដ្ឋប្បវេណី (ciclg.com) (ចូលទស្សនាថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២២)

[8] វចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត ឆ្នាំ១៩៦៨ ។

[9] មាត្រា៦៦៩ សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ឆ្នាំ២០១០។

[10] មាត្រា៦៦៩ សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ឆ្នាំ២០១០។

**១.កិច្ចសន្យាបញ្ញើជាប្រាក់នៅធនាគារ**

កិច្ចសន្យាបញ្ញើជាប្រាក់នៅធនាគារ ជាកិច្ចសន្យាដែលម្ចាស់កម្មសិទ្ធិលើប្រាក់បញ្ញើបានដាក់ផ្ញើសាច់ប្រាក់តាមគ្រប់ប្រភពដែលជាចំណូលរបស់ខ្លួននៅគ្រឹះស្ថានធនាគារ ឬមីក្រូហិរញ្ញវត្ថុផ្សេងៗ។ លើសពីនេះការដាក់ប្រាក់បញ្ញើ គឺដើម្បីបំពេញនូវទំនុកចិត្តស្របច្បាប់ដល់ម្ចាស់ប្រាក់បញ្ញើ និងដើម្បីសុវត្ថិភាពផ្នែកហិរញ្ញវត្ថុរបស់ខ្លួន ពីព្រោះមានតែគ្រឹះស្ថានធនាគារ ជាពិសេសធនាគារពាណិជ្ជ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើប៉ុណ្ណោះដែលអាចធ្វើប្រតិបត្តិការទទួលប្រាក់បញ្ញើពីសាធារណជនបានស្របតាមច្បាប់ស្តីពីធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ នៃព្រះរាជាណាចក្រកម្ពុជា។

ទន្ទឹមនឹងនោះ ការស្នើបើកគណនីនៅតាមធនាគារ ឬមីក្រូហិរញ្ញវត្ថុ ច្បាប់តម្រូវឱ្យអ្នកស្នើសុំ ត្រូវបំពេញលក្ខខណ្ឌមួយចំនួន ដែលក្នុងនោះលក្ខខណ្ឌសមត្ថភាពត្រូវតម្រូវចំពោះម្ចាស់ស្នើសុំបើកគណនីផងដែរ។ ជាគោលការណ៍ច្បាប់ អ្នកស្នើសុំបើកគណនីត្រូវតែជាជនដែលមាននីតិភាព ឬជានីតិបុគ្គល។

**២.លក្ខណៈនៃកិច្ចសន្យាបញ្ញើជាប្រាក់**

កិច្ចសន្យាបញ្ញើ ជាប្រាក់មានលក្ខណៈជាកិច្ចសន្យាបញ្ញើបរិភោគ មានន័យថានៅពេលអ្នកបានផ្ញើប្រាក់នៅក្នុងធនាគារមួយ ធនាគារនោះអាចយកប្រាក់នោះទៅប្រើប្រាស់បន្តបាន ដោយរក្សាចំនួនទឹកប្រាក់របស់អ្នកនៅដដែលរហូតដល់ពេលកំណត់អ្នកអាចដកប្រាក់បានដូចធម្មតា។ នៅក្នុងកិច្ចសន្យាបញ្ញើ បើបានព្រមព្រៀងឱ្យអ្នកទទួលបញ្ញើអាចបរិភោគក្នុងបញ្ញើបាន អ្នកទទួលបញ្ញើមានករណីយកិច្ចសងវត្ថុដែលមានប្រភេទ និងចំនួនដូចគ្នាដូចវត្ថុបញ្ញើនោះ[11]។

**ឧទាហរណ៍៖** អ្នកផ្ញើប្រាក់ X បានឱ្យធនាគារ Y រក្សាទុកវត្ថុបញ្ញើ (ប្រាក់)។ ធនាគារ Y បានប្រើប្រាស់ប្រាក់នោះព្រោះវត្ថុបញ្ញើគឺជាប្រាក់។ ដោយសារតែបែបនេះហើយ កិច្ចសន្យាផ្ញើប្រាក់មានចំណុចសង្កត់ធ្ងន់មួយត្រង់ថា វាធ្វើឡើងដើម្បីផលប្រយោជន៍របស់អ្នកផ្ញើប្រាក់ ហេតុនេះមានមតិភាគច្រើនយល់ថា កិច្ចសន្យាផ្ញើប្រាក់ គឺជាកិច្ចសន្យាបញ្ញើបរិភោគ។ ប៉ុន្តែជាក់ស្តែង ភាគច្រើនក្នុងអំឡុងពេលធ្វើកិច្ចសន្យារវាង អ្នកផ្ញើប្រាក់ X និងធនាគារ Y គឺធ្វើឡើងដោយកិច្ចសន្យាប្រតិបត្តិការដោយមានកិច្ចធានាធម្មតា ហេតុនេះបញ្ហាដែលកើតឡើងរវាងអ្នកផ្ញើប្រាក់ និងធនាគារនឹងត្រូវបានដោះស្រាយផ្អែកតាមការកំណត់ ដែលមានក្នុងកិច្ចសន្យាប្រតិបត្តិការដោយ មានកិច្ចធានាធម្មតានោះ[12]។

**៣.ប្រភេទនៃកិច្ចសន្យាបញ្ញើប្រាក់នៅធនាគារ**

បញ្ញើប្រាក់នៅធនាគារមានប្រភេទផ្សេងៗគ្នា ហើយការបែងចែកប្រភេទផ្សេងៗគ្នានេះ ដោយសារទម្រង់នៃបញ្ញើ និងអត្ថប្រយោជន៍នៃប្រភេទនីមួយៗមានភាពខុសគ្នា។

[11] មាត្រា៦៩០ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[12] កម្រងមេរៀន២០១៦ ដោយវិភាគទានច្បាប់(បទបង្ហាញស្តីពី កិច្ចសន្យាបញ្ញើ ឧទ្ទេសនាមដោយមេធាវី មាស សារិន)

### ៣.១.បញ្ញើក្នុងគណនីមានកាលកំណត់

បញ្ញើបែបនេះវាមានលក្ខណៈដូចបញ្ញើបែបគណនីសំចៃដែរ គ្រាន់តែខុសគ្នាត្រង់អ្នកផ្ញើទទួលការប្រាក់ខ្ពស់ជាង និងមានកំណត់អំឡុងពេលនៃការដកប្រាក់ ដែលវាជាធាតុផ្សំនៃបញ្ញើបរិភោគផង និងជាការខ្ចីបរិភោគផង។ ផ្ទុយទៅវិញ ប្រសិនបើអ្នកផ្ញើចង់ដកប្រាក់វិញមុនកាលកំណត់ នោះអ្នកផ្ញើមិនអាចទទួលបានការប្រាក់តាមការសន្យាពិសេសនេះទេ គាត់អាចទទួលបានការប្រាក់ជាលក្ខណៈបែបគណនីបញ្ញើសំចៃជំនួសវិញ គឺគាត់អាចដក់ប្រាក់ពេលណាក៏បាន។ ការដាក់ប្រាក់បញ្ញើមានកាលកំណត់ ចែកជា បី គឺ បញ្ញើមានកំណត់កំណើនខ្ពស់ បញ្ញើមានកាលកំណត់ចំណូលខ្ពស់ និងបញ្ញើមានកាលកំណត់រយៈពេលវែង។ បញ្ញើមានកាលកំណត់កំណើនខ្ពស់ គឺជាប្រភេទប្រាក់បញ្ញើដែលអាចដកប្រាក់ដើម និងការប្រាក់ នៅពេលបញ្ចប់កិច្ចសន្យា។ បញ្ញើមានកាលកំណត់ចំណូលខ្ពស់ ជាប្រភេទប្រាក់បញ្ញើដែលអាចដកការប្រាក់បានជារៀលរាល់ខែ និងប្រាក់ដើមអាចដកបាននៅពេលបញ្ចប់កិច្ចសន្យា។ មានន័យថា អាចដកបានតែការប្រាក់ប៉ុណ្ណោះ ប្រាក់ដើមត្រូវដកនៅពេលបញ្ចប់កិច្ចសន្យា។ បញ្ញើមានកាលកំណត់រយៈពេលវែង គឺជាប្រភេទប្រាក់បញ្ញើដែលអាចដកប្រាក់បានជារៀងរាល់បីខែម្តង និងប្រាក់ដើមអាចដកបាននៅពេលបញ្ចប់កិច្ចសន្យា[13]។

#### ក.សិទ្ធិ និងករណីយកិច្ចរបស់អ្នកផ្ញើ

ក្នុងការដាក់ប្រាក់បញ្ញើ លក្ខណៈបញ្ញើមានកាលកំណត់នេះ អ្នកផ្ញើមានសិទ្ធិដកប្រាក់បាន និងមានសិទ្ធិទទួលបានអត្រាការប្រាក់ ប៉ុន្តែដកតាមកាលកំណត់របស់ធនាគារនីមួយៗប៉ុណ្ណោះ ទើបទទួលបានអាត្រាការប្រាក់ខ្ពស់។ ឧទាហរណ៍ជាក់ស្តែង ក្នុងការដាក់ប្រាក់បែបបញ្ញើមានកាលកំណត់ របស់ធនាគារអេស៊ីលីដា ភីអិលស៊ី អ្នកផ្ញើមានសិទ្ធិដកប្រាក់បានតែតាមរយៈគោលការណ៍ដែលជាប្រាក់បញ្ញើមានកាលកំណត់ប៉ុណ្ណោះ មានន័យថាបើសិនអ្នកផ្ញើបានផ្ញើជាមួយធនាគារកំណត់រយៈពេល ១២ខែ នោះអ្នកផ្ញើនឹងទទួលបានអត្រាប្រាក់ ៤.៨០% ក្នុងមួយឆ្នាំ ដែលធៀបនឹងការដាក់ប្រាក់បែបបញ្ញើសំចៃអាចដកពេលណាក៏បានប៉ុន្តែ ទទួលបានអត្រាការប្រាក់តែ ០.៧៥% ប៉ុណ្ណោះក្នុងមួយឆ្នាំ។

#### ខ.សិទ្ធិ និងករណីយកិច្ចរបស់អ្នកទទួលបញ្ញើ

ក្នុងការដាក់ប្រាក់បែបបញ្ញើមានកាលកំណត់នេះ អ្នកទទួលបញ្ញើ(ធនាគារ) មានសិទ្ធិចែកចាយប្រាក់បន្ត និងមានសិទ្ធិរក្សាទុកនូវប្រាក់បញ្ញើផងដែរ។ មួយវិញទៀត អ្នកទទួលបញ្ញើ មានករណីកិច្ចផ្តល់នូវការប្រាក់ជូនដល់អ្នកផ្ញើដូចទៅនឹងកិច្ចសន្យា[14]។

### ៣.២. បញ្ញើក្នុងគណនីមិនមានកាលកំណត់

បញ្ញើក្នុងគណនីមិនមានកាលកំណត់ ជាគណនីបែបបញ្ញើសំចៃ នៅពេលដែលអ្នកផ្ញើបានដាក់ប្រាក់សន្សំនោះនឹងទទួលបានអាត្រាការប្រាក់ ប៉ុន្តែបានតែតិចតួចប៉ុណ្ណោះ។ នៅក្នុងប្រតិបត្តិការធនាគារ បញ្ញើជាប្រាក់មានប្រភេទ

[13] https://www.acledabank.com.kh/kh/khm/ps_defixeddeposit

[14] https://jtrustroyal.com/kh/personal/everyday-banking/term-deposit-account/

បញ្ញើដែលមានលក្ខណៈសន្សំសំចៃនេះ អ្នកផ្ញើអាចទទួល បានការប្រាក់ក្នុងកម្រិតតិចតួច ហើយធនាគារជាអ្នកទទួលបញ្ញើអាចយកប្រាក់នេះទៅចាត់ចែងបន្តក្នុងរយៈពេលខ្លីមិនកំណត់ ហើយត្រូវប្រគល់សងទៅឱ្យអ្នកផ្ញើវិញនៅពេលមានការទាមទារឱ្យបើកប្រាក់ផ្ញើនោះសងវិញ។ ក្នុងស្ថានភាពបែបនេះ យើងអាចកំណត់បានថា បញ្ញើពិសេសបែបនេះជាបញ្ញើបរិភោគ ដោយហេតុថាប្រាក់ដែលត្រូវប្រគល់សងវិញ មិនមែនជាក្រដាសប្រាក់ដែលបានផ្ញើតាំងពីដំបូងនោះទេ អ្នកផ្ញើបានទទួលផលប្រយោជន៍ពីការផ្ញើប្រាក់នៅធនាគារ។ ចំពោះធនាគារក៏ទទួលបានផលប្រយោជន៍ជាការប្រាក់ ដោយធនាគារបានយកប្រាក់បញ្ញើនេះទៅចាត់ចែងបន្តដូចជាឱ្យ អតិថិជនខ្ចីបន្ត ហើយទទួលបានការប្រាក់មកវិញ[15]។ គ្រប់បុគ្គលទាំងអស់រួមទាំងរូបវន្តបុគ្គល និងនីតិបុគ្គល មានសិទ្ធិបង្កើតគណនីបញ្ញើសន្សំ ឬគណនីធនាគារស្របតាមតម្រូវការរបស់ខ្លួននៅតាមគ្រឹះស្ថានធនាគារ ឬមីក្រូហិរញ្ញវត្ថុដែលបានអាជ្ញាប័ណ្ណត្រឹមត្រូវពីអាជ្ញាធរមានសមត្ថកិច្ចដើម្បីរក្សាទុកប្រាក់បញ្ញើ ឬរក្សាទុកប្រាក់សន្សំដោយអាចទទួលបានការប្រាក់ ឬអត្ថប្រយោជន៍ផ្សេងទៀតស្របតាមការព្រមព្រៀង និងគោលនយោបាយរបស់គ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុនោះ[16]។

### ក.សិទ្ធិ និងករណីយកិច្ចរបស់អ្នកផ្ញើ

ក្នុងការដាក់ប្រាក់បញ្ញើសន្សំនៅធនាគារ អ្នកផ្ញើមានសិទ្ធិដកប្រាក់ពេលណាក៏បាន ហើយអាចមានសិទ្ធិដាក់ប្រាក់ប៉ុន្មានក៏បានដែរ ប៉ុន្តែមិនទទួលបានការប្រាក់ខ្ពស់នោះទេ មិនមែនមានន័យថាទទួលបានការប្រាក់ទាបរហូតទេ គឺដាក់ប្រាក់កាន់តែច្រើនទទួលបានការប្រាក់កាន់តែច្រើន គ្រាន់តែមានការប្រាក់តិចជាងបញ្ញើមានកាលកំណត់។ ឧទាហរណ៍ជាក់ស្តែង នៅក្នុងធនាគារអេស៊ីលីដា ភីអិលស៊ី ការដាក់ប្រាក់បែបបញ្ញើសំចៃ ទទួលបានអាត្រាការប្រាក់ ០.៧៥% ក្នុងមួយឆ្នាំ ហើយអាចដកប្រាក់បានគ្រប់ពេលវេលា ប៉ុន្តែត្រូវស្របតាមគោលការណ៍របស់ធនាគារ។ គោលការណ៍របស់ធនាគារអេស៊ីលីដា ភីអិលស៊ី ប្រសិនបើបិទគណនីក្រោយពីថ្ងៃបើកគណនីរយៈពេល៣ខែ សម្រាប់បញ្ញើជារូបិយបណ្ណក្រៅពីប្រាក់រៀល ដុល្លារអាមេរិក និងបាត គឺមិនទទួលបានអាត្រាការប្រាក់ទេ[17]។

### ខ.សិទ្ធិ និងករណីយកិច្ចរបស់អ្នកទទួលបញ្ញើ

នៅពេលដែលអ្នកផ្ញើបានដាក់ប្រាក់បញ្ញើនៅធនាគារ អ្នកទទួលបញ្ញើ(ធនាគារ) មានសិទ្ធិដកប្រាក់នោះទៅបង្វិលពេលណាក៏បាន មានន័យថាអាចយកប្រាក់នោះទៅដាក់ជាប្រាក់ដើម្បីឱ្យអតិថិជនកម្ចីបន្តបាន ប៉ុន្តែត្រូវមានករណីយកិច្ចប្រគល់ប្រាក់ត្រឡប់ទៅអ្នកផ្ញើវិញនៅពេល អ្នកផ្ញើមកដកប្រាក់គ្រប់ពេល។

### ៣.៣.បញ្ញើជាប្រាក់នៅក្នុងគណនីចរន្តធនាគារ

បញ្ញើជាប្រាក់នៅក្នុងគណនីចរន្តធនាគារ គឺជាបញ្ញើបរិភោគ ដោយធនាគារជាអ្នករក្សាទុកប្រាក់បញ្ញើនេះដើម្បីទុកលទ្ធភាពឱ្យអ្នកផ្ញើ ចាត់ចែងប្រាក់បញ្ញើសម្រាប់ប្រតិបត្តិការទូទាត់ក្នុងការជួញដូរ។ ធនាគារក៏អាចយកប្រាក់នេះ

---

[15] បទបង្ហាញស្តីពី កិច្ចសន្យាបញ្ញើ ឧទ្ទេសនាមដោយមេធាវី មាស សារិន, ឆ្នាំ២០១៦។

[16] https://www.lareine.com.kh/news/eco-bussiness/24853/

[17] https://www.acledabank.com.kh/kh/khm/ps_desavingacc?t=p

ទៅ ចាត់ចែងក្នុងចំនួនកំណត់ណាមួយ ហើយអ្នកផ្ញើភាគច្រើនមិនទទួលបានការប្រាក់ទេ[18]។ គណនីចរន្តភាគច្រើន ប្រើប្រាស់សម្រាប់អ្នកអាជីវករ ឬក្រុមហ៊ុន ដែលធ្វើការទូទាត់រាល់ការចំណាយ ការដកប្រាក់ ឬការដាក់ប្រាក់ដែល ធនាគារតម្រូវឱ្យម្ចាស់គណនីអាចធ្វើប្រតិបត្តិការបានតាមតម្រូវការ និងគ្រប់ពេលវេលាក្នុងម៉ោងធ្វើការដោយមិន ទទួលបាននូវអាត្រាការប្រាក់ឡើយ។ បញ្ញើជាប្រាក់ក្នុងគណនីចរន្តធនាគារ មានពីរ ប្រភេទ គឺ គណនីចរន្តធម្មតា និង គណនីចរន្តផ្ញើស។ គណនីចរន្តធម្មតា គឺមិនទទួលបានការប្រាក់នោះទេ ហើយតម្រូវឱ្យអ្នកផ្ញើតម្កល់សាច់ប្រាក់ក្នុង ការបើកគណនីដំបូងចំនួន ១០០ ដុល្លារ។ ចំពោះ គណនីចរន្តផ្ញើស គឺអ្នកផ្ញើទទួលបានអត្រាការប្រាក់ 0.៥0% ក្នុង មួយឆ្នាំ ហើយត្រូវតម្កល់សាច់ប្រាក់ក្នុងការបើកគណនីដំបូងចំនួន ៥00 ដុល្លារ។

ជាទូទៅ គណនីចរន្តធនាគារ គឺអ្នកផ្ញើអាចធ្វើជាសៀវភៅសែក ដែលហៅម្យ៉ាងទៀតថាឧបករណ៍ដែលអាច ជួញដូរបាន។ ក្នុងនោះដែរ អ្នកផ្ញើមានសិទ្ធិដកប្រាក់ដោយប្រើសែក ហើយឱ្យគេទៅបើកជំនួសក៏បាន ប៉ុន្តែត្រូវមានការ អនុញ្ញាតពីម្ចាស់សែកនោះជាមុនសិន។ ចំពោះ គណនីដែលប្រើប្រាស់ក្នុងនាមក្រុមហ៊ុន ក្នុងការផ្ទេរសមតុល្យសាច់ ប្រាក់ក្នុងគណនី ម្ចាស់គណនីមានសិទ្ធិផ្ទេរដោយគ្រាន់តែទំនាក់ទំនងតាមប្រព័ន្ធទូរសព្ទក៏បាន ឬអាចទៅផ្ទេរនៅ តាមធនាគារក៏បាន។ ការផ្ទេរនៅក្នុងធនាគារ ឬទំនាក់ទំនងតាមទូរសព្ទ ត្រូវតែជាម្ចាស់ប៉ុណ្ណោះទើបអាចផ្ទេរបាន ប៉ុន្តែមានករណីលើកលែងប្រសិនជាចង់ឱ្យអ្នកផ្សេងទៅផ្ទេរជំនួស គឺម្ចាស់គណនីត្រូវផ្តល់សិទ្ធិដល់អ្នកជំនួយដោយ ត្រូវបំពេញទម្រង់តាមគោលការណ៍របស់ធនាគារ។

ជាកិច្ចបន្ទាប់ លោក-លោកស្រីនឹងបានសិក្សាអំពីការបង្កើតកិច្ចសន្យាបញ្ញើ នៅក្នុងជំពូកទី២ វិញម្តង។

[18] កិច្ចពិភាក្សាស្តីពី កិច្ចសន្យាជួលចំណត នៅថ្ងៃទី ២៥ កញ្ញា ឆ្នាំ២០១៦ នៅCJCC។

# ជំពូកទី២

# ការបង្កើតកិច្ចសន្យាបញ្ញើ

# ជំពូកទី២
# ការបង្កើតកិច្ចសន្យាបញ្ញើ

កិច្ចសន្យា មានអានុភាពនៅពេលដែលមានសំណើ និងស្វីការត្រូវគ្នា [19] ប៉ុន្តែនៅក្នុងករណីដែលបង្ហាញឆន្ទៈមានវិការៈ ឬខ្លឹមសារនៃសកម្មភាពផ្ទុយនឹងច្បាប់ នោះអានុភាពនឹងត្រូវបានបដិសេធដោយក្រមរដ្ឋប្បវេណី។ សំណើត្រូវតែជាសំណើ ដែលច្បាស់លាស់ និងពិតប្រាកដ។ រីឯស្វីការវិញ ត្រូវកើតចេញពីឆន្ទៈពិតប្រាកដ មិនមានវិការៈក្នុងការបង្ហាញឆន្ទៈដូចជា ការភ័ន្តច្រឡំ ការឆបោក ការគំរាមកំហែង ជាអាទិ៍។

កិច្ចសន្យាបញ្ញើត្រូវបានបង្កើតឡើងដោយការប្រគល់វត្ថុ និងកិច្ចសន្យាឯកតោភាគី។ ក្នុងកិច្ចសន្យាបញ្ញើ នៅពេលដែលអ្នកទទួលបញ្ញើបានទទួលវត្ថុ ករណីយកិច្ចរបស់អ្នកទទួលបញ្ញើនោះនឹងកើតឡើង មានន័យថាជាគោលការណ៍ កិច្ចសន្យាបញ្ញើត្រូវបានបង្កើតឡើងដោយចាំបាច់មានការប្រគល់វត្ថុ។ ប៉ុន្តែ កិច្ចសន្យាបញ្ញើដែលត្រូវបានបង្កើតឡើងដោយការព្រមព្រៀង ក៏ត្រូវបានអនុញ្ញាតឱ្យធ្វើដែរ។ ការផ្ញើដោយមិនយកកម្រៃ គឺជាកិច្ចសន្យាឯកតោភាគី ពីព្រោះអ្នកទទួលបញ្ញើទទួលបន្ទុកនូវករណីយកិច្ចរក្សាទុក និងប្រគល់វិញនូវវត្ថុផ្ញើ រីឯអ្នកផ្ញើមិនមានករណីយកិច្ចអ្វីទាំងអស់[20]។

ក្នុងជំពូកទី២នេះ លោក-លោកស្រីនឹងបានសិក្សាអំពីការបង្កើតកិច្ចសន្យាបញ្ញើ ដែលរួមមានសំណើ និងស្វីការ (ផ្នែកទី១) វិការៈនៃការបង្ហាញឆន្ទៈ (ផ្នែកទី២) និងសមត្ថភាពនៃភាគី (ផ្នែកទី៣)។

## ផ្នែកទី១. សំណើ និងស្វីការ

សំណើ និងស្វីការ ជាធាតុពីរបំពេញឱ្យគ្នាទៅវិញទៅមក ដើម្បីឱ្យកិច្ចសន្យាមួយមានអានុភាព មានន័យថាបើមានតែសំណើ ប៉ុន្តែសំណើនោះមិនត្រូវគ្នានឹងស្វីការ ក៏កិច្ចសន្យាគ្មានអានុភាពតាមផ្លូវច្បាប់នោះឡើយ។

ខាងក្រោមនេះ យើងនឹងបកស្រាយពាក់ព័ន្ធសំណើ និងស្វីការ។

### កថាភាគទី១. សំណើ

សំណើ គឺជាការសុំបង្កើតកិច្ចសន្យា ដែលធ្វើឡើងដោយមានឆន្ទៈភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្ត ក្នុងករណីដែលមានស្វីការរបស់ភាគីម្ខាងទៀតចំពោះសំណើនេះ [21] ។ សំណើមានអានុភាព នៅពេលដែលសំណើនោះបានដល់ភាគីម្ខាងទៀត។ តែបើដំណឹងអំពីការដកសំណើវិញ ដល់ភាគីម្ខាងទៀតនៅពេលព្រមគ្នានឹងពេលសំណើដល់ ឬមុនពេលសំណើដល់នោះ អានុភាពនៃសំណើនោះមិនត្រូវកើតឡើងឡើយ។

**ឧទាហរណ៍៖** លោក A បាននិយាយទៅកាន់លោក B ថា ខ្ញុំចង់ផ្ញើឡាននៅកន្លែងរបស់អ្នក។ ការស្នើរបស់លោក A ហៅថា សំណើ។

[19] មាត្រា៣៣៧ ១ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[20] មាត្រា៦ សេចក្ដីកំណត់មាត្រានីមួយនៃក្រមរដ្ឋប្បវេណី ឆ្នាំ២០១០។

[21] មាត្រា៣៣៧ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

**១.លក្ខខណ្ឌសុពលភាពនៃសំណើ**

សំណើមានសុពលភាពនៅពេល ដែលសំណើមានលក្ខណៈច្បាស់លាស់ និងមានបញ្ជាក់ពីគោលបំណងនៃសំណើ ហើយត្រូវតែមានការជូនដំណឹងអំពីសំណើដល់ភាគីម្ខាងទៀត។

**១.១.សំណើត្រូវតែមានលក្ខណៈច្បាស់លាស់**

សំណើត្រូវតែមានលក្ខណៈច្បាស់លាស់ សំដៅទៅលើសំណើ ដែលមានខ្លឹមសារច្បាស់លាស់ មានលិខិតលាយលក្ខណ៍អក្សរ និងគោលបំណងពិតប្រាកដ។

**ឧទាហរណ៍៖** លោក A បានដាក់សំណើជាលាយលក្ខណ៍អក្សរទៅលោក B ថាគាត់ចង់ផ្ញើម៉ូតូនៅកន្លែងផ្ញើម៉ូតូរបស់លោក B ដោយបញ្ជាក់ពីស្លាកលេខ ម៉ាក ម៉ូតូ យ៉ាងច្បាស់លាស់ ហើយផ្ញើក្នុងតម្លៃ ១០$ក្នុងមួយខែ។ លោក B បានទទួលសំណើរួចក៏ឆ្លើយតបថាយល់ព្រមទទួលបញ្ញើនូវវត្ថុបញ្ញើ ដែលជាម៉ូតូរបស់លោក A។ ម៉្យាងទៀតលោកបានបញ្ជាក់ច្បាស់ថាលោក A ពិតជាមានបំណងចង់ផ្ញើម៉ូតូឱ្យទៅលោក B ពិតប្រាកដមែន។ ដូចនេះ សំណើមានអានុភាព ពីព្រោះសំណើមានភាពច្បាស់លាស់។

**១.២.បញ្ជាក់ពីគោលបំណងនៃសំណើ**

អ្នកដាក់សំណើ ត្រូវតែបញ្ជាក់យ៉ាងច្បាស់លាស់ថាមានគោលបំណងចង់បង្កើតកិច្ចសន្យាពិតប្រាកដទើបសំណើមានអានុភាពក្នុងការអនុវត្ត។ សំណើ មិនមានអានុភាពនៅពេលសំណើនោះជាសំណើដោយការលេងសើចមិនច្បាស់លាស់ មិនមានគោលដៅពិតប្រាកដ ឬក្នុងពេលភ័យខ្លាចនោះទេ។ ករណីនេះក៏មិនអាចបង្កើតកិច្ចសន្យាចងកាតព្វកិច្ចតាមផ្លូវច្បាប់សម្រាប់ភាគីម្ខាងទៀតក្នុងការធ្វើស្វីការបានដែរ។

**ឧទាហរណ៍៖** លោក A បានដាក់សំណើទៅលោក B ថាគាត់ត្រូវផ្ញើម៉ូតូជាមួយលោក B ដើម្បីឱ្យលោក B រក្សាទុក និងមើលថែម៉ូតូនោះ។ សំណើនេះមានអានុភាពពីព្រោះបានបញ្ជាក់ថាគាត់ត្រូវផ្ញើម៉ូតូនេះ។ ប្រសិនបើលោក A បានដាក់សំណើទៅលោក B ថាគាត់អាចនឹងផ្ញើម៉ូតូ ដើម្បីឱ្យ B រក្សាទុក។ ក្នុងករណីនេះ សំណើនេះមិនមានអានុភាពទេ ពីព្រោះលោក A បានដាក់សំណើមែន តែមិនប្រាកដថាគាត់មានបំណងផ្ញើម៉ូតូឱ្យលោក B ឬអត់ទេ ដោយសារគាត់បានប្រើពាក្យថាអាចនឹងផ្ញើ មានន័យថាសំណើមិនមានភាពច្បាស់លាស់នោះទេ។

**១.៣.សំណើត្រូវបានដល់ភាគីទទួលសំណើ**

សំណើមានអានុភាពនៅពេលដែលសំណើនោះបានដល់ភាគីម្ខាងទៀត ដោយអនុលោមតាមគោលការណ៍ទាក់ទងទៅនឹងពេលវេលា ដែលការបង្ហាញឆន្ទៈត្រូវមានអានុភាព។ តែបើដំណឹងអំពីការដកសំណើវិញ ដល់ភាគីម្ខាងទៀតនៅពេលព្រមគ្នានឹងពេលសំណើដល់ ឬមុនពេលសំណើដល់នោះ អានុភាពនៃសំណើនោះមិនត្រូវកើតឡើងឡើយ។

**ឧទាហរណ៍៖** លោក A បានខលទូរស័ព្ទ ដើម្បីដាក់សំណើទៅ លោក B តែលោក B មិននៅ កូនរបស់លោក B បានលើកទូរស័ព្ទជំនួស ហើយទទួលសំណើជំនួសលោក B។ ដូចនេះ សំណើ នេះមានអានុភាព ពីព្រោះកូនរបស់គាត់បានទទួលសំណើជំនួស។

## ២.អានុភាពនៃសំណើ

### ២.១.សំណើមានកំណត់អំឡុងពេលសម្រាប់ស្ទីការ និងការដកសំណើនោះ

សំណើអាចធ្វើឡើងបានដោយកំណត់អំឡុងពេលសម្រាប់ស្ទីការ។ អំឡុងពេលសម្រាប់ស្ទីការ ត្រូវគិតចាប់ពីថ្ងៃដែលជូនដំណឹងអំពីសំណើ បើមិនច្បាស់ថាអ្នកស្នើកំណត់ពេលផ្សេង។ សំណើដែលត្រូវបានធ្វើឡើងដោយមានកំណត់អំឡុងពេលសម្រាប់ស្ទីការមិនអាចដកវិញបានទេ ។

ប្រសិនបើអ្នកស្នើមិនបានទទួលដំណឹងអំពីស្ទីការ ក្នុងអំឡុងពេលដែលបានកំណត់នៅកថាខណ្ឌទី១ខាងលើនេះទេ សំណើនោះត្រូវបាត់បង់អានុភាពដោយស្វ័យប្រវត្តិ នៅពេលផុតអំឡុងពេលសម្រាប់ស្ទីការ។ ក្នុងករណីដែលដំណឹងអំពីការបដិសេធសំណើបានដល់អ្នកស្នើក្នុងអំឡុងពេលសម្រាប់ស្ទីការនោះ សំណើនោះក៏ត្រូវបាត់បង់អានុភាពដែរ[22]។

**ឧទាហរណ៍៖** មានករណីមួយ លោក A បានប្រាប់ លោក B ថា ចង់លក់ឡានរបស់ខ្លួនក្នុងតម្លៃ ២០,០០០ ដុល្លារ ហើយស្នើឱ្យ B ធ្វើការឆ្លើយតបក្នុងរយៈពេលមួយសប្តាហ៍។ រយៈពេលមួយសប្តាហ៍ ត្រូវចាប់ផ្តើមគិតចាប់ពីពេល A បានប្រាប់ ហើយប្រសិនបើហួសអំឡុងពេលមួយសប្តាហ៍ ចាត់ទុកថាសំណើនោះគ្មានអានុភាព ហើយ A អាចដកសំណើនោះវិញបាន។

### ២.២.សំណើគ្មានកំណត់អំឡុងពេលសម្រាប់ស្ទីការ និងការដកសំណើនោះ

ចំពោះសំណើ ដែលត្រូវបានធ្វើឡើងដោយគ្មានកំណត់អំឡុងពេល សម្រាប់ស្ទីការ រវាងគូភាគី ដែលកំពុងនិយាយគ្នានៅក្នុងស្ថានភាព ដែលអាចឆ្លើយភ្លាមៗបាន ប្រសិនបើភាគីដែលទទួលសំណើមិនបានយល់ព្រមភ្លាមៗទេ សំណើនោះត្រូវបាត់បង់អានុភាព។

ចំពោះសំណើ ដែលធ្វើរវាងគូភាគី ដែលមិនពិភាក្សាគ្នាអំពីការកំណត់អំឡុងពេលសម្រាប់ស្ទីការទេ អ្នកស្នើមិនអាចដកសំណើនោះវិញ ក្នុងអំឡុងពេលសមរម្យបានឡើយ។ ការដកសំណើត្រូវមានអានុភាព នៅពេលដល់ការជូនដំណឹងអំពីការដកសំណើនោះបានមកដល់ភាគីម្ខាងទៀត មុនពេលភាគីម្ខាងទៀត ជូនដំណឹងអំពីស្ទីការ[23]។

**ឧទាហរណ៍៖** កញ្ញាA បានដាក់សំណើទៅកញ្ញា B ថាគាត់ផ្ញើសៀវភៅនៅ B ។ B មិនទាន់តបទៅនឹងសំណើនោះទេ A ក៏ដកសំណើនោះវិញ។

## កថាភាគទី២. ស្ទីការ

ស្ទីការ គឺជាការបង្ហាញឆន្ទៈ ដែលអ្នកទទួលសំណើយល់ព្រមចំពោះសំណើនោះ។ ស្ទីការត្រូវមានអានុភាពនៅពេលដែលស្ទីការនោះបានដល់អ្នកស្នើ។ ប៉ុន្តែប្រសិនបើដំណឹងអំពីការដកស្ទីការវិញ ដល់អ្នកស្នើ នៅពេលព្រមគ្នា

[22] មាត្រា៣៣៨ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[23] មាត្រា៣៣៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

នឹងពេលស្ទីការដល់ ឬ មុនពេលស្ទីការដល់ នោះអានុភាពនៃស្ទីការ មិនត្រូវកើតឡើយ[24]។

**ឧទាហរណ៍៖** លោក A បាននិយាយទៅកាន់លោក B ថា ខ្ញុំចង់ផ្ញើឡាននៅកន្លែងរបស់លោក។ លោក B បានតបវិញថា ខ្ញុំយល់ព្រមទទួលបញ្ញើក្នុងការថែរក្សាឡានរបស់លោក A ក្នុងតម្លៃ៣០$ក្នុង១ខែ។ ការឆ្លើយតបរបស់លោក B ហៅថាស្ទីការ។

## ផ្នែកទី២. វិការៈក្នុងការបង្ហាញឆន្ទៈ

កិច្ចសន្យាមានអានុភាពនៅពេលការបង្ហាញឆន្ទៈរបស់ភាគីទាំងពីរស្របគ្នាទៅវិញទៅមក។ ហេតុដូច្នេះហើយ បើគ្មានការបង្ហាញឆន្ទៈ ដែលមានអានុភាព ដែលជាធាតុផ្សំនៃកិច្ចសន្យាទេ កិច្ចសន្យាពុំមានចំណងភ្ជាប់ភាគីទាំងពីរតាមផ្លូវច្បាប់នោះទេ។ មួយវិញទៀត ប្រសិនបើការបង្ហាញឆន្ទៈនោះមានវិការៈ (ភាពមិនប្រក្រតី) ណាមួយភាគីម្ខាងទៀតអាចទាមទារឱ្យលុបចោលកិច្ចសន្យានោះបាន។ វិការៈនៃការបង្ហាញឆន្ទៈរួមមាន៖ ការភាន់ច្រឡំ ការឆបោកពត៌មានមិនពិត ការរំលោភលើស្ថានភាព ការគំរាមមកកំហែង អំពើកេងយកចំណេញហួសហេតុ បបនីយផ្លូវចិត្ត ការបង្ហាញឆន្ទៈមិនពិត។

### កថាភាគទី១. ការភាន់ច្រឡំ

ការភាន់ច្រឡំ គឺជាការបង្ហាញឆន្ទៈទៅលើកិច្ចសន្យាដោយការយល់ច្រឡំអំពីខ្លឹមសារនៅកិច្ចសន្យ[25]។ ក្នុងករណី ដែលភាគីមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា ភាគីម្ខាងទៀតស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីការភាន់ច្រឡំនេះ ភាគីដែលមានការភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។

ក្នុងករណីដែលភាគីម្ខាងនៃកិច្ចសន្យា មានការភាន់ច្រឡំអំពីចំណុចនៃកិច្ចសន្យា ដែលខ្លួនយល់ឃើញថាសំខាន់ ឬចំណុចដែលខ្លួនយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា បើភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីភាពសំខាន់នៃចំណុចនេះ និងការភាន់ច្រឡំរបស់អ្នកបង្ហាញឆន្ទៈនោះ ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ។

ក្នុងករណី ដែលភាគីទាំងសងខាងមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា ឬចំណុចណាមួយនៃកិច្ចសន្យា ដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា ទោះបីជាភាគីម្ខាងមិនមានលទ្ធភាពអាចដឹងអំពីការភាន់ច្រឡំរបស់ភាគីម្ខាងទៀតក៏ដោយ ក៏ភាពដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបានដែរ ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។ ការលុបចោលកិច្ចសន្យាដោយការភាន់ច្រឡំ ក្រៅ

---

[24] មាត្រា៣៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[25] មេរៀនស្ដីពី ក្រមរដ្ឋប្បវេណី&ក្រមនីតិវិធីរដ្ឋប្បវេណី ដោយគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់និងតុលាការក្រសួងយុត្តិធម៌និងJICA។

ពីភាគីម្ខាងទៀតអាចអះអាងចំពោះតតិយជនបាន។ ប៉ុន្តែប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីការភាន់ច្រឡំមិនអាចអះអាងនូវការលុបចោលចំពោះតតិយជននោះបានឡើយ[26]។

**ឧទាហរណ៍៖** លោក A គាត់បានដាក់សំណើទៅលោក B ថាគាត់ចង់ផ្ញើទូរស័ព្ទមួយគ្រឿង។ បន្ទាប់មកលោក A ក៏យល់ព្រមទទួលសំណើនោះ ព្រោះគាត់គិតថាទូរស័ព្ទនោះមានតម្លៃថោក។ ក្រោយមកមកលោក B ក៏យកទូរស័ព្ទមក ប៉ុន្តែទូរស័ព្ទនោះជាប្រភេទទូរស័ព្ទ ដែលមានតម្លៃថ្លៃ (IPHONE 13 PRO)។ នៅពេលលោក B ឃើញគាត់មិនចង់ទទួលបញ្ញើនោះទេ។ ក្នុងករណីនេះ B អាចលុបចោលបាន ពីព្រោះនៅក្នុងកិច្ចសន្យាបញ្ញើនេះ ការបង្ហាញយល់ឆន្ទៈមានវិការៈដោយមានការភាន់ច្រឡំចំពោះការព្រមព្រៀង។

### កថាភាគទី២. ការឆបោក

បុគ្គលដែលបានធ្វើការបង្ហាញឆន្ទៈ ដោយសារការឆបោករបស់ភាគីម្ខាងទៀត អាចលុបចោលកិច្ចសន្យាដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ[27]។ ក្នុងករណី ដែលការបង្ហាញឆន្ទៈបានធ្វើឡើងដោយសារការ ឆបោករបស់តតិយជន អ្នកបង្ហាញឆន្ទៈអាចលុបចោលនូវកិច្ចសន្យា ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ លុះត្រាតែក្នុងករណី ដែលភាគីម្ខាងទៀតនៃការបង្ហាញឆន្ទៈនោះបានដឹង ឬអាចដឹងអំពីការឆបោកនោះ។

ការលុបចោលនូវកិច្ចសន្យាដោយការឆបោក ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន។ ប៉ុន្តែប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីការឆបោក មិនអាចអះអាងនូវអានុភាពនៃការលុបចោលចំពោះតតិយជននោះបានឡើយ[28]។

**ឧទាហរណ៍៖** លោក A គាត់បាននិយាយប្រាប់ B ថាគាត់ជាបុគ្គលិកក្នុងក្រុមហ៊ុនដឹកជញ្ជូនទទួលបញ្ញើអីវ៉ាន់គ្រប់ប្រភេទ គាត់បានប្រាប់ថា ក្រុមហ៊ុនមានបញ្ចុះតម្លៃបើលោកផ្ញើអីវ៉ាន់។ លោក A ក៏បានចុះកិច្ចសន្យាព្រមព្រៀងនឹងផ្ញើអីវ៉ាន់នៅក្នុងក្រុមហ៊ុននេះ។ ក្រោយមក លោក A បានដឹងថាក្រុមហ៊ុននេះមិនមានការបញ្ចុះតម្លៃនោះទេ។ ដូចនេះលោក A អាចលុបចោលកិច្ចសន្យាបញ្ញើនេះបាន ដោយសារកិច្ចសន្យាបញ្ញើនេះបានបង្ហាញថាមានវិការៈដោយការឆបោក។

### កថាភាគទី៣. ព័ត៌មានមិនពិត

នៅពេលធ្វើកិច្ចសន្យា បើហេតុដែលបង្ហាញដោយភាគីម្ខាងនោះខុសពីការពិត ហើយភាគីម្ខាងទៀតបានបង្ហាញឆន្ទៈដោយជឿជាក់ថា ហេតុទាំងនោះជាការពិត ប៉ុន្តែបើភាគីនោះដឹងថា ហេតុនោះមិនមែនជាការពិត ខ្លួននឹងមិនបង្ហាញឆន្ទៈទេ ភាគីនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ។ ក្នុងករណីដែលបុគ្គលនោះមានកំហុសមិនរារាំងភាគី ដែលបានបង្ហាញឆន្ទៈក្នុងការទាមទារសំណងនៃការខូចខាតពី

---

[26] មាត្រា៣៤៦ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[27] មាត្រា៣៤៧ ១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[28] មាត្រា៣៤៧ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

បុគ្គល ដែលបានបង្ហាញការណ៍មិនពិតនោះទេ។ ការលុបចោលនូវកិច្ចសន្យាដោយពត៌មានមិនពិត ក្រៅពីភាគីម្ខាងទៀតអាចអះអាងចំពោះតតិយជនបាន។ ប៉ុន្តែប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីពត៌មានមិនពិត មិនអាចអះអាងនូវអានុភាពនៃការលុបចោលចំពោះតតិយជននោះបានឡើយ[29]។

**ឧទាហរណ៍៖** លោក A បានប្រាប់ លោក B ថាកន្លែងផ្ញើឡានរបស់គាត់មានសុវត្ថិភាព ប៉ុន្តែតាមការពិតកន្លែងផ្ញើនោះពុំមានសុវត្ថភាពនោះទេ។ នេះបង្ហាញថាវាជាការបង្ហាញពត៌មានមិនពិត។

### កថាភាគទី៤. ការរំលោភបំពានលើស្ថានភាព

នៅពេលកិច្ចសន្យា បើភាគីកិច្ចសន្យាបានប្រើដោយមិនត្រឹមត្រូវនូវឋានៈខ្លួន ដែលមានអាទិភាពជាងភាគីម្ខាងទៀត ខាងផ្នែកសេដ្ឋកិច្ច ឬសង្គម ឬបានប្រើដោយមិនត្រឹមត្រូវនូវស្ថានភាពផ្សេងទៀត ដែលភាគីម្ខាងទៀតមិនអាចប្រឆាំងតបបានទេ ភាគីម្ខាងទៀតនោះអាចលុបនូវកិច្ចសន្យាបានដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។

ការលុបចោលនូវកិច្ចសន្យាមិនអាចអះអាងចំពោះតតិយជន ដែលជាជនសុចរិត ហើយគ្មានកំហុសអំពីការរំលោភបំពានលើស្ថានភាពបានឡើយ[30]។

**ឧទាហរណ៍៖** លោក A យកឡានទៅផ្ញើនៅកន្លែងផ្ញើឡានរបស់លោក B ហើយនិយាយថា បើលោក B មិនយល់ព្រមទទួលបញ្ញើ គាត់នឹងឱ្យប្អូនរបស់គាត់កាត់ប្រាក់ខែរបស់លោក B ។

### កថាភាគទី៥. ការគំរាមកំហែង

បុគ្គលដែលបានបង្ហាញឆន្ទៈដោយសារមានការគម្រាមកំហែងពីសំណាក់ភាគីម្ខាងទៀត ឬពីសំណាក់តតិយជនអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ[31] ។ ការបង្ហាញឆន្ទៈដោយមានការគំរាមកំហែងក៏ជាការបង្ហាញឆន្ទៈ ដែលអនុញ្ញាតឱ្យអ្នកបង្ហាញឆន្ទៈលុបចោលកិច្ចសន្យាបាន។

**ឧទាហរណ៍៖** លោក A បានដាក់សំណើទៅ B ថា ផ្ញើម៉ូតូ១០គ្រឿង នៅកន្លែងផ្ញើម៉ូតូរបស់លោក B។ លោក B បានតបមិនយល់ព្រមសំណើរបស់លោក A ទេ។ ប៉ុន្តែក្នុងករណីនេះ លោក A បានគំរាមលោក B ថា បើមិនទទួលបញ្ញើទេនោះ លោកនឹងដុតកន្លែងផ្ញើម៉ូតូនោះចោល បន្ទាប់មកលោក B ក៏បានយល់ព្រមព្រោះដោយភាពភ័យខ្លាចការគំរាមពីសំណាក់លោក A។

### កថាភាគទី៦. ការកេងយកចំណេញហួសហេតុ

ក្នុងករណី ដែលភាគីម្ខាងបានធ្វើកិច្ចសន្យាដោយឆ្លៀតឱកាសដោយភាគីម្ខាងទៀតកំពុងជួបការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬភាពល្ងង់ខ្លៅ ឬខ្វះការពិសោធន៍ ហើយបានយកកេងចំណេញពីកិច្ចសន្យានោះ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាដោយហេតុថា ការបង្ហាញឆន្ទៈមានវិការៈ[32]។

[29] មាត្រា៣៤៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[30] មាត្រា៣៤៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[31] មាត្រា៣៥០ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[32] មាត្រា៣៥១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

**ឧទាហរណ៍៖** កញ្ញា A បើកឡានទៅផ្សារ។ នៅពេលទៅដល់គាត់បានផ្ញើឡាននៅកន្លែងផ្ញើឡាន (បញ្ញើយកកម្រៃ)។ បន្ទាប់ពីទិញរួច គាត់ដើរចេញពីផ្សារទៅយកឡាន ប៉ុន្តែអ្នកទទួលបញ្ញើនោះឃើញថាកញ្ញា A ជាមនុស្សល្ងង់ ជាហេតុធ្វើឱ្យអ្នកទទួលបញ្ញើទាមទារប្រាក់លើសពីតម្លៃ ដែលធ្លាប់ផ្ញើរាល់ដង ដោយតម្លៃផ្ញើរាល់ដងត្រឹមតែ ១៥០០ រៀល តែគាត់(អ្នកទទួលបញ្ញើ) ទាមទារដល់ទៅ ១៥០០០រៀល។ ក្នុងករណីនេះកញ្ញា អាចលុបចោលកិច្ចសន្យាបាន ដោយហេតុថាការបង្ហាញឆន្ទៈមានវិការៈដោយការកេងប្រវ័ញ្ចហេតុ។

### កថាភាគទី៧. ឋបនីយផ្លូវចិត្ត

ប្រសិនបើកិច្ចសន្យាត្រូវបានបង្កើតឡើងដោយការបង្ហាញឆន្ទៈ ដែលភាគីដោយដឹងខ្លួនថាខុសឆន្ទៈពិតរបស់ខ្លួនកិច្ចសន្យានោះមិនត្រូវរារាំងដោយអានុភាពឡើយ។ ប៉ុន្តែក្នុងករណី ដែលភាគីម្ខាងទៀតក៏ដឹងថាការបង្ហាញឆន្ទៈនោះខុសពីឆន្ទៈពិតរបស់អ្នកបង្ហាញឆន្ទៈនៅតែអាចបដិសេធការអនុវត្តកិច្ចសន្យាបាន[33]។

**ឧទាហរណ៍ ៖** លោក "ក" មានបំណងយករថយន្តរបស់ខ្លួនម៉ាក LEXUS LX 600 F-Sport ទៅផ្ញើនៅកន្លែងផ្ញើរថយន្តរបស់លោក "ខ"។ លោក "ខ" ដឹងថាខ្លួនមិនអាចមានលទ្ធភាពក្នុងការមើលថែរក្សារថយន្ត ដែលមានតម្លៃថ្លៃនេះបានទេ ព្រោះបារម្ភថា បើមានការខូចខាតណាមួយទៅលើរថយន្តនេះ ខ្លួននឹងមិនមានលទ្ធភាពក្នុងការសងការខូចខាតទៅឱ្យលោក "ក" ទេ។ ដោយសារមានការបញ្ចុះបញ្ចូលពីលោក "ក" ធ្វើឱ្យលោក "ខ" យល់ព្រមទទួលបញ្ញើ ដោយមានការបារម្ភក្នុងចិត្ត។ ក្នុងករណីនេះបញ្ជាក់ថា "ខ" គ្មានឆន្ទៈក្នុងការទទួលយកសំណើរបស់ "ក" ទេ។ ការបង្ហាញឆន្ទៈនេះទៀតសោត ក៏ខុសពីឆន្ទៈពិតប្រាកដដំបូងរបស់គាត់ដែរ។ ដូចនេះ លោក "ខ" អាចបដិសេធការអនុវត្តកិច្ចសន្យាបាន។

## ផ្នែកទី២. សមត្ថភាពនៃភាគី

នៅក្នុងការបង្កើតកិច្ចសន្យា សមត្ថភាពរបស់ភាគីជាលក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌសំខាន់ៗផ្សេងទៀត ព្រោះថាបើភាគីមិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបង្កើតកិច្ចសន្យានោះទេ កិច្ចសន្យានោះនឹងមិនមានសុពលភាពតាមផ្លូវច្បាប់ឡើយ។ ដូច្នេះហើយ គ្រប់ភាគីទាំងអស់ត្រូវមានសមត្ថភាពដូចខាងក្រោម៖

### កថាភាគទី១. សមត្ថភាពទទួលបាននូវសិទ្ធិ

ប្រសិនបើភាគីណាម្ខាងនៃកិច្ចសន្យាមិនមានសមត្ថភាពទទួលសិទ្ធិនោះទេ កិច្ចសន្យានឹងគ្មានសុពលភាពទេ។ សមត្ថភាពទទួលសិទ្ធិ មានន័យថាក្នុងឋានៈជាមនុស្ស មិនត្រូវមានការរើសអើងវណ្ណៈ ភេទ អាយុ មុខរបរ សាសនា ជាអាទិ៍ឡើយ ហើយមនុស្សគ្រប់រូបមានលក្ខណៈសម្បត្តិអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចបាន[34]។ អ្នកដែលអាចទទួលសិទ្ធិក្នុងការធ្វើសកម្មភាពបាន មានតែនីតិជន ឬអនីតិជនដែលទទួលបាននូវ អត្តាធីនភាពប៉ុណ្ណោះ។ ទោះបីជា សមត្ថភាពក្នុងការទទួលសិទ្ធិមិនត្រូវមានការរើសអើង វណ្ណៈ ជាតិសាសន៍ក៏ពិតមែន ប៉ុន្តែច្បាប់ក៏បាន

[33] មាត្រា៣៥២ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[34] មាត្រា៦ សេចក្តីកំណត់មាត្រានីមួយៗចំពោះក្រមរដ្ឋប្បវេណី ឆ្នាំ២០១០។

កំណត់អំពីការទទួលសិទ្ធិចំពោះជនបរទេស ដែលមិនអាចទទួលបាន ឬកាន់កាប់នូវសិទ្ធិមួយចំនួនដែលត្រូវបានកំណត់ឡើយ ក្នុងករណីដែលមានបញ្ញត្តិផ្សេងនៅក្នុងច្បាប់ជាតិ ឬសន្ធិសញ្ញា ឬ អនុសញ្ញាអន្តរជាតិ។ ឧទាហរណ៍ជាក់ស្តែងនៃករណីដែលមានកំណត់ដោយច្បាប់មានដូចជា នៅក្នុងរដ្ឋធម្មនុញ្ញ មាត្រា៤៤ កថាខណ្ឌទី១ មានចែងថា មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី។

**កថាភាគទី២. សមត្ថភាពខាងឆន្ទៈ**

សមត្ថភាពខាងឆន្ទៈ គឺជាសមត្ថភាពដែលអាចយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នូវសកម្មភាពរបស់ខ្លួន [35] ។ ប្រសិនបើភាគីណាម្ខាងនៃកិច្ចសន្យាមិនមានសមត្ថភាពខាងឆន្ទៈទេនោះ កិច្ចសន្យានឹងមិនមានសុពលភាព ហើយអាចលុបចោលបាន។ មានន័យថា នៅពេលដែលគូភាគី បានបង្កើតកិច្ចសន្យាជាមួយគ្នាអាចប្រព្រឹត្តទៅបានដោយពេញលេញ គឺត្រូវប្រាកដថាភាគីទាំងពីរមានភាពប្រក្រតី និងបានដឹង បានយល់អំពីខ្លឹមសារនៃកិច្ចសន្យានោះច្បាស់លាស់ ដោយមិនមានការយល់ច្រឡំ និងមិនមានវិការៈ ហើយការបង្កើតកិច្ចសន្យានេះឡើងក្នុងស្ថានភាពដែលមានសតិ និងស្មារតីត្រឹមត្រូវ មិនមានសេពគ្រឿងញៀន គ្រឿងស្រវឹង ឬមានវិបល្លាសស្មារតីឡើយ។

**កថាភាគទី៣. សមត្ថភាពធ្វើសកម្មភាព**

សមត្ថភាពក្នុងការធ្វើសកម្មភាព គឺជាសមត្ថភាពក្នុងការធ្វើកិច្ចសន្យា ឬសកម្មភាពឯកតោភាគី ដែលមិនអាចលុបចោលបានដោយឯកឯង[36]។ ប្រសិនបើ ភាគីណាម្ខាងនៃកិច្ចសន្យាមិនមានសមត្ថភាពក្នុងការធ្វើសកម្មភាពទេ នោះកិច្ចសន្យាមានសុពលភាព តែអាចលុបចោលបាន។ សកម្មភាព សំដៅលើកិច្ចសន្យា ឬសកម្មភាពឯកតោភាគី [37] ។ អ្នកដែលមានសមត្ថភាពក្នុងការធ្វើសកម្មភាពមានដូចជា នីតិជន និងអនីតិជនដែលទទួលបានអត្តាធីនភាពប៉ុណ្ណោះ។ ច្បាប់បានកំណត់ និងបានកម្រិតសមត្ថភាពច្បាស់លាស់ចំពោះអ្នកដែលអាចធ្វើសកម្មភាពបាន គឺជនណាដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ ជនស្ថិតនៅក្រោម ហិតូបត្ថម្ភ និងអនីតិជនជាដើម ជនដែលមិនមានក្នុងលក្ខខណ្ឌទាំងនេះ ត្រូវបានកម្រិតសមត្ថភាពអាចបង្កើតនូវកិច្ចសន្យាមានសុពលភាពពេញលេញ លើកលែងតែមានមូលហេតុផ្សេងទៀតនាំឱ្យមោឃៈភាព ឬមូលហេតុដែលអាចលុបចោលកិច្ចសន្យានោះបាន។

**១.នីតិជន**

រូបវន្តបុគ្គលគ្រប់រូប មានលក្ខណសម្បត្តិអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចបាន[38]។ រូបវន្តបុគ្គលទទួលបាននូវបុគ្គលភាពភាពនៅពេលដែលបានដល់នីតិភាព។ នីតិជន សំដៅជនទាំងឡាយណា ដែលមានអាយុចាប់ពី

[35] មាត្រា១៤ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[36] មាត្រា១៦ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[37] មាត្រា១៥ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[38] មាត្រា៦ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

១៨ឆ្នាំឡើង។ នីតិជនមានសមត្ថភាពពេញលេញក្នុងការក្នុងការបង្ហាញឆន្ទៈប្រកបដោយប្រសិទ្ធភាពជាស្ថាពរ និងដោយឯករាជ្យ។ តាមន័យនេះ បុគ្គលដែលមានសកម្មភាពពេញលេញអាចបង្ហាញឆន្ទៈប្រកបដោយសុពលភាពដោយការសម្រេចចិត្តរបស់ខ្លួនផ្ទាល់ ដោយមិនចាំបាច់មានជំនួយពីបុគ្គលណាម្នាក់ឡើយ។

**២.អនីតិជនដែលទទួលបានអត្តាធីនភាព**

ជាគោលការណ៍ អនីតិជនមិនមានសមត្ថភាពក្នុងការធ្វើសកម្មភាព ដែលត្រូវបានទទួលស្គាល់ដោយច្បាប់នោះទេ។ បើទោះបីជាអនីតិជនបានធ្វើសកម្មភាពទាំងនោះក៏ដោយ ប្រសិនបើគ្មានការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបាទេ សកម្មភាពទាំងនោះនឹងអាចត្រូវបានលុបចោល ដើម្បីការពារប្រយោជន៍របស់អនីតិជន ជៀសវាងក្នុងការបង្កើតកិច្ចសន្យាជាមួយភាគីម្ខាងទៀតដោយមានវិការៈ។ ហេតុនេះហើយបានជា ច្បាប់អនុញ្ញាតឱ្យអនីតិជនអាចដល់នីតិភាពតាមរយៈការទទួលបានអត្តាធីនភាព។ អត្តាធីនភាព សំដៅស្ថានភាពមួយ ដែលផ្តល់ឱ្យអនីតិជនបានរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬរួចផុតពីអំណាចមេបា ហើយមានសមត្ថភាពដូចនីតិជនដែរ[39]។ ក្នុងករណី អនីតិជនដែលទទួលអត្តាធីនភាព ត្រូវចាត់ទុកថាបានដល់នីតិភាព[40]។ អនីតិជន អាចទទួលបានអត្តាធីនភាពដូចខាងក្រោម។

ក្នុងករណី ដែលអនីតិជនដែលបានដល់អាយុ១៦ (ដប់ប្រាំមួយ) ឆ្នាំ ទ្រទ្រង់ជីវភាពខ្លួនឯងដោយឯករាជ្យ តុលាការអាចប្រកាសនូវអត្តាធីនភាពរបស់អ្នកនោះបានតាមពាក្យសុំរបស់អនីតិជននោះ ប្រសិនបើតុលាការយល់ឃើញថា អត្តាធីនភាពស្របនឹងផលប្រយោជន៍របស់អនីតិជននោះ។ ក្នុងករណីនេះ តុលាការត្រូវសួរយោបល់ពីអ្នកមានសិទ្ធិអំណាចមេបា[41]។ ក្នុងលក្ខខណ្ឌនេះ ការដែលអនីតិជនអាយុ១៦ឆ្នាំឡើង អាចទ្រង់ទ្រង់ជីវភាពខ្លួនឯងដោយឯករាជ្យ ដោយមានការទទួលស្គាល់ពីអ្នកមានអំណាចមេបា អាចទទួលបានអត្តាធីនភាពដោយស្វ័យប្រវត្តិនោះទេ គឺចាំបាច់ត្រូវដាក់ពាក្យសុំទៅតុលាការ ដើម្បីឱ្យតុលាការប្រកាសអត្តាធីនភាពនេះ។

អនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ហើយ ត្រូវទទួលអត្តាធីនភាព ដោយមិនចាំបាច់មានការប្រកាសពីតុលាការទេ[42]។ ក្នុងករណីនេះ អនីតិជនដែលមានគំនិតចាស់ទុំអាចរៀបអាពាហ៍ពិពាហ៍តាមលក្ខខណ្ឌកំណត់ដោយច្បាប់ អាចចាត់ទុកជាអនីតិជនម្នាក់ដែលអាចប្រកបកិច្ចការជួញដូរ អាចធ្វើសកម្មភាពនានាបានដោយអាចពិចារណាពីលទ្ធផលតាមផ្លូវច្បាប់ ដូច្នេះត្រូវផ្តល់អត្តាធីនភាពដល់អនីតិជននោះ ដើម្បីរក្សានូវឯករាជ្យភាពនៃអាពាហ៍ពិពាហ៍។ ករណីនេះខុសពីអនីតិជន ដែលទទួលអត្តាធីនភាពដោយសារឯករាជ្យភាពនៃការទ្រទ្រង់ជីវភាពដោយខ្លួនឯង ដែល

[39] សន្ទានុក្រមផ្នែករដ្ឋប្បវេណី ដកស្រង់ចេញពីសន្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី, រៀបចំដោយគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់, បោះពុម្ពដោយទីស្តីការគណៈរដ្ឋមន្ត្រី, ឆ្នាំ២០០៧។

[40] មាត្រា២២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[41] មាត្រា២១ ១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[42] មាត្រា២១ ២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ត្រូវមានការស្នើសុំទៅតុលាការ។ ម្យ៉ាងវិញទៀត បើទោះបីភាគីលែងលះ គ្នាក៏ដោយ ក៏អានុភាពនៃអត្តាធីនភាពមិនរលត់ឡើយ[43]។

អនីតិជនមួយចំនួន អាចមានសមត្ថភាពយល់ដឹងខ្ពស់អាចមានភាពលំបាកក្នុងការធ្វើសកម្មភាពចំនួនដូចជា បញ្ញើ ការលក់ទិញ ការដូរ ជាអាទិ៍។ ហេតុនេះហើយ បានជាច្បាប់បង្កើតឱ្យមានរបបអត្តាធីនភាពឡើង ដើម្បីបង្កភាពងាយស្រួលដល់អនីតិជនក្នុងការធ្វើសកម្មភាពចាំបាច់របស់ខ្លួនប្រចាំថ្ងៃ។ ដូច្នេះ ច្បាប់កំណត់ឱ្យអនីតិជនអាចទទួលបានអត្តាធីនភាពដោយអនីតិជនអាយុ១៦ឆ្នាំ ដែលអាចទ្រទ្រង់ជីវភាពខ្លួនឯងដោយឯករាជ្យ និងការទទួលបានអត្តាធីនភាពដោយសារអាពាហ៍ពិពាហ៍។ ការបង្កើតឱ្យមានរបបស្តីពីអត្តាធីនភាពនេះ ផ្តល់ប្រយោជន៍យ៉ាងច្រើនដល់អនីតិជនក្នុងការធ្វើសកម្មភាពចាំបាច់នានា ដោយមានការទទួលស្គាល់ដោយច្បាប់ ដោយអាចជៀសវាងការធ្វើសកម្មភាពហើយ ត្រូវបានលុបចោលដោយសារជាសកម្មភាពដែលធ្វើឡើងដោយអនីតិជន។

ក្រោយពីបានស្វែងយល់អំពីការបង្កើតកិច្ចសន្យាបញ្ញើរួចហើយមក ជាកិច្ចបន្តទៅទៀតនេះ យើងនឹងបកស្រាយអំពីប្រភេទនៃកិច្ចសន្យាបញ្ញើ នៅក្នុងជំពូកបន្ទាប់ (ជំពូកទី៣)។

[43] មាត្រា២១ ៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

# ជំពូកទី៣
# ប្រភេទកិច្ចសន្យាបញ្ញើ

# ជំពូកទី៣
# ប្រភេទកិច្ចសន្យាបញ្ញើ

កិច្ចសន្យាបញ្ញើ ជាប្រភេទមួយនៃកិច្ចសន្យាជាច្រើន ដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។ ក្នុងកិច្ចសន្យាបញ្ញើនេះទៀតសោត ក៏មានការបែងចែកជាប្រភេទបន្តទៅទៀត ដើម្បីងាយស្រួលកំណត់អំពីសញ្ញាណគតិយុត្តខុសគ្នាក្នុងការអនុវត្ត ពីប្រភេទមួយទៅប្រភេទមួយទៀត។ ក្នុងសង្គមបច្ចុប្បន្ន យើងមើលឃើញថាវត្ថុមួយចំនួនត្រូវបានគេរក្សាទុកដោយយកកម្រៃ ហើយគោលការណ៍ដោយឱ្យបង់កម្រៃត្រូវតែមានការសន្យាពិសេស ប៉ុន្តែនៅពេលដែលអ្នកទទួលបញ្ញើទទួលនូវការផ្ញើក្នុងនាមអាជីវកម្មរបស់ខ្លួន។ ជាគោលការណ៍បញ្ញើនោះ ត្រូវសន្មតថាបញ្ញើដែលអ្នកទទួលបញ្ញើបានទទួលនូវការផ្ញើក្នុងនាមអាជីវកម្មរបស់ខ្លួន គឺជាបញ្ញើដែលអ្នកទទួលបញ្ញើនោះ ទទួលម្តងហើយម្តងទៀតពីបុគ្គលផ្សេងៗ ដោយទទួលបានផលចំណេញ ដូចជាអាជីវកម្ម ឃ្លាំងស្តុកទំនិញ គឺជាបញ្ញើសម្រាប់អាជីវកម្ម ប៉ុន្តែការថែរក្សាទុកអីវ៉ាន់នៅសណ្ឋាគារឱ្យមានសុវត្ថិភាព មិនមែនជាបញ្ញើសម្រាប់អាជីវកម្មនោះទេ ពីព្រោះសណ្ឋាគារមិនបានទទួលផលចំណេញពីបញ្ញើនោះឡើយ។ រីឯបញ្ញើខ្លះ ត្រូវធ្វើឡើងដោយមិនយកកម្រៃ ដោយហេតុថា អ្នកផ្ញើបានយកទ្រព្យសម្បត្តិរបស់ខ្លួនផ្ញើជាមួយនឹងអ្នកជិតខាង ឬអ្នកស្គាល់គ្នាជាដើម។ បញ្ញើ ដែលមិនយកកម្រៃបែបនេះ នាំឱ្យមានការកាត់បន្ថយនូវការទទួលខុសត្រូវរបស់អ្នកទទួលបញ្ញើផងដែរ។

ជំពូកទី៣នេះ នឹងលើកឡើងពីរប្រភេទកិច្ចសន្យាបញ្ញើ រួមមានកិច្ចសន្យាបញ្ញើដោយយកកម្រៃ (ផ្នែកទី១) និងកិច្ចសន្យាបញ្ញើដោយមិនយកកម្រៃ (ផ្នែកទី២) ព្រមទាំងបានលើកយកករណីសិក្សាមកធ្វើការសិក្សាផងដែរ (ផ្នែកទី៣)។

## ផ្នែកទី១. កិច្ចសន្យាបញ្ញើដោយយកកម្រៃ

កិច្ចសន្យាបញ្ញើយកកម្រៃ ជាប្រភេទកិច្ចសន្យាមួយ ដែលភាគីម្ខាងជាអ្នកទទួលបញ្ញើ សន្យាទទួលយកវត្ថុបញ្ញើ ពីភាគីម្ខាងទៀតជាអ្នកមករក្សាទុកក្នុងអំឡុងពេលដែលបានកំណត់ ហើយនៅក្រោយពេលដែលអំឡុងពេលរក្សាទុកនោះត្រូវបានបញ្ចប់ត្រូវសងវត្ថុដដែលនោះទៅឱ្យអ្នកផ្ញើវិញ។[44]

**ឧទាហរណ៍៖** លោក X បានផ្ញើម៉ូតូនៅលោក Y ដើម្បីឱ្យលោក Y អ្នករក្សាទុក ក្នុងរយៈពេលមួយខែ លុះដល់ពេលកំណត់មួយខែ លោក Y ត្រូវសងម៉ូតូដដែលនោះទៅឱ្យលោក X វិញ។ បើគ្មានកិច្ចសន្យាពិសេស អ្នកផ្ញើពុំមានករណីយកិច្ចបង់កម្រៃឱ្យអ្នកទទួលបញ្ញើឡើយ។ ប៉ុន្តែក្នុងករណី ដែលអ្នកទទួលបញ្ញើបានធ្វើកិច្ចសន្យានោះជាមួយអ្នកផ្ញើក្នុងនាមជាអាជីវកម្មរបស់ខ្លួន ឬប្រសិនបើមានកំណត់ក្នុងច្បាប់ ទោះបីជាពុំបានធ្វើកិច្ចសន្យាពិសេសចំពោះកម្រៃក៏ដោយ អ្នកទទួលបញ្ញើអាចទាមទារកម្រៃសមរម្យពីអ្នកផ្ញើបាន។[45]

**ឧទាហរណ៍៖** លោក A មានម្ហូប និងបន្លែជាច្រើនដើម្បីរក្សានៅឱ្យបានយូរ តែលោកA គាត់មិនមានគ្រឿងបរិក្ខារសម្រាប់រក្សាទុក ម្ហូប និងបន្លែឱ្យបានយូរនោះទេ។ លោក B បើកជាអាជីវកម្មមួយ ដែលគាត់មានគ្រឿងបរិក្ខារសម្រាប់

[44] មាត្រា ៦៦៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[45] មាត្រា៦៦៩ ១ ២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ស្តុកទុកម្ហូប និងបន្លែ។ ដូចនេះលោក A បានផ្ញើនៅលោក B ដែលលោក B យកកម្រៃសេវាសម្រាប់ស្តុកទុក ១០០$ ក្នុង១ខែ។

### កថាភាគទី១. លក្ខណៈនៃកិច្ចសន្យាបញ្ញើយកកម្រៃ

កិច្ចសន្យាបញ្ញើដោយយកកម្រៃ ជាកិច្ចសន្យាដែលមានលក្ខណៈជាកិច្ចសន្យាមុលា។ កិច្ចសន្យាមុលា ជាកិច្ចសន្យា ដែលភាគីទាំងសងខាងផ្តល់តាវកាលិក ដែលមានតម្លៃថ្នូរទៅវិញទៅមក។ ក្នុងកិច្ចសន្យាបញ្ញើដោយយកកម្រៃ អ្នកផ្ញើមានកាតព្វកិច្ចបង់កម្រៃទៅឱ្យអ្នកទទួលបញ្ញើ ហើយអ្នកទទួលបញ្ញើមានកាតព្វកិច្ចថែរក្សានូវវត្ថុបញ្ញើនោះ។ ក្នុងករណីដែលអ្នកទទួលបញ្ញើបានធ្វើកិច្ចសន្យានោះជាមួយអ្នកផ្ញើក្នុងនាមជាអាជីវកម្មរបស់ខ្លួន ឬប្រសិនបើមានកំណត់ក្នុងច្បាប់ ទោះបីជាពុំបានធ្វើកិច្ចសន្យាពិសេសចំពោះកម្រៃក៏ដោយ អ្នកទទួលបញ្ញើអាចទាមទារកម្រៃសមរម្យពីអ្នកផ្ញើបាន។ កិច្ចសន្យាបញ្ញើដោយយកកម្រៃ ត្រូវបានបង្កើតឡើង ដោយអ្នកទទួលបញ្ញើ ទទួលយកកម្មវត្ថុនៃបញ្ញើតាមការព្រមព្រៀង[46]។ ការព្រមព្រៀងគ្នាអាចចងគូភាគីបាន ប្រសិនបើភាគីទាំងពីរធ្វើការព្រមព្រៀងពិសេសចំពោះបញ្ញើនាពេលអនាគត ហើយមានបំណងឱ្យការព្រមព្រៀងគ្នានោះឱ្យមានអានុភាពចងគូភាគី[47]។

**ឧទាហរណ៍៖** ពាណិជ្ជករកំពុងនាំចូលទំនិញមកពីក្រៅប្រទេស ហើយបង្កើតកិច្ចសន្យាបញ្ញើសម្រាប់ពេលអនាគតជាមួយនឹងអ្នកកាន់កាប់ឃ្លាំង ដោយសារកប៉ាល់ដែលដឹកទំនិញនឹងមកដល់កំពង់ផែនៅថ្ងៃខាងមុខ។ ក្នុងករណីនេះបញ្ញើដោយយកតម្លៃថ្នូរ ដែលឱ្យអ្នកផ្ញើបង់កម្រៃវិញមានភាពសមរម្យក្នុងការផ្តល់ឱ្យត្រូវអានុភាពខ្លាំងជាងអានុភាពនៃបញ្ញើដោយមិនយកកម្រៃ[48]។ **ឧទាហរណ៍៖** ប្រសិនបើ A ចង់ផ្ញើទំនិញទៅឱ្យអ្នកកាន់កាប់ឃ្លាំង ចាប់ពីថ្ងៃទី០១ ខែក្រោយ ហើយអ្នកកាន់កាប់ឃ្លាំងបានយល់ព្រម អ្នកកាន់កាប់ឃ្លាំងត្រូវរៀបចំកន្លែងសម្រាប់ដាក់ទំនិញផ្ញើនៅថ្ងៃដែលបានសន្យា ដែលការណ៍នេះតម្រូវឱ្យមានការរៀបចំ និងការគ្រប់គ្រងឃ្លាំង ឧទាហរណ៍៖ ការគ្រប់គ្រង ឬការប្រើប្រាស់ឃ្លាំងដោយកុំព្យូទ័រ។ ចំពោះអ្នកផ្ញើវិញ A នឹងធ្វើសកម្មភាពដោយផ្អែកលើការសន្និដ្ឋានថា អ្នកកាន់កាប់ឃ្លាំងនឹងធ្វើការថែរក្សាទុកទំនិញ ចាប់តាំងពីថ្ងៃដូចបានព្រៀងទុកតាមការសន្យា ដោយគ្មានការខកខាន ពីព្រោះកិច្ចសន្យាស្តុកទំនិញ ជាកិច្ចសន្យាដោយយកកម្រៃ។ ដូច្នេះ វាមានភាពសមរម្យក្នុងការលើកកម្ពស់អានុភាពកិច្ចសន្យាបញ្ញើដោយយកកម្រៃ។

### កថាភាគទី២. សិទ្ធិ និងករណីយកិច្ចរបស់អ្នកផ្ញើ

#### ១.សិទ្ធិរបស់អ្នកផ្ញើ

អ្នកផ្ញើមានសិទ្ធិ ដូចជាសិទ្ធិទាមទារឱ្យសងវត្ថុបញ្ញើ សិទ្ធិទាមទារសំណងនៃការខូចខាត និងសិទ្ធិទទួលបានការជូនដំណឹងពីអ្នកទទួលបញ្ញើ។

[46] មាត្រា៦៧០ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[47] មាត្រា៦៧១ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[48] មាត្រា៦៧១ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

**១.១.សិទ្ធិទាមទារឱ្យសងវត្ថុបញ្ញើ**

សិទ្ធិទាមទាររបស់អ្នកផ្ញើឱ្យអ្នកទទួលបញ្ញើសងវត្ថុបញ្ញើវិញបានគ្រប់ពេលវេលា បើទោះបីជាភាគី បានកំណត់អំឡុងពេលនៃការសងវត្ថុបញ្ញើក៏ដោយ អ្នកផ្ញើអាចទាមទារឱ្យសងវត្ថុបញ្ញើនោះនៅពេលណាក៏បាន។ សិទ្ធិក្នុងការទាមទារឱ្យសងវិញចំពោះវត្ថុបញ្ញើ ដោយសារបញ្ញើត្រូវបានធ្វើឡើង ដើម្បីផលប្រយោជន៍របស់អ្នកផ្ញើ អ្នកទទួលបញ្ញើមិនមានផលប្រយោជន៍ផ្ទាល់ខ្លួនអ្វីក្នុងការបន្តបញ្ញើនោះទេ លើកលែងតែកម្រៃ ទោះបីជាកិច្ចសន្យាបញ្ញើបានកំណត់អំឡុងពេលណាក៏ដោយ ក៏អ្នកផ្ញើអាចទាមទារឱ្យសងវិញគ្រប់ពេលវេលាពេលណាក៏បាន[49]។

**១.២.សិទ្ធិទាមទារសំណងនៃការខូចខាត**

ក្នុងករណី ដែលអ្នកទទួលបញ្ញើពុំទទួលខុសត្រូវចំពោះការធ្វើឱ្យបាត់បង់ ឬបែកបាក់វត្ថុបញ្ញើទេ ប្រសិន បើអ្នកទទួលបញ្ញើបានទទួលប្រាក់ធានារ៉ាប់រង ឬវត្ថុផ្សេងទៀតជំនួសវត្ថុបញ្ញើ ដែលត្រូវបានធ្វើឱ្យបាត់បង់ ឬបែកបាក់នោះ អ្នកទទួលបញ្ញើមានករណីយកិច្ចត្រូវសងវត្ថុ ដែលបានធ្វើឧបាទេសកម្មនោះឱ្យទៅអ្នកផ្ញើវិញ។ ប្រសិនបើវត្ថុនោះត្រូវបានធ្វើឱ្យបាត់បង់ ឬបែកបាក់បណ្តាលមកពីកំហុសរបស់អ្នកទទួលបញ្ញើ អ្នកទទួលបញ្ញើនោះត្រូវទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាតទៅឱ្យអ្នកផ្ញើ ដោយសារបញ្ហានេះអាចត្រូវបានចេញពីគោលការណ៍ទូទៅទាក់ទងទៅនឹងការទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ច[50]។

**១.៣.សិទ្ធិទទួលបានការជូនដំណឹងពីអ្នកទទួលបញ្ញើ**

បើតតិយជន ដែលអះអាងអំពីសិទ្ធិចំពោះវត្ថុបញ្ញើបានដាក់ពាក្យបណ្តឹងចំពោះអ្នកទទួលបញ្ញើ ឬវត្ថុបញ្ញើត្រូវបានរឹបអូស អ្នកទទួលបញ្ញើត្រូវជូនដំណឹងអំពីហេតុនោះ ទៅឱ្យអ្នកផ្ញើដោយគ្មានការយឺតយ៉ាវ។ ក្នុងករណីអ្នកផ្ញើមានឱកាសការពារសិទ្ធិរបស់ខ្លួន តាមរយៈការជូនដំណឹងទៅអ្នកផ្ញើ ក្នុងករណីដែលតតិយជនបានអនុវត្តសិទ្ធិដោយអះអាងថា ខ្លួនមានកម្មសិទ្ធិលើវត្ថុបញ្ញើនោះ។ ប្រសិនបើអ្នកផ្ញើទទួលដំណឹងថា តតិយជន បានអនុវត្តសិទ្ធិ អ្នកផ្ញើអាចប្រមូលភស្តុតាងដែលបញ្ជាក់ថា កម្មសិទ្ធិរបស់អ្នកផ្ញើមានសុពលភាព ហើយត្រូវផ្តល់ភស្តុតាងនោះទៅអ្នកទទួលបញ្ញើ ដើម្បីឱ្យអ្នកទទួលបញ្ញើអាចធ្វើសកម្មភាពបណ្តឹងជាអាទិ៍ ដើម្បីផលប្រយោជន៍ដល់អ្នកទទួលបញ្ញើ[51]។

**២.ករណីយកិច្ចរបស់អ្នកផ្ញើ**

**២.១.ការបង់កម្រៃសេវាទៅឱ្យអ្នកទទួលបញ្ញើ**

អ្នកផ្ញើមានករណីកិច្ចបង់កម្រៃសេវាទៅឱ្យអ្នកទទួលបញ្ញើ។ កិច្ចសន្យាបញ្ញើដោយយកកម្រៃ បើទោះបីក្នុងករណីអ្នកទទួលបញ្ញើបានធ្វើកិច្ចសន្យានោះជាមួយអ្នកផ្ញើក្នុងនាមជាអាជីវកម្មរបស់ខ្លួន ឬប្រសិនបើមានកំណត់ក្នុងច្បាប់ ទោះបីជាពុំបានធ្វើកិច្ចសន្យាពិសេសចំពោះកម្រៃក៏ដោយ អ្នកទទួលបញ្ញើអាចទាមទារកម្រៃសមរម្យពីអ្នកផ្ញើបាន។

[49] មាត្រា ៦៨២ ២ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[50] មាត្រា ៦៨០ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[51] មាត្រា ៦៧៩ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

### ២.២.ការសងសំណងការខូចខាតទៅលើអ្នកទទួលបញ្ញើ

អ្នកផ្ញើចាំបាច់ត្រូវបង់សោហ៊ុយដែលចាំបាច់ ក្នុងការរក្សាទុកវត្ថុបញ្ញើ។ អ្នកទទួលបញ្ញើអាចទាមទារសំណងនៃការខូចខាត ដែលបណ្តាលមកពីវត្ថុបញ្ញើ ដោយមិនមែនជាកំហុសរបស់ខ្លួនពីអ្នកផ្ញើបាន។ ក្នុងករណីអ្នកទទួលបញ្ញើទទួលការខូចខាតដោយសារវត្ថុបញ្ញើ ដោយមិនមែនមកពីកំហុសរបស់អ្នកទទួលបញ្ញើ នោះវាជាការសមស្របដែលអ្នកផ្ញើត្រូវសងសំណងការខូចខាតនោះទៅអ្នកទទួលបញ្ញើ។

### ២.៣.ការរាយការណ៍អំពីប្រភេទ និងតម្លៃនៃវត្ថុបញ្ញើ

ករណីដែលអ្នកផ្ញើបានផ្ញើប្រាក់ឧបករណ៍អាចជួញដូរបាន និងវត្ថុដែលមានតម្លៃខ្ពស់ផ្សេងទៀត ប្រសិនបើអ្នកផ្ញើមិនបានរាយការណ៍អំពីប្រភេទ និងតម្លៃនោះ ទៅឱ្យអ្នកទទួលបញ្ញើ តុលាការអាចបន្ថយការទទួលខុសត្រូវលើការសងសំណងនៃការខូចខាតរបស់អ្នកទទួលបញ្ញើបាន។[8] ក្នុងករណីបញ្ញើ ជាវត្ថុដែលមានតម្លៃ អ្នកទទួលបញ្ញើនឹងធ្វើការរក្សាទុកដោយប្រុងប្រយ័ត្នពិសេស ដើម្បីកុំឱ្យមានការខូចខាត។ ផ្ទុយទៅវិញ ប្រសិនបើអ្នកទទួលបញ្ញើមិនបានដឹងថា វត្ថុបញ្ញើនោះជាវត្ថុដែលមានតម្លៃទេ អ្នកទទួលបញ្ញើអាចនឹងធ្វើការប្រុងប្រយ័ត្នធម្មតាតែប៉ុណ្ណោះ។ ប៉ុន្តែវាជារឿងអកុសលចំពោះការទទួលបញ្ញើ ហើយនៅពេលដែលខ្លួនទទួលនូវការទាមទារសំណងការខូចខាតដែលមានទំហំធំនៅក្រោយពេលដែលការខូចខាតបានកើតឡើងហើយនោះ។ លើសពីនេះទៅទៀត ដោយសារតែការរក្សាទុកនូវវត្ថុដែលមានតម្លៃ ទាមទារឱ្យមានការចំណាយច្រើនសន្ធឹកសន្ធាប់ដែរនោះ អ្នកទទួលបញ្ញើទាមទារកម្រៃសម្រាប់ការរក្សាទុកនោះលើសពីធម្មតា តែបើសិនអ្នកទទួលបញ្ញើមិនបានដឹងថា វត្ថុនោះមានតម្លៃខ្ពស់ អ្នកទទួលបញ្ញើមិនអាចធ្វើបែបនេះបាននោះទេ។

## កថាភាគទី៣. សិទ្ធិនិងករណីយកិច្ចរបស់អ្នកទទួលបញ្ញើ

### ១. សិទ្ធិរបស់អ្នកទទួលបញ្ញើ

អ្នកទទួលបញ្ញើ ជាអ្នកមើលថែរក្សានូវវត្ថុ និងត្រូវប្រគល់ជូនអ្នកផ្ញើវិញនៅពេលអ្នកផ្ញើមកទទួលយកបញ្ញើនោះវិញពិតមែន ប៉ុន្តែអ្នកទទួលបញ្ញើក៏មានសិទ្ធិមួយចំនួនផងដែរក្នុងការការពារខ្លួន និងជាប្រយោជន៍ផងដែរ។ អ្នកទទួលបញ្ញើ មានសិទ្ធិដូចជា សិទ្ធិទាមទារកម្រៃ សិទ្ធិសងវត្ថុបញ្ញើទីអ្នកផ្ញើ សិទ្ធិទាមទារសំណងនៃការខូចខាត និងសិទ្ធិឃាត់ទុកវត្ថុបញ្ញើជាដើម។

### ១.១.សិទ្ធិទាមទារកម្រៃពីអ្នកផ្ញើក្នុងការរក្សាទុកវត្ថុបញ្ញើ

អ្នកទទួលបញ្ញើមានសិទ្ធិទាមទារកម្រៃពីអ្នកផ្ញើតាមការព្រមព្រៀងរវាងអ្នកផ្ញើ និងអ្នកទទួលបញ្ញើក្នុងការរក្សាទុកវត្ថុបញ្ញើ។ ក្នុងកិច្ចសន្យាបញ្ញើដោយយកកម្រៃ បើទោះបីក្នុងករណីអ្នកទទួលបញ្ញើបានធ្វើកិច្ចសន្យានោះជាមួយអ្នកផ្ញើក្នុងនាមជាអាជីវកម្មរបស់ខ្លួន ឬប្រសិនបើមានកំណត់ក្នុងច្បាប់ ទោះបីជាពុំបានធ្វើកិច្ចសន្យាពិសេសចំពោះកម្រៃក៏ដោយ អ្នកទទួលបញ្ញើអាចទាមទារកម្រៃសមរម្យពីអ្នកផ្ញើបាន[52]។

---

[52] មាត្រា៦៧៣ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

**១.២.សិទ្ធិសងវត្ថុបញ្ញើពីអ្នកទទួលបញ្ញើ**

ក្នុងករណី ភាគីពុំបានកំណត់អំឡុងពេលនៃការសងវត្ថុបញ្ញើទេ អ្នកទទួលបញ្ញើអាចសងវត្ថុបញ្ញើនោះ នៅពេលណាក៏បាន។ ប្រសិនបើមានកំណត់អំឡុងពេលដែលត្រូវសង បើគ្មានមូលហេតុដែលពុំអាចជៀសវាងបានទេ អ្នកទទួលបញ្ញើមិនអាចសងវត្ថុបញ្ញើ នៅមុនពេលកំណត់បានឡើយ[53]។ នៅក្នុងកិច្ចសន្យាបញ្ញើ ពេលកំណត់ត្រូវសងត្រូវបានកំណត់ ដើម្បីប្រយោជន៍របស់អ្នកផ្ញើ អ្នកផ្ញើរំពឹងថាអ្នកទទួលបញ្ញើនឹងរក្សាទុកវត្ថុរហូតដល់ពេលត្រូវសង។ នៅពេលមានការកំណត់អំពីពេលត្រូវសងវត្ថុវិញ អ្នកទទួលបញ្ញើមិនអាចសងវត្ថុបញ្ញើនៅមុនពេលកំណត់បានទេ។ ប៉ុន្តែអ្នកទទួលបញ្ញើអាចសងវត្ថុបញ្ញើមុនពេលកំណត់បាន ប្រសិនបើមានមូលហេតុដែលមិនអាចជៀសវាងបាន ដូចជាការរក្សាទុកមិនអាចធ្វើទៅបាន ដោយសារការខូចខាតសម្ភារៈសម្រាប់កន្លែងផ្ញើជាដើម។ ប្រសិនបើពេលសម្រាប់សងមិនត្រូវបានកំណត់ទេ វាមិនច្បាស់ទេថា អ្នកផ្ញើចង់ឱ្យអ្នកទទួលបញ្ញើរក្សាទុកវត្ថុបញ្ញើរហូតដល់ពេលណានោះទេ។

**១.៣.សិទ្ធិទាមទារសំណងនៃការខូចខាត**

អ្នកទទួលបញ្ញើ អាចទាមទារសំណងនៃការខូចខាតបណ្តាលមកពីវត្ថុបញ្ញើ ដែលមិនមែនជាកំហុសរបស់ខ្លួនពីអ្នកផ្ញើបាន។ ប្រសិនបើអ្នកទទួលបញ្ញើទទួលការខូចខាតដោយសារវត្ថុបញ្ញើ ដែលមិនមែនមកពីកំហុសរបស់អ្នកទទួលបញ្ញើ វាជាការសមស្របនឹងសមភាពដែលអ្នកផ្ញើត្រូវសងសំណងការខូចខាតនោះទៅអ្នកទទួលបញ្ញើ។ ឧទាហរណ៍៖ ប្រសិនបើទ្រព្យសម្បត្តិរបស់អ្នកទទួលបញ្ញើត្រូវបានបំផ្លិចបំផ្លាញដោយសារតែការផ្ទុះវត្ថុបញ្ញើ អ្នកផ្ញើត្រូវទទួលបន្ទុកនូវការខូចខាតនោះ។ អ្នកផ្ញើត្រូវបង់សោហ៊ុយ ឬសងសំណងនៃការខូចខាតនៅពេលដែលសោហ៊ុយ ឬការខូចខាតនោះកើតឡើង។

**១.៤.សិទ្ធិឃាត់ទុកវត្ថុបញ្ញើ**

អ្នកទទួលបញ្ញើអាចឃាត់ទុកវត្ថុបញ្ញើ រហូតដល់ពេល ដែលអ្នកផ្ញើបានបង់សោហ៊ុយ និងសំណងនៃការខូចខាត។ នៅក្នុងមាត្រា ៦៨៦ បានចែងថា អ្នកផ្ញើចាំបាច់ត្រូវបង់សោហ៊ុយដែលចាំបាច់ក្នុងការរក្សាទុកវត្ថុបញ្ញើ ហើយអ្នកទទួលបញ្ញើអាចទាមទារសំណងនៃការខូចខាត ដែលបណ្តាលមកពីវត្ថុបញ្ញើ ដោយមិនមែនជាកំហុសរបស់ខ្លួនពីអ្នកផ្ញើបាន។ សិទ្ធិឃាត់ទុកកើតឡើងចំពោះសិទ្ធិទាមទារឱ្យសងសោហ៊ុយ និងសិទ្ធិទាមទារសំណងការខូចខាតរបស់អ្នកទទួលបញ្ញើ ប៉ុន្តែមាត្រានេះត្រូវបានដាក់បញ្ចូលនៅទីនេះ ដើម្បីបញ្ជាក់ឱ្យកាន់តែច្បាស់ថែមទៀត ក្នុងករណីនៃបញ្ញើ សិទ្ធិឃាត់ទុកតែងតែកើតឡើងជាទម្លាប់ ដោយសារលក្ខណៈនៃកិច្ចសន្យា។

**២. ករណីយកិច្ចអ្នកទទួលបញ្ញើ**

**២.១.រក្សាទុកវត្ថុបញ្ញើ**

ករណីយកិច្ចរបស់អ្នកទទួលបញ្ញើ គឺត្រូវរក្សាទុកវត្ថុបញ្ញើ ដោយព្យាយាមប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត។ បើគ្មានការយល់ព្រមពីអ្នកផ្ញើទេ អ្នកទទួលបញ្ញើមិនអាចប្រើវត្ថុបញ្ញើបានឡើយ។

[53] មាត្រា ៦៧៩ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

**២.២.ករណីយកិច្ចក្នុងការជូនដំណឹងរបស់អ្នកទទួលបញ្ញើ**

អ្នកទទួលបញ្ញើមានករណីយកិច្ចជូនដំណឹងទៅអ្នកផ្ញើ ប្រសិនបើតតិយជន ដែលអះអាងអំពីសិទ្ធិចំពោះវត្ថុបញ្ញើបានដាក់ពាក្យបណ្តឹងចំពោះអ្នកទទួលបញ្ញើ ឬវត្ថុបញ្ញើត្រូវបានរឹបអូស អ្នកទទួលបញ្ញើត្រូវជូនដំណឹង អំពីហេតុនោះ ទៅឱ្យអ្នកផ្ញើ ដោយគ្មានការយឺតយ៉ាវ [54]។ អ្នកផ្ញើមានឱកាសការពារសិទ្ធិរបស់ខ្លួន ក្នុងករណីតតិយជនអនុវត្តសិទ្ធិដោយអះអាងថា ខ្លួនមានកម្មសិទ្ធិលើវត្ថុបញ្ញើនោះ។ ប្រសិនបើអ្នកផ្ញើទទួលដំណឹងថា តតិយជនបានអនុវត្តសិទ្ធិ អ្នកផ្ញើអាចប្រមូលភស្តុតាង ដែលបញ្ជាក់ថា កម្មសិទ្ធិរបស់អ្នកផ្ញើមានសុពលភាព ហើយផ្តល់ភស្តុតាងនោះ ទៅអ្នកទទួលបញ្ញើ ដើម្បីឱ្យអ្នកទទួលបញ្ញើអាចធ្វើសកម្មភាពបណ្តឹងជាអាទិ៍ ដើម្បីផលប្រយោជន៍ដល់អ្នកទទួលបញ្ញើ ។

**២.៣.សងសំណងខូចខាតនៅលើវត្ថុបញ្ញើ**

អ្នកទទួលបញ្ញើមានករណីយកិច្ចទទួលខុសត្រូវ ក្នុងករណីដែលបានធ្វើឱ្យបាត់បង់ ឬបានធ្វើឱ្យបែកបាក់វត្ថុបញ្ញើនោះ អ្នកទទួលបញ្ញើត្រូវសងសំណងនៃការខូចខាតនោះ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ បើអ្នកទទួលបញ្ញើបានបញ្ជាក់អំពីការគ្មានកំហុស ចំពោះការធ្វើឱ្យ បាត់បង់ ឬបែកបាក់នោះ។ ក្នុងករណីដែលបញ្ញើត្រូវបានធ្វើឡើងតាមការទាមទាររបស់អ្នកទទួលបញ្ញើ ប្រសិនបើគ្មានការបញ្ជាក់ថា ជាករណីប្រធានសក្តិទេ អ្នកទទួលបញ្ញើមិនអាចរួចផុតពីការទទួលខុសត្រូវចំពោះការធ្វើឱ្យ បាត់បង់ ឬបែកបាក់បានឡើយ។ នៅទីកន្លែងដូចជា សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន កន្លែងងូតទឹក សិល្បៈការផ្សេងទៀត ដែលមានភ្ញៀវជួបជុំ ប្រសិនបើកម្មសិទ្ធិករនៃសិល្បៈការទាំងឡាយនោះបានទទួលវត្ថុបញ្ញើពីភ្ញៀវ ប្រសិនបើគ្មានការបញ្ជាក់ថាជាករណីប្រធានសក្តិទេ។

**២.៤.សងវត្ថុបញ្ញើ**

អ្នកទទួលបញ្ញើ មានករណីយកិច្ចសងវត្ថុដដែល ដែលបានទទួលនៅពេលធ្វើបញ្ញើ។ អ្នកទទួលបញ្ញើពុំទទួលខុសត្រូវចំពោះការធ្វើឱ្យបាត់បង់ ឬបែកបាក់វត្ថុបញ្ញើទេ ប្រសិនបើអ្នកទទួលបញ្ញើបានទទួលប្រាក់ធានារ៉ាប់រង ឬវត្ថុផ្សេងទៀតជំនួសវត្ថុបញ្ញើ ដែលត្រូវបានធ្វើឱ្យបាត់បង់ ឬបែកបាក់នោះ អ្នកទទួលបញ្ញើមានករណីយកិច្ចត្រូវសងវត្ថុដែលបានធ្វើឧបាទេសកម្មនោះឱ្យទៅអ្នកផ្ញើវិញ [55]។

ប្រសិនបើវត្ថុនោះត្រូវបានធ្វើឱ្យបាត់បង់ ឬបែកបាក់ បណ្តាលមកពីកំហុសរបស់អ្នកទទួលបញ្ញើ អ្នកទទួលបញ្ញើនោះ ត្រូវទទួលខុសត្រូវក្នុងការសងនូវសំណងនៃការខូចខាតទៅឱ្យអ្នកផ្ញើ។ ដោយសារបញ្ហានេះអាចត្រូវបានចេញពីគោលការណ៍ទូទៅទាក់ទងទៅនឹងការទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ច។ មាត្រានេះមិនបានចែងអំពីចំណុចនេះឡើយ។ ប្រសិនបើអ្នកទទួលបញ្ញើគ្មានកំហុសចំពោះការបាត់បង់ ឬការបែកបាក់វត្ថុទេ អ្នកទទួលបញ្ញើអាចសងទៅវិញនូវវត្ថុតាមភាពជាក់ស្តែង (ប្រសិនបើវត្ថុត្រូវបានធ្វើឱ្យខូចខាត អ្នកទទួលបញ្ញើអាចសងវត្ថុ ដែលខូចខាតនោះ ប៉ុន្តែប្រសិនបើអ្នកទទួលបញ្ញើបានទទួលនូវវត្ថុជំនួសវត្ថុ ដែលបាត់បង់ ឬ បែកបាក់ អ្នកទទួលបញ្ញើត្រូវ

[54] មាត្រា៦៧៤ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[55] មាត្រា៦៨២ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

តែប្រគល់នូវវត្ថុជំនួសនោះទៅឱ្យអ្នកផ្ញើ។ ឧទាហរណ៍៖ ប្រសិនបើអ្នកទទួលបញ្ញើបានទទួលប្រាក់ធានារ៉ាប់រង អ្នកទទួលបញ្ញើត្រូវប្រគល់ប្រាក់ធានារ៉ាប់រងនោះទៅឱ្យអ្នកផ្ញើ។

**កថាភាគទី៤.ការរួចផុតពីការទទួលខុសត្រូវរបស់អ្នកទទួលបញ្ញើយកកម្រៃ**

ក្នុងករណីដែលបានសន្យាបង្កើត កិច្ចសន្យាបញ្ញើដោយឱ្យ បង់ថ្លៃវិញ ប្រសិនបើបានធ្វើឱ្យខូចខាតដល់ភាគីម្ខាងទៀត ដោយសារការបដិសេធមិនទទួលវត្ថុបញ្ញើផ្ទុយនឹងការសន្យានោះ ភាគីដែលជាអ្នកទទួលបញ្ញើ មានករណីយកិច្ចត្រូវសងសំណងនៃការខូចខាតនោះ ឱ្យទៅភាគីម្ខាងទៀត ប្រសិនបើការ បដិសេធនោះ គ្មានមូលហេតុត្រឹមត្រូវទេ[56]។ ប៉ុន្តែក្នុងករណីដែលបញ្ញើត្រូវបានធ្វើឡើង តាមការទាមទាររបស់អ្នកទទួលបញ្ញើ ប្រសិនបើមានការបញ្ជាក់ថាជាករណីប្រធានសក្តិ នោះអ្នកទទួលបញ្ញើអាចរួចផុតពីការទទួលខុសត្រូវបាន។

**ឧទាហរណ៍ទី១៖** លោក "ក" យកម៉ូតូទៅផ្ញើនៅផ្ទះរបស់ "ខ" ដោយបញ្ញើមិនយកកម្រៃ។ បន្ទាប់មកដោយអាកាសធាតុមានការប្រែប្រួលមានខ្យល់កន្ត្រាក់ ដែលបណ្តាលឱ្យផ្ទះរបស់ "ខ" រលំសង្កត់ម៉ូតូរបស់ "ក" មានការខូចខាតយ៉ាងខ្លាំង។ ក្នុងករណីនេះ "ខ" អាចលើកឡើងពីករណីប្រធានសក្តិ ដើម្បីអាចរួចផុតពីការទទួលខុសត្រូវនោះបាន។

**ផ្នែកទី២. កិច្ចសន្យាបញ្ញើមិនយកកម្រៃ**

កិច្ចសន្យាបញ្ញើដោយមិនយកកម្រៃ ជាប្រភេទនៃកិច្ចសន្យាបញ្ញើធម្មតា ដែលធ្វើឡើងរវាង អ្នកផ្ញើ និងអ្នកទទួលបញ្ញើ ដែលតាមរយៈកិច្ចសន្យានេះ អ្នកទទួលបញ្ញើយល់ព្រមដោយស្ម័គ្រចិត្តទទួលយកវត្ថុ បញ្ញើមករក្សាទុកដោយមិនយកកម្រៃ ក្នុងអំឡុងពេលមួយកំណត់ ឬមិនកំណត់ ហើយត្រូវសងវត្ថុបញ្ញើនោះទៅអ្នកផ្ញើវិញ នៅពេលមានការទាមទារឱ្យសងពីអ្នកផ្ញើ ឬពេលកំណត់សងបានមកដល់[57]។

**ឧទាហរណ៍៖** ករណីការជួយដោយស្ម័គ្រចិត្តរវាងមិត្តភក្តិ X នឹងទៅសិក្សានៅបរទេសរយៈពេល ១ ឆ្នាំ។ ក្នុងអំឡុងពេល១ ឆ្នាំនេះ X ត្រូវការកន្លែងមួយដើម្បីទុកវ៉ាលីទាំង ៣ របស់គាត់។ ដូច្នេះ X បានផ្ញើវាជាមួយ Y ដែលជាមិត្តភក្តិរបស់ X ដោយមិនគិតថ្លៃ។

គោលការណ៍មិនយកកម្រៃ នៅក្នុងស្ថានភាពជាក់ស្តែង វត្ថុមួយចំនួនត្រូវបានគេរក្សាទុកដោយមិនយកកម្រៃដូចជាការថែរក្សាឥវ៉ាន់ឱ្យមានសុវត្ថិភាពនៅសារៈមន្ទីរ ឬនៅសណ្ឋាគារជាអាទិ៍។ ហេតុនេះ ជាគោលការណ៍ បញ្ញើ គឺមិនគិតកម្រៃ ហើយចំពោះបញ្ញើដោយឱ្យបង់កម្រៃវិញត្រូវតែមានការសន្យាពិសេស ប៉ុន្តែនៅពេលដែលអ្នកទទួលបញ្ញើទទួលនូវការផ្ញើក្នុងនាមអាជីវកម្មរបស់ខ្លួន ជាគោលការណ៍ បញ្ញើនោះត្រូវសន្មតថា បញ្ញើដែលអ្នកទទួលបញ្ញើបានទទួលនូវការផ្ញើក្នុងនាមអាជីវកម្មរបស់ខ្លួន គឺជាបញ្ញើ ដែលអ្នកទទួលបញ្ញើនោះ ទទួលម្តងហើយម្តងទៀតពីបុគ្គលផ្សេងៗ ដោយទទួលបានផលចំណេញ ដូចជាអាជីវកម្ម ឃ្លាំងស្តុកទំនិញ គឺជាបញ្ញើសម្រាប់អាជីវកម្ម ប៉ុន្តែការថែរក្សា

[56] មាត្រា៦៧១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[57] មេរៀនសង្ខេបរបស់លោកសាស្ត្រាចារ្យ មេធាវី អ៊ីវ ប៉ូលីឆ្នាំ២០១១។

ទុកអីវ៉ាន់នៅសណ្ឋាគារឱ្យមានសុវត្ថិភាព មិនមែនជាបញ្ញើសម្រាប់អាជីវកម្មនោះទេ ពីព្រោះសណ្ឋាគារមិនបានទទួលផលចំណេញពីបញ្ញើនោះឡើយ[58]។

**កថាភាគទី១. លក្ខណៈកិច្ចសន្យាបញ្ញើដោយមិនយកកម្រៃ**

កិច្ចសន្យាបញ្ញើមិនយកម្រៃមានលក្ខណៈជាកិច្ចសន្យាមុធា។ កិច្ចសន្យាមុធា ជាកិច្ចសន្យាដែលមានតែភាគីម្ខាងនៃកិច្ចសន្យាដែលមានកាតព្វកិច្ចផ្តល់តាវកាលិក ហើយភាគីម្ខាងទៀតពុំមានកាតព្វកិច្ចផ្តល់តាវកាលិកដែលមានខ្លឹមសារជាតម្លៃថ្នូរនោះទេ។ នៅក្នុងកិច្ចសន្យាបញ្ញើមិនយកកម្រៃមានន័យថា អ្នកផ្ញើមិនមានកាតព្វកិច្ចបង់កម្រៃទៅឱ្យអ្នកទទួលបញ្ញើ តែអ្នកទទួលបញ្ញើមានកាតព្វកិច្ចថែរក្សានូវវត្ថុបញ្ញើ។ បើគ្មានកិច្ចសន្យាពិសេស អ្នកផ្ញើពុំមានករណីយកិច្ចបង់កម្រៃឱ្យអ្នកទទួលបញ្ញើឡើយ[59]។

**កថាភាគទី២.សិទ្ធិនិងករណីយកិច្ចរបស់អ្នកផ្ញើ**

ក្នុងករណីប្រធានសក្តិ ក៏អ្នកទទួលបញ្ញើមិនអាចរួចផុតពីការទទួលខុសត្រូវបានដែរ។ ការបន្ថយការទទួលខុសត្រូវរបស់អ្នកទទួលបញ្ញើដោយមិនយកកម្រៃ នៅក្នុងបញ្ញើដោយមិនយកកម្រៃ តុលាការអាចបន្ថយការទទួលខុសត្រូវលើការសងសំណងការខូចខាតរបស់អ្នកផ្ញើ ដោយពិចារណាទៅលើស្ថានភាពនៃទ្រព្យសម្បត្តិភាគីទាំងសងខាង និងកាលៈទេសៈផ្សេងៗទៀតបាន[60]។ អ្នកទទួលបញ្ញើដោយមិនយកកម្រៃមានករណីយកិច្ចប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិតផងដែរ។

**ឧទាហរណ៍ទី២៖** "ក" យកម៉ូតូទៅផ្ញើនឹង "ខ" ដោយបញ្ញើមិនយកកម្រៃ។ បន្ទាប់មក "ខ" បានទទួលយកម៉ូតូនោះមករក្សាទុក។ ប្រសិនអ្នកទទួលបញ្ញើមានភស្តុតាងបញ្ជាក់ថា ខ្លួនមានការប្រុងប្រយ័ត្នដែរ ក្នុងការរក្សាបញ្ញើនោះដោយរក្សាទុកយ៉ាងប្រុងប្រយត្ន័ ប៉ុន្តែនៅតែចោរអាចលួចយកបានមិនត្រឹមតែលួចយកម៉ូតូរបស់ "ក" ទេ សូម្បីតែម៉ូតូរបស់ "ខ" ក៏ចោរលួចដែរ។ ក្នុងករណីនេះ "ខ" មិនអាចរួចផុតពីការទទួលខុសត្រូវបាន ទោះបី "ខ" បានរក្សាទុក យ៉ាងប្រុងប្រយ័ត្នហើយ ប៉ុន្តែចោរនៅតែអាចគាស់យកបានក៏ដោយ។ ផ្ទុយទៅវិញ បើអ្នកផ្ញើបានផ្ញើប្រាក់ ឧបករណ៍អាចជួញដូរបាន និងវត្ថុដែលមានតម្លៃខ្ពស់ផ្សេងទៀត ប្រសិនបើអ្នកផ្ញើ មិនបានរាយការណ៍អំពីប្រភេទ និងតម្លៃនោះទៅឱ្យអ្នកទទួលបញ្ញើទេ តុលាការអាចបន្ថយការទទួលខុសត្រូវសងសំណងនៃការខូចខាតរបស់អ្នកទទួលបញ្ញើបាន។

**១.សិទ្ធិរបស់អ្នកផ្ញើ**

អ្នកផ្ញើមានសិទ្ធិដូចជា សិទ្ធិទាមទារឱ្យសងវត្ថុបញ្ញើ សិទ្ធិទាមទារដកហូតការព្រមព្រៀងចំពោះទំនាក់ទំនងបញ្ញើនាពេលអនាគត និងសិទ្ធិក្នុងការទាមទារសំណងនៃការខូចខាត។

---

[58] មេរៀនសង្ខេបរបស់លោកសាស្ត្រាចារ្យ មេធាវី អ៊ីវ ប៉ូលីឆ្នាំ២០១១។

[59] មាត្រា៦៦៩ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[60] មាត្រា៦៧៥ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

**១.១.សិទ្ធិទាមទារឱ្យសងវត្ថុបញ្ញើ**

អ្នកផ្ញើមានសិទ្ធិទាមទារវត្ថុឱ្យអ្នកទទួលបញ្ញើសងវត្ថុបញ្ញើ ទោះបីជាកិច្ចសន្យាបញ្ញើមានកំណត់អំឡុងពេលក៏ដោយ ក៏អ្នកផ្ញើអាចទាមទារឱ្យសងវិញនៅពេលណាក៏បាន[61]។

**១.២.សិទ្ធិដកហូតការព្រមព្រៀងចំពោះទំនាក់ទំនងបញ្ញើនាពេលអនាគត**

ក្នុងករណីភាគី គ្រាន់តែបានព្រមព្រៀងថានឹងបង្កើតទំនាក់ទំនងបញ្ញើនាពេលអនាគត ភាគីនីមួយៗអាចដកការព្រមព្រៀងនោះចេញនៅពេលណាក៏បាន រហូតដល់ពេលដែលបានប្រគល់កម្មវត្ថុនៃបញ្ញើនោះ[62]។

**១.៣.សិទ្ធិទាមទារសំណង**

អ្នកផ្ញើមានសិទ្ធិទាមទារសំណងពីអ្នកទទួលបញ្ញើ ក្នុងករណីអ្នកទទួលបញ្ញើបានធ្វើឱ្យបាត់បង់ ឬបានធ្វើឱ្យបែកបាក់វត្ថុបញ្ញើនោះ[63]។ អំពីការទទួលខុសត្រូវរបស់ អ្នកទទួលបញ្ញើ ក្នុងករណីដែលអ្នកទទួលបញ្ញើបានធ្វើឱ្យខូចខាតដល់វត្ថុបញ្ញើ ដោយការបំពានករណីយកិច្ចរបស់ខ្លួន។ ការទទួលខុសត្រូវរបស់អ្នកទទួលបញ្ញើក្នុងការសងសំណងការខូចខាត គឺជាការទទួលខុសដោយមានកំហុស។

**២. ករណីយកិច្ចរបស់អ្នកផ្ញើ**

អ្នកផ្ញើមានករណីយកិច្ច សងសោហ៊ុយដល់អ្នកទទួលបញ្ញើនៅពេលដែលទទួលបាននូវវត្ថុបញ្ញើនោះមកគ្រប់គ្រងវិញ។

**២.១.សោហ៊ុយនៃការរក្សាទុកវត្ថុបញ្ញើ**

នៅក្នុងកិច្ចសន្យាបញ្ញើដោយមិនយកកម្រៃ សោហ៊ុយចាំបាច់នៃការសងវត្ថុបញ្ញើត្រូវតែជាបន្ទុករបស់អ្នកផ្ញើ[64]។ ប៉ុន្តែក្នុងករណី ដែលអ្នកទទួលបញ្ញើបានផ្លាស់ប្តូរកន្លែងធ្វើសោហ៊ុយនៃការសងវត្ថុបញ្ញើ ដែលកើតឡើងដោយសារការផ្លាស់ប្តូរកន្លែងនោះត្រូវជាបន្ទុករបស់អ្នកទទួលបញ្ញើ។ សោហ៊ុយសម្រាប់ការសង គឺជាបន្ទុករបស់កូនបំណុល ដែលមានក្នុងមាត្រា៤៨៦។ ក្នុងករណីបញ្ញើដោយមិនយកកម្រៃមិនមានភាពសមរម្យទេ ប្រសិនបើអ្នកទទួលបញ្ញើ ដែលជាកូនបំណុលចំពោះកាតព្វកិច្ចសងវិញនូវវត្ថុបញ្ញើត្រូវទទួលបន្ទុកលើសោហ៊ុយ។

**២.២.ការសងសោហ៊ុយវិញ**

អ្នកផ្ញើចាំបាច់ត្រូវបង់សោហ៊ុយដែលចាំបាច់ ក្នុងការរក្សាទុកវត្ថុបញ្ញើ[65]។ សូម្បីបញ្ញើមិនយកកម្រៃ សោហ៊ុយសម្រាប់ការរក្សាទុកវត្ថុបញ្ញើ ក៏ត្រូវតែជាបន្ទុករបស់អ្នកផ្ញើដែរ ពីព្រោះបញ្ញើមិនយកកម្រៃ មានន័យថា មិនបានបង់នូវលាភសក្ការៈទៅអ្នកទទួលបញ្ញើ ដូច្នេះកម្រៃមិនពាក់ព័ន្ធជាមួយសោហ៊ុយចំណាយជាក់ស្តែងសម្រាប់ការរក្សាទុកទេ។ ប្រសិនបើអ្នកទទួលបញ្ញើរក្សាទុកវត្ថុដោយការក្លាសេនោះ អ្នកទទួលបញ្ញើអាចទាមទារថ្លៃអគ្គិសនីជាអាទិ៍ ពីអ្នកផ្ញើបាន សូម្បីតែក្នុងករណីជាបញ្ញើដោយមិនយកកម្រៃក៏ដោយ។

---

[61] មាត្រា៦៨០ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[62] មាត្រា៦៦៧ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[63] មាត្រា៦៧៤ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[64] មាត្រា៦៨៥ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[65] មាត្រា៦៨៦, ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

## កថាភាគទី៣. សិទ្ធិ និងករណីយកិច្ចរបស់អ្នកទទួលបញ្ញើ

### ១.សិទ្ធិរបស់អ្នកទទួលបញ្ញើ

នៅក្នុងកិច្ចសន្យាបញ្ញើមិនយកកម្រៃអ្នកទទួលបញ្ញើមានសិទ្ធិឃាត់ទុកវត្ថុបញ្ញើ រហូតដល់ពេលដែលអ្នកផ្ញើបានបង់សោហ៊ុយ និងសំណងនៃការខូចខាត ដែលនេះជាសិទ្ធិឃាត់ទុករបស់អ្នកទទួលបញ្ញើកើតចេញពី សោហ៊ុយ និងសំណងនៃការខូចខាតរបស់អ្នកទទួលបញ្ញើ[66]។

### ២.ករណីយកិច្ចរបស់អ្នកទទួលបញ្ញើ

#### ២.១.ថែរក្សាវត្ថុបញ្ញើ

អ្នកទទួលបញ្ញើមានករណីយកិច្ចរក្សាទុកវត្ថុបញ្ញើរបស់អ្នកផ្ញើ ដោយព្យាយាមប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត បើគ្មានការយល់ព្រមពីអ្នកផ្ញើទេ អ្នកទទួលបញ្ញើមិនអាចប្រើប្រាស់វត្ថុបញ្ញើនោះបានឡើយ[67]។

#### ២.២.ករណីយកិច្ចក្នុងការជូនដំណឹងមុន

អ្នកទទួលបញ្ញើមានករណីយកិច្ចជូនដំណឹងទៅអ្នកផ្ញើ ក្នុងករណីតតិយជនអះអាងអំពីសិទ្ធិចំពោះវត្ថុបញ្ញើបានដាក់ពាក់បណ្ដឹងចំពោះអ្នកទទួលបញ្ញើ ឬវត្ថុបញ្ញើត្រូវបានរឹបអូស[68]។ ប្រសិនបើអ្នកផ្ញើទទួលដំណឹងថា តតិយជនបានអនុវត្តសិទ្ធិ អ្នកផ្ញើអាចប្រមូលភស្តុតាងដែលបញ្ជាក់ថា កម្មសិទ្ធិរបស់អ្នកផ្ញើមានសុពលភាព ហើយផ្ដល់ភស្តុតាងទៅអ្នកទទួលបញ្ញើ ដើម្បីឱ្យអ្នកទទួលបញ្ញើអាចធ្វើសកម្មភាពបណ្ដឹងជាអាទិ៍ ដើម្បីផលប្រយោជន៍ដល់អ្នកទទួលបញ្ញើ។

#### ២.៣.ករណីសងវត្ថុបញ្ញើ

នៅក្នុងកិច្ចសន្យាបញ្ញើ បើបានព្រមព្រៀងឱ្យអ្នកទទួលបញ្ញើអាចបរិភោគវត្ថុបញ្ញើបាន អ្នកទទួលបញ្ញើមានករណីយកិច្ចសងវត្ថុបញ្ញើ ដែលមានប្រភេទ និងចំនួនដូចគ្នានឹងវត្ថុបញ្ញើនោះ។[69] ក្នុងករណីបញ្ញើធម្មតា អ្នកទទួលបញ្ញើរក្សាវត្ថុបញ្ញើ ដែលខ្លួនបានទទួលពីអ្នកផ្ញើ ហើយសងនូវវត្ថុដដែលនោះ នៅពេលកំណត់សង រីឯក្នុងករណីបញ្ញើបរិភោគវិញ អ្នកទទួលបញ្ញើអាចបរិភោគវត្ថុ ដែលត្រូវបានផ្ញើនោះ ហើយនៅពេលកំណត់សង អ្នកទទួលបញ្ញើអាចយកវត្ថុបញ្ញើ ដែលមានប្រភេទដូចគ្នាមកសងវិញបាន។

#### ២.៤.រក្សាវត្ថុបញ្ញើដោយខ្លួនឯង

បើគ្មានការយល់ព្រមពីអ្នកផ្ញើទេ អ្នកទទួលបញ្ញើពុំអាចឱ្យតតិយជនរក្សាទុកវត្ថុបញ្ញើបានឡើយ [70]។ ករណីយកិច្ចរបស់អ្នកទទួលបញ្ញើក្នុងការរក្សាទុកវត្ថុបញ្ញើដោយខ្លួនឯងផ្ទាល់។ ជាគោលការណ៍ អ្នកទទួលបញ្ញើពុំអាចឱ្យតតិយជនរក្សាទុកវត្ថុបញ្ញើបន្តបានឡើយ។ ទោះបីជាអ្នកទទួលបញ្ញើគ្រាន់តែប្រតិបត្តិការរក្សាទុកនូវវត្ថុបញ្ញើស្នើសុំក៏ដោយ ក៏អ្នកផ្ញើបានពិចារណាអំពីជំនាញ និងលក្ខខណ្ឌដទៃផ្សេងទៀតរបស់អ្នកទទួលបញ្ញើ នៅពេល

---

[66] មាត្រា៦៨៨, ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[67] មាត្រា៦៧៣, ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[68] មាត្រា៦៧៩, ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[69] មាត្រា៦៩០, ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[70] មាត្រា៦៧៧, ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

សម្រេចផ្ញើវត្ថុនោះដែរ ហេតុដូច្នេះមិនមានភាពសមរម្យទេ ដែលអ្នកទទួលបញ្ញើនោះផ្ទុកផ្តាក់ផ្ញើបន្តនូវវត្ថុបញ្ញើទៅតតិយជនដោយសេរី ។

### ២.៥.ការសងសំណងខូចខាត

អ្នកទទួលបញ្ញើមានករណីយកិច្ចសងសំណងខូចខាត ក្នុងករណីអ្នកទទួលបញ្ញើបានធ្វើឱ្យបាត់បង់ ឬបានធ្វើឱ្យបែកបាក់វត្ថុបញ្ញើនោះ។[71] ការទទួលខុសត្រូវរបស់អ្នកទទួលបញ្ញើ ក្នុងការសងសំណងការខូចខាត គឺជាការទទួលខុសដោយមានកំហុស ប៉ុន្តែបើគ្មានកំហុស អ្នកទទួលបញ្ញើមិនមានករណីយកិច្ចសងសំណងនៃការខូចខាតឡើយ។

## ផ្នែកទី៣. ករណីសិក្សាអំពីបញ្ញើ

ការសិក្សាទៅលើទ្រឹស្តីពិតជាមានសារៈសំខាន់ណាស់ ដើម្បីយកទ្រឹស្តីច្បាប់នោះទៅអនុវត្តនៅក្នុងស្ថានភាពជាក់ស្តែង ដែលបានកើតមានឡើងក្នុងសង្គមរស់នៅប្រចាំថ្ងៃ។ ការសិក្សាទៅលើទ្រឹស្តីតែមួយមុខ អ្នកសិក្សាស្រាវជ្រាវអាចមានការពិបាកក្នុងការស្វែងយល់ឱ្យបានស៊ីជម្រៅ ដូច្នេះហើយនៅក្នុងជំពូកនេះ យើងខ្ញុំនឹងរំលេចនូវអង្គហេតុបានកើតឡើងក្នុងកិច្ចសន្យាបញ្ញើសម្រាប់ធ្វើជាករណីសិក្សាជាក់ស្តែង និងបង្ហាញនូវតថភាពមួយចំនួនក្នុងកិច្ចសន្យាបញ្ញើជាមួយនឹងទិដ្ឋភាពច្បាប់របស់កម្ពុជាយើងបច្ចុប្បន្ន។

នៅក្នុងជំពូកនេះ យើងនឹងបានសិក្សាទៅលើករណីសិក្សាចំនួន ០២ សម្រាប់យកជាមូលដ្ឋានក្នុងការពិចារណាអំពីកិច្ចគតិយុត្តក្នុងបញ្ហានៃកិច្ចសន្យាបញ្ញើ។ ជាបន្តទៅទៀត សូមលើកឡើងនូវករណីសិក្សាទាំងនោះដូចតទៅ។

### កថាភាគទី១. ករណីសិក្សាទី១

**អង្គហេតុ**

នារីម្នាក់ បានជួលផ្ទះស្នាក់នៅមួយកន្លែង ដែលមានទីតាំងចតឡានតូចចង្អៀតមិនអាចចតឡានក្នុងផ្ទះបាន។ ក្រោយពីបានចតឡានក្រៅផ្ទះយូរៗទៅ ក៏បានលេចឮដំណឹងថា ចោរតែងតែកាច់កញ្ចក់ឡាន គ្រឿងឡាន ឬបាត់ឡានជាញឹកញាប់។ ក្រោយមក នាងក៏សម្រេចចិត្តផ្ញើឡាននៅកន្លែងផ្ញើឡានមួយកន្លែង ដែលទីតាំងនោះជាផ្ទះមួយ ដែលមានរបងបិទជិត និងមានមនុស្សយាមកាម ដើម្បីឡានចេញចូល ហើយមានសំបុត្របញ្ជាក់អំពីការផ្ញើរថយន្តត្រឹមត្រូវ។ ការផ្ញើរថយន្តនេះ មានរយៈពេលកំណត់១ខែ ដោយមានគិតថ្លៃឈ្នួល២៥$ ហើយអ្នកផ្ញើត្រូវប្រគល់សោរទៅអ្នកទទួលបញ្ញើ ដើម្បីគ្រប់គ្រង។ នៅថ្ងៃមួយ អ្នកទទួលបញ្ញើបានយកឡានរបស់នារីនោះ ទៅជិះដោយមិនមានការអនុញ្ញាត បណ្តាលឱ្យប៉ះនឹងជញ្ជាំងផ្ទះគេ។ ឡានត្រូវបានខូចខាតជាច្រើនកន្លែង និងជួសជុលអស់ថវិកាច្រើនផងដែរ។

**កំណែលំហាត់អនុវត្ត**

នារីម្នាក់ បានជួលផ្ទះស្នាក់នៅមួយកន្លែង ដែលមានទីតាំងក្នុងការចតឡានតូចចង្អៀត និងមិនអាចចតឡានក្នុងផ្ទះបាន។ ដោយលេចឮដំណឹងបាត់ឡានជាញឹកញាប់ នាងក៏សម្រេចយកឡានទៅផ្ញើ។ ក្រោយពីបានផ្ញើឡាន

[71] មាត្រា៦៧៤ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

មួយរយៈមក អ្នកទទួលផ្ញើបានយកឡាននាងទៅជិះ ហើយបានបើកទៅប៉ះនឹងជញ្ជាំងផ្ទះ បណ្តាលឱ្យមានការខូចខាតជាច្រើនកន្លែង និងជួសជុលអស់ថវិកាច្រើនផងដែរ។

តើអ្នកទទួលបញ្ញើត្រូវទទួលខុសត្រូវយ៉ាងដូចម្តេច ដើម្បីតបស្នងការខូចខាតរបស់អ្នកផ្ញើ?

យោងតាមមាត្រា ៦៧៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ "**អ្នកទទួលបញ្ញើ មានករណីកិច្ចរក្សាទុកវត្ថុបញ្ញើ ដោយព្យាយាមប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត។ បើគ្មានការយល់ព្រមពីអ្នកផ្ញើទេ អ្នកទទួលបញ្ញើ មិនអាចប្រើវត្ថុបញ្ញើបានឡើយ**"។ យោងតាមមាត្រា ៦៧៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ កថាខណ្ឌទី១ "**នៅក្នុងករណីដែលបានធ្វើឱ្យបាត់បង់ ឬធ្វើឱ្យបែកបាក់វត្ថុបញ្ញើនោះ អ្នកទទួលលបញ្ញើត្រូវសងសំណងនៃការខូចខាតនោះ**"។ កថាខណ្ឌទី២ "**ក្នុងករណីដែលបញ្ញើត្រូវបានផ្ញើឡើង តាមការទាមទាររបស់អ្នកទទួលបញ្ញើ ប្រសិនបើគ្មានការបញ្ជាក់ថាជាករណីប្រធានសក្តិទេ អ្នកទទួលបញ្ញើមិនអាចរួចផុតពីការទទួលខុសត្រូវ ចំពោះការធ្វើឱ្យបាត់បង់ ឬបែកបាក់បានឡើយ**"។

សង្កេតទៅលើអង្គហេតុខាងលើ បានឱ្យឃើញថារថយន្តត្រូវបានផ្ញើនោះ គឺផ្ញើនៅទីតាំងចំណតសម្រាប់អាជីវកម្ម និងមានការកាន់កាប់កូនសោររថយន្តដោយម្ចាស់ចំណតអាជីវកម្មនោះ។ កន្លែងផ្ញើរថយន្តនោះ មានជញ្ជាំងព័ទ្ធជុំវិញ និងរបងមិនបានចាក់សោរទេ ប៉ុន្តែមានសន្តិសុខយាមដើម្បីត្រួតពិនិត្យរថយន្តចេញចូល។ ដោយរថយន្ត ត្រូវបានគ្រប់គ្រងតាមរយៈការប្រគល់សោរ និងកាន់កាប់ដោយចំណតអាជីវកម្ម ការផ្ញើនេះជា កិច្ចសន្យាបញ្ញើ ដោយមានការទទួលខុសត្រូវនូវការខូចខាត។ ដោយភាពគ្មានការប្រុងប្រយ័ត្ន និងមិនរក្សាសុវត្ថិភាពនៃរថយន្តរបស់ភ្ញៀវ អ្នកទទួលបញ្ញើបានជិះរថយន្តភ្ញៀវចេញក្រៅ ហើយថែមទាំងធ្វើឱ្យមានការខូចខាតដល់រថយន្តភ្ញៀវទៀតផង។ ការខូចខាតនេះ បណ្តាលមកពីការធ្វេសប្រហែស និងមិនមានទទួលខុសត្រូវរបស់អ្នកទទួលបញ្ញើដោយផ្ទាល់ ដូច្នេះអ្នកទទួលបញ្ញើត្រូវទទួលខុសត្រូវនូវការខូចខាត ដោយទទួលជួសជុលរថយន្តនោះឡើងវិញ និងត្រូវទទួលខុសត្រូវសងជំងឺចិត្តតាមការទាមទាររបស់អ្នកផ្ញើ។ ករណីដែលអ្នកទទួលបញ្ញើបានធ្វើឱ្យខូចខាតដោយកំហុសខ្លួនផ្ទាល់បែបនេះ អ្នកទទួលបញ្ញើមិនអាចរួចផុតពីការទទួលខុសត្រូវបានឡើយ។

ផ្អែកទៅលើអង្គហេតុ និងអង្គច្បាប់ យើងសង្កេតឃើញថា ការខូចខាតដែលកើតឡើងដោយអ្នកទទួលបញ្ញើផ្ទាល់ គឺត្រូវតបស្នងទៅអ្នកផ្ញើដោយទទួលជួសជុលចំពោះរថយន្ត និងសងជំងឺចិត្តដល់អ្នកផ្ញើ។

### កថាភាគទី២. ករណីសិក្សាទី២

#### អង្គហេតុ

បុរសម្នាក់ ជាអ្នកលក់គ្រឿងអេឡិចត្រូនិច ដោយសង្គមមានការជឿនលឿន អ្នកលក់បច្ចុប្បន្នមិនចាំបាច់លក់ត្រឹមតែនៅហាងនោះទេ តែក៏មានសេវាកម្មអាចដឹងជញ្ជូនដល់ទីកន្លែងផងដែរ។ ការដឹកជញ្ជូន បុរសនោះបានទៅសហការជាមួយក្រុមហ៊ុនសម្រាប់ដឹកជញ្ជូនដើម្បីមានភាពងាយស្រួល និងអាចទុកចិត្តបាន ព្រោះជាភ្នាក់ងារដែលមានកិច្ចសន្យាដឹកជញ្ជូន មានទីតាំង និងមានបង់ថ្លៃសេវាច្បាស់លាស់។ ការផ្ញើក្រុមហ៊ុនដឹកជញ្ជូន គឺតម្រូវឱ្យមានការ

ដាក់តម្លៃច្បាស់លាស់អំពីតម្លៃនៃទំនិញ វាជាការបង្ការនៅពេលដែលមានការបាត់បង់ ឬខូចខាតទំនិញ ងាយស្រួលវាយតម្លៃនៃការខូចខាតនោះ។ បុរសនោះ បានយកឥវ៉ាន់ដែលជាទូរស័ព្ទដៃផ្ញើទៅ អតិថិជនដែលរស់នៅតាមបណ្តាខេត្តតាមទម្លាប់របស់ខ្លួន ដោយរាល់លើកលោកពុំបានដាក់តម្លៃពិតប្រាកដរបស់ទំនិញទេ ហើយក៏មិនមានបញ្ហាអ្វីលើទំនិញ។ ប៉ុន្តែលើកចុងក្រោយនេះ លោកបានទៅផ្ញើទូរស័ព្ទដៃទៅអតិថិជននៅតាមខេត្ត ហើយដាក់តម្លៃមិនពិតដដែល បញ្ហាក៏កើតមានឡើង ដោយទូរស័ព្ទដៃនោះត្រូវបានបាត់ ហើយលោកទាមទារឱ្យខាងក្រុមហ៊ុនសងសំណងស្មើរនឹងទូរស័ព្ទរបស់លោក។

**កំណែលំហាត់អនុវត្ត**

បុរសម្នាក់ បានផ្ញើទូរស័ព្ទដៃទៅឱ្យអតិថិជនរបស់ខ្លួននៅបណ្តាខេត្ត ដោយផ្ញើតាមក្រុមហ៊ុនដឹកជញ្ជូនដ៏ល្បីមួយ លោកពុំបានដាក់តម្លៃនៃទំនិញពិតប្រាកដនោះទេ។ ទំនិញនោះក៏បានបាត់ ដោយអតិថិជនមិនបានទទួលអីវ៉ាន់នោះពីអ្នកទទួលបញ្ញើឡើយ។ ក្នុងការបាត់បង់នេះ លោកមិនសុខចិត្ត និងបានទាមទារឱ្យខាងក្រុមហ៊ុនសងសំណងស្មើនឹងទូរស័ព្ទរបស់ខ្លួន។

តើក្នុងកាលៈទេសៈនៃការខាតបង់របស់បុរសនោះ គាត់អាចទទួលបានសំណងពេញលេញដែរឬទេ?

យោងតាមមាត្រា៨៦ កថាខណ្ឌទី១ នៃក្រឹត្យ-ច្បាប់ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ឆ្នាំ១៩៨៨ បានបញ្ញត្តថា "**អ្នកដឹកជញ្ជូនត្រូវទទួលខុសត្រូវអំពីការបាត់បង់ ឬការខូចខាតលើវត្ថុដឹកជញ្ជូន**"។ រីឯមាត្រា ៦៧៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ " **នៅក្នុងករណី ដែលអ្នកផ្ញើបានផ្ញើប្រាក់ ឧបករណ៍អាចជួញដូរបាន និងវត្ថុ ដែលមានតម្លៃខ្ពស់ផ្សេងទៀត ប្រសិនបើអ្នកផ្ញើមិនបានរាយការណ៍អំពីប្រភេទ និងតម្លៃនោះទៅឱ្យអ្នកទទួលបញ្ញើទេ តុលាការអាចបន្ថយការទទួលខុសត្រូវសងសំណងនៃការខូចខាតរបស់អ្នកទទួលបញ្ញើបាន**"។

នៅក្នុងករណី ដែលក្រុមហ៊ុនដឹកជញ្ជូនបានទទួលទំនិញមកគ្រប់គ្រង និងទទួលបានប្រាក់កម្រៃសេវាពីអ្នកផ្ញើ នេះជាកិច្ចសន្យាបញ្ញើមួយ។ ការផ្ញើតាមក្រុមហ៊ុនដឹកជញ្ជូន តម្រូវឱ្យអ្នកផ្ញើសរសេរលេខទូរស័ព្ទ ទីតាំង និងតម្លៃពិតប្រាកដរបស់ទំនិញនោះ។ លោក ពុំបានធ្វើតាមការណែនាំរបស់ក្រុមហ៊ុនទេ នៅពេលដែលទំនិញបានបាត់លោកទាមទារឱ្យក្រុមហ៊ុនសង។ ក្នុងករណីបែបនេះ ក្រុមហ៊ុនដឹកជញ្ជូនត្រូវសងនូវការខូចខាតនេះទៅអ្នកផ្ញើ ទោះបីជា មានបញ្ញត្តិច្បាប់ចែងអំពីការទទួលខុសត្រូវរបស់អ្នកទទួលបញ្ញើក៏ដោយ ប៉ុន្តែមិនមែនមានន័យថា អ្នកទទួលបញ្ញើត្រូវសងទៅតាមអ្វីដែលអ្នកផ្ញើទាមទារនោះទេ។ អ្នកផ្ញើ មិនបានប្រាប់ពីតម្លៃពិតនៅក្នុងក្រដាសសំបុត្រដឹកជញ្ជូនដែលជាភស្តុតាងបញ្ជាក់អំពីការទាមទារ នាំឱ្យខាងក្រុមហ៊ុនអាចទទួលសងត្រឹមតម្លៃដែលបានកត់ត្រាលើសំបុត្របញ្ញើ ឬតិចជាងតម្លៃនៃទំនិញនោះប៉ុណ្ណោះ។

ផ្អែកតាមអង្គហេតុ និងអង្គច្បាប់ បានឱ្យឃើញថាការទាមទាររបស់បុរសម្នាក់នោះ ដែលទាមទារសំណងស្មើនឹងតម្លៃនៃទូរស័ព្ទវិញ គឺពុំអាចធ្វើទៅបានទេ ព្រោះលោកមិនបញ្ជាក់តម្លៃនៃទំនិញពិតប្រាកដដើម្បីបង្ហាញពីតម្លៃនៃការខូចខាតពិត។ តុលាការនឹងសម្រាលនូវសំណងនៃការខូចខាតដល់អ្នកទទួលបញ្ញើ។

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទខាងលើរួចមក យើងសង្កេតឃើញថា ពីមួយជំនាន់ ទៅមួយជំនាន់ ប្រទេសមានការអភិវឌ្ឍកាន់តែរីកចម្រើនឡើង។ សកម្មភាពរបស់ប្រជាពលរដ្ឋកាន់តែមានភាពមមាញឹក ហើយទីកន្លែងរស់នៅរបស់គាត់ក៏កាន់តែចង្អៀត ដោយសារតែកំណើនប្រជាជនឥតឈប់ឈរពីមួយឆ្នាំទៅមួយឆ្នាំ។ ទន្ទឹមនឹងនេះ ទ្រព្យសម្បត្តិ និងរបស់របរប្រើប្រាស់នានា ក៏មានកាន់តែច្រើនឡើងៗ ជាហេតុធ្វើឱ្យមិនមានកន្លែងទុកដាក់បានគ្រប់គ្រាន់។ ដូច្នេះហើយបានជាតម្រូវការនៃការផ្ញើទ្រព្យសម្បត្តិរបស់ខ្លួននៅ ទីតាំងរបស់អ្នកដទៃកាន់តែមាននិន្នាការ។ ក្នុងនោះដែរ ការផ្ញើ របស់របរ ឬទ្រព្យសម្បត្តិមានតម្លៃផ្សេងៗ ក៏មានការយកកម្រៃផងដែរក្នុងពេលបច្ចុប្បន្ននេះ។ ការយកកម្រៃ ក្នុងន័យនេះអ្នកទទួលបញ្ញើបានប្រកបជាអាជីវកម្មក្នុងការមើលថែរក្សាវត្ថុបញ្ញើនោះ ដោយគិតអំពីប្រាក់កម្រៃ ហើយមានកំណត់អំឡុងពេលដែលត្រូវប្រគល់វត្ថុនោះ ទៅអ្នកផ្ញើវិញ ដូចដើម។

យ៉ាងណាមិញ ទោះបីជាមានការប្រុងប្រយ័ត្ន ដោយភ័យខ្លាចបាត់បង់ទ្រព្យសម្បត្តិក៏សម្រេចចិត្តយកទៅផ្ញើអ្នកទទួលបញ្ញើ ដោយសង្ឃឹមថាអាចមើលថែរក្សារបស់ខ្លួនបានឱ្យបានគង់ ប៉ុន្តែនៅតែមានការបាត់បង់ ឬខូចខាតដដែល ហើយថែមទាំងពុំមានអ្នកទទួលខុសត្រូវទៀតផង។ ហេតុដែលពុំមានអ្នកទទួលខុសត្រូវ ពីព្រោះតែមានបញ្ហាមួយចំនួនដូចជា ការមិនបានយល់ដឹងអំពីការទទួលខុសត្រូវទៅលើសំណងនៃការខូចខាតចំពោះវត្ថុបញ្ញើ និងលក្ខខណ្ឌដែលទាក់ទងនឹងកិច្ចសន្យាបញ្ញើជាដើម។ យោងតាមក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧ បានចែងយ៉ាងច្បាស់អំពីកិច្ចសន្យាបញ្ញើ និងការទទួលខុសត្រូវចំពោះការខូចខាត ឬបាត់បង់វត្ថុបញ្ញើ ហើយក៏ចែងអំពីការទទួលខុសត្រូវរបស់អ្នកផ្ញើផងដែរ ដោយអ្នកផ្ញើមានតួនាទីសងប្រាក់ទៅអ្នកទទួលបញ្ញើបន្ទាប់ពីទទួលបានវត្ថុរបស់ខ្លួនវិញ។

ដោយឡែក ទោះបីជាមានច្បាប់បានបញ្ញត្តិការពារផលប្រយោជន៍ដល់ភាគីទាំងសងខាងក៏ដោយ ប៉ុន្តែនៅតែមានអ្នកដែលមានភាពខ្វះខាតនូវការយល់ដឹងពាក់ព័ន្ធនឹងការទទួលខុសត្រូវនេះនៅឡើយ ដែលជាហេតុនាំឱ្យពេលកើតមានបញ្ហាមិនមានដំណោះស្រាយសមស្របមួយដល់ភាគីរងគ្រោះ។ ជាក់ស្តែង នៅក្នុងសង្គមសព្វថ្ងៃនេះបានកើតមាននូវបញ្ហាជាច្រើនពាក់ព័ន្ធនឹងការបែងចែកពុំដាច់រវាងការជួលចំណត និងកិច្ចសន្យាបញ្ញើ។ ជាសង្ខេបមក ការជួលចំណតខុសពីបញ្ញើត្រង់ថា ការជួលចំណត ម្ចាស់ទីតាំងចំណតមិនបានគ្រប់គ្រងវត្ថុនោះទេ រីឯបញ្ញើវិញ អ្នកទទួលបញ្ញើបានគ្រប់គ្រងវត្ថុ ហើយអាចផ្លាស់ទីវត្ថុគ្រប់ទីកន្លែងបាន។ ក្នុងការជួលចំណតរថយន្តវិញ ម្ចាស់ទីតាំងចំណតបានត្រឹមតែផ្តល់ទីតាំងសម្រាប់ចំណតរថយន្តប៉ុណ្ណោះ ពោលម្ចាស់ រថយន្តមិនបានប្រគល់សោរឱ្យម្ចាស់ទីតាំង ដើម្បីអាចគ្រប់គ្រងរថយន្តរបស់ខ្លួនឡើយ។ ផ្ទុយទៅវិញ បើក្នុងករណីបញ្ញើរថយន្តវិញ ជាគោលការណ៍ត្រូវតែមានការប្រគល់សោររថយន្តឱ្យអ្នកទទួលបញ្ញើ ដើម្បីបញ្ជាក់ថាអ្នកទទួលបញ្ញើបានគ្រប់គ្រង និងអាចផ្លាស់ទីរថយន្តបាន។ ក្នុងករណីនេះដែរ ប្រសិនបើទីតាំងអាជីវកម្មសម្រាប់ការផ្ញើរថយន្តវិញ មិនចាំបាច់បំពេញលក្ខខណ្ឌនៃការប្រគល់សោររថយន្តនោះទេ ព្រោះថាទីតាំងបញ្ញើមានលក្ខណៈអាជីវកម្ម ប្រាកដជាមានការទទួលខុសត្រូវទៅលើវត្ថុបញ្ញើនោះហើយ។

# អនុសាសន៍

ឆ្លងតាមការស្រាវជ្រាវ និងការតាក់តែងអត្ថបទសារណាទៅលើប្រធានបទ "**កិច្ចសន្យាបញ្ញើ**" រួចមក យើងខ្ញុំសូមផ្តល់អនុសាសន៍ក្នុងការអនុវត្តកិច្ចសន្យាបញ្ញើដើម្បីជៀសវាងកុំឱ្យមានវិវាទ។ ដូចនេះយើងខ្ញុំសូមផ្តល់ជាអនុសាសន៍ ដូចខាងក្រោមៈ

នៅក្នុងកិច្ចសន្យាបញ្ញើ សិទ្ធិ និង ករណីយកិច្ចរបស់អ្នកទទួលបញ្ញើ និងអ្នកផ្ញើ ចែងមកមានការពិបាកក្នុងការវែកញែកថាវាមាននៅក្នុងកិច្ចសន្យាបញ្ញើយកកម្រៃ ឬមិនយកកម្រៃដោយសារតែមានចែងក្នុងបញ្ញត្តិតែមួយ។ រីឯចំពោះការទទួលខុសត្រូវនៅពេលមានការបាត់បង់ ឬខូចខាត ដើម្បីងាយស្រួលបែងចែងអំពីដែននៃការទទួលខុសត្រូវសងនូវសំណងនៃការខូចខាត ដែលនាពេលកន្លងមកឃើញថា នៅមិនទាន់អាចបែងចែក និងរកអ្នកទទួលខុសត្រូវពិតប្រាកដបាននៅឡើយ។ម៉្យាងទៀត យើងឃើញថាក្នុងករណីខ្លះមានការភាន់ច្រលំព្រោះមិនមានការបញ្ជាក់ថាតើចំពោះបញ្ញើយកកម្រៃ ឬ មិនយកកម្រៃ ឬ យ៉ាងណា ។ ប្រសិនជា មានការបែងចែកឱ្យដាច់ពីគ្នាគឺវាមានភាពងាយស្រួលក្នុងការកំណត់ជាងនេះ។

ដោយហេតុម្យ៉ាងទៀតថា ប្រជាជនកម្ពុជាជាក់ស្តែងជាទូទៅមាន មនោសញ្ចេតនា និងមានសីលធម៌ខ្ពស់។ ទន្ទឹមនឹងនេះ សកម្មភាពខ្លះក៏បាននាំឲ្យកើតមានឡើងនូវបញ្ហា មួយចំនួនតូចដែរ ដូចជា ខ្វះការយោគយល់អធ្យាស្រ័យ ឬខ្វះការយល់ដឹងទាក់ទងទៅនឹងច្បាប់ពាក់ព័ន្ធក្នុងកិច្ចសន្យាបញ្ញើ យើងទាំងអស់គ្នាគួរគប្បីធ្វើការកែតម្រូវ ឬបំពេញបន្ថែមនូវចំណុចខ្វះខាតមួយចំនួនតូចនេះ។

ជាចុងក្រោយយើងខ្ញុំសង្ឃឹមថា យើងទាំងអស់គ្នាចូលរួមបំពេញនូវចំណុចខ្វះខាតខាងលើបាន នោះ និងឆ្លើយតបមកវិញនូវភាពរីកចម្រើននូវវិស័យច្បាប់ ការកាត់បន្ថយនូវវិវាទដែលពាក់ព័ន្ធទៅបញ្ញើមិនថាបញ្ញើយកកម្រៃ ឬមិនយកកម្រៃនោះទេ និងត្រូវចេះយោគយល់គ្នាទៅវិញទៅមកនៅក្នុងសង្គមសមជាប្រទេសព្រះរាជាណាចក្រកម្ពុជាលើសកលលោក។ហើយយើងខ្ញុំក៏សង្ឃឹមទៀត ថាក្រមរដ្ឋប្បវេណី និងបញ្ញត្តិឱ្យបានច្បាស់លាស់ថាតើបញ្ញត្តិណាអនុវត្តន៍ចំពោះ បញ្ញើយកកម្រៃ និងបញ្ញត្តិណាអនុវត្តន៍ចំពោះបញ្ញើមិនយកកម្រៃដើម្បីងាយស្រួលនៅក្នុងការអនុវត្ត។

# ឯកសារយោង

# ឯកសារយោង

## ១.ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត


- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧
- ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦
- ច្បាប់ភូមិបាល, លេខ នស/រកម/០៨-០១, ៣០ សីហា ២០០១
- ក្រឹត្យ-ច្បាប់ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា, លេខ ៣៨ ក្រ.ច, ២៨ តុលា ១៩៨៨។


## ២.សៀវភៅ និងអត្ថបទផ្សេងៗ


- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ឆ្នាំ២០១០, ភាគ១ គន្ថីទី១-គន្ថីទី៣
- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ឆ្នាំ២០១០, ភាគ៣ គន្ថីទី៥
- សម្តេចព្រះសង្ឃរាជ ជួន ណាត, វចនានុក្រមខ្មែរ, ការផ្សព្វផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ឆ្នាំ១៩៦៨
- ញឹក វុធ្ធី. គ្មានកាលបរិច្ឆេទ. នីតិកាតព្វកិច្ច. មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។
- ស៊ន់ សុជាតិ. ២០១៥. កិច្ចសន្យាពិសេស
- អ៊ីវ ប៉ូលី. ២០១១. មេរៀនសង្ខេបស្តីពីកិច្ចសន្យា
- បទបង្ហាញស្តីពី កិច្ចសន្យាបញ្ញើ ឧទ្ទេសនាមដោយមេធាវី មាស សារិន, ឆ្នាំ២០១៦
- មេរៀនស្តីពី ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ដោយគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់និងតុលាការ ក្រសួងយុត្តិធម៌និងJICA


## ៣. ឯកសារពិភាក្សា


- កិច្ចពិភាក្សាស្តីពី កិច្ចសន្យាជួលចំណត នៅថ្ងៃទី ២៥ កញ្ញា ឆ្នាំ២០១៦ នៅCJCC។


## ៤. គេហទំព័រ


- មាស រ៉ាវីន និងសូត្រ សុវណ្ណរាជ្យ. យល់ដឹងផ្នែកច្បាប់៖ អគ្គាធិនភាព. ដកស្រង់ចេញពី យល់ដឹងផ្នែកច្បាប់៖ អគ្គាធិនភាព (ciclg.com) ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២១
- ប៉ាន់ វាសនា. តើអ្នកណាមានសិទ្ធិចាត់ចែងប្រាក់បញ្ញើនៅធនាគារ ក្នុងករណីម្ចាស់ទទួលមរណភាព?. ដកស្រង់ចេញពី តើអ្នកណាមានសិទ្ធិចាត់ចែងប្រាក់បញ្ញើនៅធនាគារ ក្នុងករណីម្ចាស់ទទួលមរណភាព? | La Reine Media ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨។
- https://jtrustroyal.com/kh/personal/everyday-banking/term-deposit-account/
- https://www.acledabank.com.kh/kh/khm/ps_desavingacc?t=p

# ឧបសម្ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចសន្យាបញ្ញើរថយន្ត

**រវាង**

ឈ្មោះ [illegible] ភេទស្រី អាយុ២២ អត្តសញ្ញាណបណ្ណលេខ [illegible] អាសយដ្ឋានផ្ទះលេខ២២ ផ្លូវ២២ ភូមិ២២ សង្កាត់២២ ខណ្ឌ២២ ក្រុង២២ មុខរបរ លក់ចេកចៀនប្រេន ត្រូវជាម្ចាស់កម្មសិទ្ធិករលើឡានម៉ាក Lexus330 ពណ៌ស មានស្លាកលេខ[illegible] ចាប់ពីពេលនេះទៅហៅថា **ភាគី“ក”** ។ ទូរសព្ទលេខ[illegible] ។

និង

ឈ្មោះ [illegible] ភេទស្រី អាយុ២២ អត្តសញ្ញាណបណ្ណលេខ [illegible] អាសយដ្ឋានផ្ទះលេខ២២ ផ្លូវ២២ ភូមិ២២ សង្កាត់២២ ខណ្ឌ២២ ខេត្ត២២ មុខរបរ ម្ចាស់ការ៉ាសឡាន ឈ្មោះ ការ៉ាសឡាន888 ចាប់ពីពេលនេះទៅហៅថា **ភាគី“ខ”** ។ ទូរសព្ទលេខ [illegible] ។

**គូរភាគីទាំងពីរបានព្រមព្រៀងគ្នាដូចខាងក្រោម ៖**

**ប្រការ ១** ៖ ស្នើសុំផ្ញើឡានដែលមានម៉ាក ពណ៌និងស្លាកលេខដូចខាងលើ ដែលជាកម្មសិទ្ធិរបស់ខ្លួន ចំពោះ **ភាគី“ខ”** ។

**ប្រការ ២** ៖ **ភាគី“ខ”** បានយល់ព្រមតាមសំណើរបស់ **ភាគី“ក”** ហើយ **ភាគី“ក”** បានប្រគល់ឡាន ដែលជាកម្មវត្ថុនៃកិច្ចសន្យាបញ្ញើនោះនៅថ្ងៃទី២២ ខែ១២ ឆ្នាំ២០២២ ទៅឱ្យ ដើម្បីរក្សាទុកក្នុងទីកន្លែងដែលបានព្រមព្រៀងគ្នា ។

**ប្រការ ៣** ៖រយៈពេលនៃការផ្ញើនេះមានចំនួន ០១ខែ ដោយគិតចាប់ពី ថ្ងៃទី០១ ខែសីហា ឆ្នាំ២០១២ ដល់ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១២។

**ប្រការ ៤** ៖កម្រៃនៃការផ្ញើឡាននេះមានចំនួន ៣០$ (សាមសិបដុល្លារ)។ ហើយនៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០១២ **ភាគី“ក”** បានប្រគល់ប្រាក់កម្រៃចំនួន៣០$ ឱ្យទៅ**ភាគី“ខ”** ដែលជាថ្នូរនឹងការបញ្ញើឡាននោះ ។

**ប្រការ ៥** ៖ការទទួលខុសត្រូវៈ **ភាគី-ខ-** ត្រូវមានករណីយកិច្ចរក្សានូវឡាននេះឱ្យបានល្អ ។ ករណីដែល ភាគី-ខ- មានការធ្វេសប្រហែសបណ្តាលឱ្យមានព្យសនកម្មកើតឡើងជាហេតុធ្វើឱ្យឡានទទួលរងនូវការខូចខាតនោះ ភាគី-ខ- ត្រូវទទួលខុសត្រូវចំពោះការខូចខាតទាំងនោះ ត្រូវចេញសំណងការខូចខាតតាមករណីដែលបានកើតឡើងជាក់ស្តែង ។

កិច្ចសន្យានេះធ្វើឡើងដោយពិតប្រាកដ និងដោយសេរី មិនមាននូវការបង្ខិតបង្ខំ ឬការគំរាមកំហែងឡើយ គឺធ្វើឡើងដោយយើងខ្ញុំមានសតិ ស្មារតីគ្រប់គ្រាន់ហើយបានអាន និងបានស្តាប់ត្រឹមត្រូវរួចហើយ ។

កិច្ចសន្យានេះ មានសុពលភាពអនុវត្តចាប់ពីថ្ងៃ ដែលយើងខ្ញុំបានផ្តិតមេដៃស្តាំទទួលយល់ព្រមដូចតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០១ ខែសីហា ឆ្នាំ២០១២

| | | | |
|---|---|---|---|
| **សាក្សីទី១** | **សាក្សីទី១** | **ស្នាមមេស្តាំដៃភាគី-ក-** | **ស្នាមមេស្តាំដៃភាគី-ខ-** |
|  |  |  |  |


បណ្ណផ្ញើកង់ ម៉ូតូ
№ 883872
តំលៃ ..........
ថ្ងៃទី ..... ខែ ..... ឆ្នាំ .....
ហួសរយៈពេល១ថ្ងៃទុកជាអសារបង់

Scanned with CamScanner


សាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច
84043
បណ្ណផ្ញើកង់_ម៉ូតូ
ហួសម៉ោង ៨:៣០ យប់ មិនទទួលខុសត្រូវ
ថ្ងៃទី..........ខែ..........ឆ្នាំ២០២....
សម្ភារៈលើម៉ូតូបាត់បង់មិនទទួលខុសត្រូវឡើយ

Scanned with CamScanner


សាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច
53530
បណ្ណចំណតរថយន្តនិស្សិត
ហួសម៉ោង ៨:៣០ យប់ មិនទទួលខុសត្រូវ,តម្លៃ
ថ្ងៃទី...........ខែ...........ឆ្នាំ២០២....

Scanned with CamScanner


បណ្ណផ្ញើកង់ ម៉ូតូ
№ 883876
តំលៃ 1000
ថ្ងៃទី ២1 ខែ 07 ឆ្នាំ 2022
ហួសរយៈពេល១ថ្ងៃទុកជាអសារបង់

បណ្ណផ្ញើកង់ ម៉ូតូ
№ 883876
តំលៃ 1000
ថ្ងៃទី ២1 ខែ ~~07~~ ឆ្នាំ 2022
ហួសរយៈពេល១ថ្ងៃទុកជាអសារបង់

Scanned with CamScanner